វិទ្យាសាស្ត្រភាសា

# មូលដ្ឋាន

# នៃ

# សូរវិទ្យា សទ្ទតាវិទ្យា & វិជ្ជាសន្តាន

ដោយ បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់

• **អតីតសាស្ត្រាចារ្យភាសាវិទ្យា**

- នៅមហាវិទ្យាល័យអក្សរសាស្ត្រ & មនុស្សសាស្ត្រ ភ្នំពេញ
- នៅមហាវិទ្យាល័យអក្សរសាស្ត្រ & មនុស្សសាស្ត្រ នៃក្រុង អាប៊ីទ្យង់ ប្រទេសកូឌីវ័រ

• **សាស្ត្រាចារ្យបច្ចុប្បន្នខាងភាសាវិទ្យា**

នៅរាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ

រក្សាសិទ្ធិ

ចេញលើកទី៤ នៅខែកក្កដា ឆ្នាំ២០១៣

# បុព្វកថា

## សម្រាប់ការផ្សាយចេញមុនៗបីរលើក

សៀវភៅសិក្សាពីភាសាដែលសរសេរជាភាសាខ្មែរ ក៏ដូចសៀវភៅមុខវិជ្ជាឯទៀតដែរ នៅមិនទាន់មានច្រើនបរិបូណ៌ទេ។ បើនិយាយពីវិទ្យាសាស្ត្រភាសាវិញ ក៏រឹតតែខ្វះទៅទៀត។ ខ្ញុំបានសង្កេតឃើញថា និស្សិតខ្មែរយើងច្រើនខ្សោយខាងភាសា ទោះខាងភាសាអង់គ្លេសក៏ដោយ។ បើភាសាបារាំងវិញ មិនបាច់និយាយទេ ! ។

ដូច្នេះហើយ គាត់ពិបាកចាប់យកចំណេះខាងភាសាវិទ្យាទូទៅតាមរយៈភាសាបរទេសណាស់ : ខ្ញុំក៏សម្រេចចិត្តបោះផ្សាយជាភាសាខ្មែរបណ្ដើរៗ តាមរយៈកូនសៀវភៅតូចៗ **(នេះជាលើកទីបីហើយ ទាក់ទងនឹងសូរវិទ្យា សទ្ទតាវិទ្យា និង វិជ្ជាសន្ទាន)** ដើម្បីអោយនិស្សិតខ្មែរមានលទ្ធភាពចាប់យកចំណេះខាងភាសាវិទ្យា តាមរយៈភាសាកំណើតសិន ជាចំណេះមូលដ្ឋានសិន មុននឹងឈានទៅរកចំណេះទូលំទូលាយតាមរយៈភាសាបរទេស ។

និស្សិតខ្មែរខ្លះបានត្អូញត្អែរពីវាក្យស័ព្ទថ្មីៗ ដែលគាត់យល់ថា ជាឧបសគ្គដល់ការងាយយល់។ អ្នកខ្លះ ដែលចេះភាសាបរទេសនៅស្ទើរនៅឡើយ នឹកស្មានថាគាត់អាចយល់ឆាប់រហ័សបើយើងប្រើភាសាបរទេសជាយាន។ ប្រាកដណាស់ យើងមិនអាចចៀសភាសាបរទេសបានទេ : បើនិស្សិតខ្មែរមិនអានសៀវភៅជាភាសាបរទេសទេ គាត់ប្រាកដជាមុជមិនជ្រៅទៅមិនឆ្ងាយឡើយ ពីព្រោះដូចបានពោលខាងលើរួចមកស្រាប់ យើងនៅខ្វះសៀវភៅជាភាសាខ្មែរ។ ប៉ុន្តែ ដើម្បីមើលយល់ជក់ចិត្តនឹងវិជ្ជាដែលថែងក្នុងសៀវភៅអ្វីមួយ ទោះក្នុងភាសាណាក៏ដោយ អ្នកអានត្រូវមានចំណេះមូលដ្ឋានសិន ហើយ ទោះក្នុងវិជ្ជាណាក៏ដោយ ក៏គេមិនអាចចៀសពាក្យបច្ចេកទេសបានឡើយ។ ពាក្យបច្ចេកទេសនៃវិទ្យាសាស្ត្រភាសា ដែលសរសេរជាភាសាបារាំងមិនមែនជាពាក្យដែលជនជាតិបារាំងធ្លាប់ស្គាល់នោះទេ តែពាក្យទាំងនោះក៏មិនមែនជាឧបសគ្គក្នុងការរៀនវិជ្ជានេះដែរ ពីព្រោះ គេតែងតែកំណត់ន័យច្បាស់លាស់ និង ពន្យល់ដោយក្បោះក្បាយ : ចំពោះពាក្យបច្ចេកទេសក្នុងភាសាខ្មែរវិញក៏ដូចគ្នានេះដែរ ។

និស្សិតខ្មែរមួយចំនួនតែងតែត្អូញត្អែរពីការខ្វះឯកភាពក្នុងវាក្យស័ព្ទ ឬ ពីគំនិតប្លែកគ្នាឬខ្វែងគ្នារវាងភាសាវិទូ/សាស្ត្រាចារ្យភាសាវិទ្យា។ ការខ្វះឯកភាពខាងវាក្យស័ព្ទឬខាងគំនិត វាតែងតែមានកាលណាមុខវិជ្ជានៅថ្មី កាលណាគេកំពុងរាវរក ទោះនៅប្រទេសជឿនលឿនក៏ដោយ។

សូមអស់លោកអ្នកអានមេត្តាជួយធ្វើការទិតៀនស្ថាបនា តាមការគួរ ដើម្បីអោយខ្ញុំមានលទ្ធភាពកែតម្រូវនិងកែលំអ សម្រាប់បញ្ចូលជាមួយផ្នែកឯទៀត នៅពេលក្រោយ អោយទៅជាសៀវភៅមួយក្បាលធំនៃភាសាវិទ្យាដែលមានគ្រប់មែកធាង។


បណ្ឌិត **ព្រុំ ម៉ល់**

សាស្ត្រាចារ្យភាសាវិទ្យា នៅរាជបណ្ឌិត្យសភាកម្ពុជា

# បុព្វកថា

## សម្រាប់ការផ្សាយចេញលើកទី៤

ចាប់ពីខែកក្កដា ឆ្នាំ២០០៣ កូនសៀវភៅ "មូលដ្ឋាននៃសូរវិទ្យា សទ្ទតា & វិជ្ជាសន្ទាន" នេះ ផ្សាយចេញបានបីលើកហើយ ដោយមានសេចក្ដីត្រូវការពីនិស្សិតខាងភាសាវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជា និង ប្រហែលពីនិស្សិតនៃគ្រឹះស្ថានសិក្សាក្រៅខ្លះទៀតផងក៏មិនដឹង ។

នៅលើកទី៤នេះ កូនសៀវភៅមូលដ្ឋាននេះ ត្រូវបានខ្ញុំធ្វើបច្ចុប្បន្នភាពទាក់ទងនឹងបច្ចេកសព្ទមួយចំនួនដែលភាគច្រើនត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.), ឧ.ប្រតិចារឹកអក្សរ (translitération) ជំនួស "អក្សរវិធីសំណង", អក្ខរក្រមសូរវិស័យអន្តរជាតិ (Alphabet phonétique international/API) ជំនួស "សញ្ញាសូរវិធីអន្តរជាតិ", កាឡូសូរ (allophones) ជំនួស "បណ្ដាសូរ", ការលើកដាក់សំឡេង (intonation) ជំនួស "សូររលក/រលកសូរ",...។ ក្រៅពីនេះ ខ្ញុំក៏បានលើកការប្រៀបធៀបសូរនៃភាសាខ្មែរនិងអក្សរខ្មែរ ទៅដាក់ខាងក្រោយការសិក្សាអំពីសូរនិងអំពីសទ្ទតានៃភាសាខ្មែរផងដែរ ។

ដោយខ្ញុំត្រូវបោះចេញឡើងវិញនូវកូនសៀវភៅមូលដ្ឋាននេះមុនថ្ងៃសម្ពោធអគារបណ្ឌិតសភាចារ្យ ខ្ញុំឥតមានពេលពិនិត្យឡើងវិញ មួយពាក្យៗ មួយបន្ទាត់ម្ដងៗ មួយទំព័រម្ដងៗ ខ្ញុំគ្រាន់តែពិនិត្យចំណុចសំខាន់ៗ ហើយ ចោលភ្នែកលើទិដ្ឋភាពទូទៅ : ដូច្នេះ ខ្ញុំជឿជាក់ថា កំណែប្រាកដជាមានការខ្វះខាតនិងការភ្លាំងភ្លាត់មិនខាន។ សូមមិត្តអ្នកអានមេត្តាអនុគ្រោះ ។ ខ្ញុំនឹងកែបង្គ្រប់នៅពេលក្រោយ បើខ្ញុំមានពេល ។

ខ្ញុំបញ្ជាក់ផងដែរថា ការប្រៀបធៀបសទ្ទតាខ្មែរទៅនឹងសទ្ទតាបាលី/សំស្ក្រឹតជាការចាំបាច់ចំពោះនិស្សិតខាងភាសាវិទ្យានិងអ្នកស្រាវជ្រាវ ។ អ្នកធម្មតាប្រាកដជាសង្កេតឃើញថា វាមានភាពស្មុគស្មាញនាំឱ្យគេវិលវល់ ។ ការយល់បែបនេះប្រាកដជាត្រឹមត្រូវ ពីព្រោះគេគ្រាន់តែចង់រៀនអក្សរខ្មែរឱ្យចេះអាននិងចេះសរសេរប៉ុណ្ណោះ ប៉ុន្តែ និស្សិតឬអ្នកស្រាវជ្រាវខាងភាសាវិទ្យាត្រូវដឹងថា សទ្ទតាខ្មែរនិងសទ្ទតាបាលី/សំស្ក្រឹត មានបន្លែករវាងគ្នាមួយចំនួន ហើយ គួរអ្នករៀនភាសាបាលីនៅប្រទេសកម្ពុជាចាប់អារម្មណ៍លើបញ្ហានេះផងដែរ ។

ខ្ញុំត្រូវបន្ថែមទៀតថា បន្លែករវាងសទ្ទតាខ្មែរនិងសទ្ទតាបាលី/សំស្ក្រឹត ព្រមទាំងករណីស្រៈនិស្ស័យផង ជាបញ្ហាស្មុគស្មាញដែលត្រូវការស្រាវជ្រាវបន្ត។ ខ្ញុំសង្ឃឹមថា អ្នកស្រាវជ្រាវជំនាន់ក្រោយ (រវាង៣០ឬ៤០ឆ្នាំទៀត) ដែលបានឆ្លងផុតពីមតិច្របូកច្របល់សព្វថ្ងៃ អាចវិភាគពិចារណាដោយឯករាជ្យ ឥតទើសទាល់ លើបញ្ហានេះ។ សូរវិទ្យាគ្រាន់តែជាមែកធាងមួយនៃភាសាវិទ្យា ហើយ ភាសាវិទ្យាគ្រាន់តែជាវិទ្យាសាស្ត្រភាសាដែលគ្រាន់តែជាឧបករណ៍មួយសម្រាប់សំលៀងប្រាជ្ញ : គេមិនត្រូវយកវាធ្វើជាឧបករណ៍ដើម្បីធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋាននៃអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដែលបុព្វជនយើងបានបន្សល់ទុកនោះឡើយ ។

ភ្នំពេញ ថ្ងៃចន្ទ ទី១ ខែមេសា ឆ្នាំ២០១៣

បណ្ឌិតសភាចារ្យ **ពុំ ច័ណ**

# សូរវិទ្យា

សូរវិទ្យា មានផ្នែកធំៗសំខាន់ពីរ គឺ ÷

- សូរវិទ្យាអាគូស្ទិក (phonétique acoustique) ដែលសិក្សាពីទម្រង់ (structure) នៃសូរ ដើម្បីអោយយល់ពីសូរទូទៅ និង ដើម្បីជាមូលដ្ឋានដល់សូរវិទ្យាបន្លឺ ។

- សូរវិទ្យាបន្លឺ (phonétique articulatoire) ដែលសិក្សា អំពីការបង្កើតសូរនៃភាសាតាមរយៈប្រដាប់បន្លឺសំឡេង/សូររបស់មនុស្ស និង អំពីលក្ខណៈផ្សេងៗនៃសូរទាំងនោះ ។

## សញ្ញាណខ្លះៗនៃសូរវិទ្យាអាគូស្ទិក

**(Notions de phonétique acoustique)**

**បុព្វយោគ :**

កាលពីថ្ងៃទី ១៣ ឧសភា ២០០៣ ក្នុងសន្និសីទស្តីពីវេជ្ជវិទ្យា នៅរាជបណ្ឌិត្យសភាកម្ពុជា អ្នកចូលរួមមួយក្រុមមិនស្គាល់ន័យរបស់ពាក្យ "អនុសាសន៍" (ប្រហែលជាមានមួយភាគធំផងក៏មិនដឹង!) ហើយលោកវេជ្ជបណ្ឌិតចំណាស់ម្នាក់បានជួយដោះស្រាយបញ្ហាដោយនិយាយកំប្លែងថា : "គេប្រែជាខ្មែរថា [រ៉ុ-កុំមង់ដាស្យុង] "។ រឿងនិទាននេះបានបង្ហាញអោយឃើញថា ពាក្យខ្មែរមួយចំនួន ដែលកើតឡើងដោយធាតុបាលី (ឬសំស្ក្រឹត) បានបង្កើតបញ្ហាដល់សាធារណជនខ្មែរជាច្រើន ជាពិសេស កាលណាពាក្យនោះមានលក្ខណៈមិនធម្មតា ដូចពាក្យ "អនុសាសន៍" នេះឯង[១] ឬ កាលណាពាក្យនោះមិនមែនជាពាក្យបច្ចេកទេសរបស់មុខវិជ្ជាណាមួយ[២] ។

---

១ : ពាក្យ "អនុសាសន៍" មានលក្ខណៈមិនធម្មតា ពីព្រោះគេធ្លាប់ស្គាល់ន័យ "អនុ" ថា "តូច/បន្ទាប់ពីអ្វីដែលធំ" ។ សាធារណជនអាចយល់ថា "អនុសាសន៍" មិនមែនជា "សំណើ" ទេ តែជា"សាសន៍តូចតាច" ទៅវិញ ។

២ : ពាក្យបច្ចេកទេសរបស់មុខវិជ្ជាណាក៏ដោយត្រូវបានគេកំណត់ន័យច្បាស់លាស់ ដើម្បីអោយអ្នកសិក្សាវិជ្ជានោះយល់ន័យ និង ចាប់ជាប់នូវវិជ្ជានោះ ។

សេចក្ដីខាងលើនេះរំលឹកខ្ញុំមិនអោយបង្កើតពាក្យមិនធម្មតានាំអោយអ្នកសិក្សាមានការពិបាក ។ ម្យ៉ាងទៀត ខ្ញុំក៏ដឹងដែរថា ស្ទើរតែនៅគ្រប់ប្រទេស គេប្រើដូចៗគ្នានូវពាក្យបច្ចេកទេសជាច្រើនក្នុងរូបវិទ្យា ។ ប៉ុន្តែ ខ្ញុំសុំ(សេចក្ដីអនុញ្ញាត) ភ្ជាប់ពាក្យកម្លាយបែបខ្មែរសុទ្ធសាធជាមួយពាក្យបរទេសសកលដើម្បីជាជំនួយដល់អ្នកសិក្សាដែលពូកែភាសាខ្មែរ ហើយ នៅស្ទើរខាងភាសាបរទេស ។ ខ្មែរភាគច្រើនមិនយល់ថា SARS[៣] ជាជំងឺបែបណាទេ ថា "អេឌីប៊ី"[៤] ជាអ្វីទេ -ល- ។ ក្នុងការនិយាយ/ការសរសេរជាសាធារណៈ ការប្រើពាក្យបរទេសបែបនេះជារបាំងរវាងខ្មែរអ្នកចេះភាសាបរទេសនិងខ្មែរឯទៀត ។

ចំពោះពាក្យកម្លាយបែបខ្មែរដើម ខ្ញុំសុំរំលឹកថា ដើម្បីបង្កើតនាមស័ព្ទសម្គាល់លទ្ធផល/អំពើ គេប្រើអន្តេបទ[៥] [-អម្ន/អ៊ម្ន-] (ឬ កាឡាសូរ [-អម/អ៊ម-]) អន្តេបទ [-ប-][៦] និង បុព្វបទ [លំ-][៧] ។

## ១ - <u>**កំណើតសូរ** & **លក្ខណៈសំខាន់ៗនៃសូរ** (production du son)</u> :

---

[៣] SARS ជាកន្សោមពាក្យកាត់នៃភាសាអង់គ្លេស កើតមកពីកន្សោម (មិនទាន់កាត់) ថា "Severe Acute Respiratory Syndrome" ។

[៤] ពាក្យបរទេស យើងអាចឮគេនិយាយឬអាចឃើញគេសរសេរ ។ ខ្ញុំបានលើកឧទាហរណ៍ពីរ : មួយតាមអក្សរ និង មួយទៀតតាមសូរសំឡេង ។ "អេឌីប៊ី" អាចចេញជាអក្សរ "ADB" ប៉ុន្តែ ក្នុងការសរសេរ គេច្រើនប្រើពាក្យ "ធនាគារអភិវឌ្ឍន៍អាស៊ី" វិញ ។

[៥] បណ្ឌិត នៅ ស៊ុន បានស្នើអោយទុកពាក្យ "អន្តរាបទ" សម្រាប់ប្រែពាក្យបារាំងថា "interfixe" : ក្រោយពីបានពិចារណាយូរបន្តិចមក ខ្ញុំក៏បានយល់ស្របនឹងគំនិតរបស់គាត់ ហើយ ប្រែពាក្យបារាំង "infixe" ថា "អន្តេបទ" វិញ ។

[៦] អន្តេបទ [-ប-] ប្រើជាមួយពាក្យឫសដែលមានព្យញ្ជនៈ /យ/ , / រ / & /ល/ នៅខាងដើម : យល់ > យ្បល់ > យោបល់/រៀប > រប្បៀប > របៀប/លាយ > ល្បាយ ។

[៧] បុព្វបទ [លំ-] ជាលទ្ធផលនៃការសម្របសូរ : នាំ + អន្តេបទ [-អ៊ម.ន-] > នអ៊មនាំ > <u>ន</u>ំនាំ > <u>លំ</u>នាំ (បុព្វបទ [លំ-] មិនមែនជាបុព្វបទតាំងពីដំបូងនោះទេ ។ ពីដើម គេប្រើវាតែជាមួយពាក្យឫសណាដែលមានព្យញ្ជនៈ/ន/ នៅខាងដើម ។ ក្រោយមកគណៈកម្មការខេមរយានកម្មបានប្រើជាមួយពាក្យឫសដែលមានព្យញ្ជនៈ/ហ/ & /ញ/ នៅខាងដើម : ហាត់ > លំហាត់ & ញ័រ > លំញ័រ) ។ លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម មានយោបល់ថា ពាក្យ "លំហើយ" មិនមែនកើតឡើងដោយ លំ + ហើយ ទេ តែជាពាក្យ "រហើយ" ផ្សំជាមួយអន្តេបទ /-ɔm-/ ដែលអោយជាពាក្យ "រំហើយ" និង ដែលអាចប្រើស្របគ្នានឹងពាក្យ "លំហើយ" : ខ្ញុំក៏យល់ដូចគាត់ដែរ ។ អ្នកស្រាវជ្រាវខ្លះថា ភាសាខ្មែរគ្មានអន្តេបទ /-អម.ណ/ ឬ /អ៊ម.ន-/ ទេ គឺមានតែ [-អម-/-អ៊ម-] ។ ប៉ុន្តែ នេះគ្រាន់តែជាមតិមួយដែលត្រូវពិនិត្យឱ្យវែងឆ្ងាយទើបយកជាការបាន ។

សូរ ដែលកើតឡើងក្នុងធម្មជាតិក្តី ឬ ដោយសារស្នាដៃមនុស្ស/សត្វក្តី សុទ្ធតែចេញពីការប៉ះទង្គិចគ្នារវាងកម្លាំងអ្វីមួយ ( ការបក់បោក, ការជ្រុះ, ទំនាញ, គំនោះ, បន្លុំ,...) និងវត្ថុអ្វីមួយ ( ស្លឹកឈើ, ខ្សែ, ស្គរ, ខ្លុយ,...) ។ ការប៉ះទង្គិចបណ្តាលឱ្យវត្ថុនេះមានលំញ័រ ( ធ្វើអោយវាញ័រ) ។

**១.១ - <u>លំញ័រ ( < ញ័រ), (vibrations)</u> :**

លំញ័រគឺជារបិត ( < រត់ ) ទៅមក១យ៉ាងរឆាប់ ពីចំណុច $A_1$ ទៅ $A_2$ និង ពី $A_2$ មក $A_1$ វិញ ដោយឆ្លងកាត់តាម $A_0$ ( $A_0$ ជាចំណុចនៅនឹងមួយកន្លែង កាលណាគ្មានការកម្រើក) ។




<u>រូបតាងទី១</u> (Fig 1)




<u>រូបតាងទី២</u> (Fig 2)




<u>រូបតាងទី៣</u> (Fig 3)

**<u>សេចក្តីពន្យល់</u> :**

(១) - រូបតាងទី១តាងខ្សែដែលគេចងជាប់នៅចំណុច $M_1$ និង $M_2$ ។

- ចំណុច $A_0$ ជាចំណុចចំពាក់កណ្តាលខ្សែ ដែលគេសន្ទឹង ហើយ ដែលគេមិនទាន់ទាញ ។
- ចំណុច $A_1$ ជាទីសម្គាល់ចំណុចឆ្ងាយបំផុតដែលគេបានទាញខ្សែឡើងទៅលើ ។
- ចំណុច $A_2$ ជាចំណុចសមប្បមាណ[៨] (symétrie) របស់ $A_1$ ។ កាលណា គេទាញខ្សែដល់ចំណុច $A_1$ រួចគេលែងវាទៅ ខ្សែនោះនឹងវាត់ចុះក្រោមទៅដល់ចំណុច $A_2$ ដោយឆ្លងកាត់តាមចំណុច

---

[៨] : ពាក្យ "សមប្បមាណ" ត្រូវនឹងពាក្យបារាំង "symétrie" ជាពាក្យខ្ចីពីវចនានុក្រម បារាំង-ខ្មែរ របស់លោក តិប យក់ & ថាវ គន្ធ បណ្ណាគារ ប៊ុតនាង ភ្នំពេញ ឆ្នាំ ១៩៦២ ដែលក្នុងនោះ គេអាចស្គាល់ធាតុ "សម" និង "មាណ" គឺជាពាក្យដែលខ្មែរធម្មតាអាចយល់បាន ។

$A_0$ : ចម្ងាយ $A_1A_0$ និងចម្ងាយ $A_0A_2$ មានប្រវែងស្មើគ្នា ។

(២) - រូបតាងទី២តាងបន្ទោងព្យួរ ។ ចំណុច $A_0$ , $A_1$ & $A_2$ និង ចម្ងាយ $A_1A_0/A_0A_2$ ក្នុងរូបតាងទី២ មានលក្ខណៈដូចគ្នានឹងចំណុច $A_0$ , $A_1$ & $A_2$ ឬ ចម្ងាយ $A_1A_0/A_0A_2$ របស់រូបតាងទី១ដែរ ។

(៣) - រូបតាងទី៣ជាវិធីតាងលំញ័រនិយ័ត[៤]/ទៀងទាត់ ដែលអ្នកវិទ្យាសាស្ត្រខាងរូបវិទ្យានិយមប្រើ :

- បន្ទាត់ xy តាងពេលវេលា : ចម្ងាយ ab / bc / ac ស៊ីពេលអស់មួយកំឡុង ។
- គំនូស adb តាងខ្សែ $M_1$ $M_2$ ដែលគេទាញឡើងដល់ចំណុច $A_1$ ។
- គំនូស bd'c តាងខ្សែ $M_1$ $M_2$ ដែលវាត់ធ្លាក់ចុះទៅក្រោមដល់ចំណុច $A_2$ ។
- ចម្ងាយ ed & e'd' តាងចំណុចខ្ពស់បំផុតដែលខ្សែទៅដល់ ។
- ចម្ងាយ ac តាងរបិត (< រត់) ទៅមក (ទៅម្តង មកម្តង) របស់ខ្សែ ដែលបាន បង្កើតលំញ័រមួយឡើង (សូមអានឡើងវិញនូវការកំណត់ន័យនៃលំញ័រខាងលើ) ។

**១.២ - វេលា (période) ឬ វដ្ត (cycle) :**

លំញ័រ ជាការកម្រើក ជាចលនា ដូច្នេះហើយ វាត្រូវស៊ីពេលដែលគេហៅថា វេលា ឬ វដ្ត ។ វេលា/វដ្តជាពេលដែលលំញ័រចំណាយ ដើម្បីទៅមកពីចំណុច $A_1$ ទៅ $A_2$ និង ពី $A_2$ មក $A_1$ វិញ ។

**១.៣ - រលក (ondes) :**

លំញ័របង្កើតជារលក ដែលចាកចេញពីចំណុចកំណើតទៅតាមអាកាសគ្រប់ទិសទី (ដូចរលកលើទឹកដែលមានរង្វង់ធំទៅៗជុំវិញកន្លែងដែលយើងបានបោះដុំថ្មក្នុងទឹកដូច្នោះដែរ) ដោយមានល្បឿន៣៤០មក្នុង១វិនាទី ។ កាលណារលកនោះទៅប៉ះនឹងក្រដាសត្រចៀកយើង វាក៏ក្លាយទៅជាសូរដែលត្រចៀកស្តាប់ឮ ។ (ដើម្បីជាការប្រៀបធៀប គួរកត់សម្គាល់ថាពន្លឺមានល្បឿន ៣០០,០០០ គ.ម.ក្នុង១វិនាទី ) ។

---

[៤] ពាក្យ "និយ័ត" ត្រូវនឹងពាក្យបារាំង "régulier" ក៏ជាពាក្យខ្ចីពីវចនានុក្រម បារាំង-ខ្មែរ របស់ លោក តិប យក់ & ថាវ គន្ធ ដែរ ។

**១.៤ - លំញោប់** (< **ញោប់**), (fréquence) & **ហឺត្ស** (Hertz) :

លំញោប់ជាចំនួនវេលា/វដ្តក្នុង១វិនាទី ។ កាលណាលំញ័រមានល្បឿនរហ័ស វាមានលំញោប់ខ្ពស់ ។ កាលណាល្បឿនវាយឺត លំញោប់ក៏ត្រូវទាបទៅដែរ ។ គេរាប់លំញោប់ដោយប្រើខ្នាតមួយឈ្មោះថា ហឺត្ស ដែលគេច្រើនស្គាល់តាមអក្សរកាត់ថា Hertz/ Hz នៃអក្ខរក្រមឡាតាំង ។ ហឺត្សជាខ្នាតសម្គាល់លំញ័រដែលមាន១វេលា/១វដ្ត ក្នុង១វិនាទី ។ លំញ័រដែលមាន១០០វេលា/១០០វដ្តក្នុង១វិនាទី គឺជាលំញ័រដែលមានលំញោប់ ១០០ ហឺត្ស ។

កាលណាលំញ័រមានលំញោប់ខ្ពស់ សូរវាស្រួយ/ឆ្មារ/គ្រលួច ហើយ កាលណាវាមានលំញោប់ទាប សូរវាធំ/ គ្រលរ ។ លំញោប់ (ខ្ពស់ ឬ ទាប) គឺអាស្រ័យនឹងវត្ថុលំញ័រ (ធាតុនៃវត្ថុ/រាងវា/មាឌវា/តំណឹងវា ....), ឧទាហរណ៍ : ខ្សែមួយមានលំញ័ររហ័សឬយឺត (មានលំញោប់ទាបឬខ្ពស់) ទៅតាមស្ថានភាពនៃទំនាញ (ថាតើគេទាញអោយតឹងខ្លាំង ឬ ទាញមិនខ្លាំង) ។ បើខ្សែពីរធ្វើពីវត្ថុធាតុខុសគ្នា ឬ មានទំហំខុសគ្នា ខ្សែទាំងពីរនោះមានលំញ័រខុសគ្នា ទោះជាគេទាញវាអោយតឹងដូចគ្នាក៏ដោយ ។

**១.៥ - កម្ពស់** (hauteur) :

កម្ពស់ជាគុណភាពអញ្ញថាហេតុ (subjectif) នៃសូរ (ផ្ទុយពីយថាហេតុ) ។ កម្ពស់ និង លំញោប់ដើរស្របគ្នា ÷ កាលណាសូរមានលំញោប់ខ្ពស់ វាក៏មានកម្ពស់ខ្ពស់ដែរ ហើយ បើសូរមានលំញោប់ទាប វាក៏មានកម្ពស់ទាបទៅតាមនោះដែរ ប៉ុន្តែ គេថាកម្ពស់ជាគុណភាពអញ្ញថាហេតុ ពីព្រោះកម្ពស់និងលំញោប់មិនឡើង ឬ មិនចុះស្របគ្នាជាប្រក្រតីទេ ។ ត្រចៀកចាប់ឮសូរទៅតាមមាត្រដ្ឋានឡូហ្គារីត (échelle logarithmique) គឺថា ត្រចៀកអាចឮសូរ ប្លែកគ្នាពីចន្លោះមួយទៅចន្លោះមួយ ។ បើនៅក្នុងចន្លោះដដែល ត្រចៀកក៏ឮសូរដដែលដែរ ទោះសូរនោះប្តូរលំញោប់ក៏ដោយ (យើងនឹងអាចឮសូរផ្សេង លុះណាមានការឆ្លងផុតពីចន្លោះ១ទៅចន្លោះ១) ប៉ុន្តែ កម្ពស់ក៏ដូចលំញ័រដែរ បណ្តាលអោយសូរមានភាពគ្រលួចឬគ្រលរទៅតាមកម្រិតកម្ពស់នោះ ។ ក្នុងការសិក្សាពីសូរសៀងនៃការនិយាយស្តី (សូរសៀងវិទ្យា) គេតែងនិយាយពីកម្ពស់នៃសូរ (la hauteur du son) ដែលប្លែកពីប្រពលភាព (intensité) នៃសូរ ។

**១.៦ - ល្បឿង (< ឡើង), (amplitude) :**

ល្បឿងគឺជាចំណុចខ្ពស់បង្អស់ដែលលំញ័រឡើងទៅដល់ គឺកម្ពស់ $A_0A_1$ ឬ $A_0A_2$ (រូបតាងទី១) ឬ ed / e'd' (រូបតាងទី២) ។ ល្បឿងខ្ពស់ឬទាប វាអាស្រ័យនឹងកម្លាំងដែលបានប្រព្រឹត្តទៅលើវត្ថុលំញ័រ ។

**១.៧ - ប្រពលភាព (intensité) :**

ប្រពលភាពគឺជាមាឌ (volume) នៃសូរដែលស្របទៅតាមល្បឿង។ ប្រពលភាពមានកម្រិតខ្លាំង កាលណាល្បឿងមានកម្រិតខ្ពស់។ វាមានកម្រិតខ្សោយ កាលណាល្បឿងមានកម្រិតទាប។ ប្រពលភាពនិង ល្បឿងមានដំណើរការស្របគ្នា (ធំឬតូច ខ្ពស់ឬទាបទៅតាមគ្នា) ។

**១.៨ - ល្បឺ (< លឺ/ឮ), (timbre) :**

ល្បឺជាគុណភាព ដែលបណ្តាលអោយសូរពីរផ្សេងគ្នាមានភាពខុសគ្នា ទោះសូរទាំងពីរនោះមានកម្ពស់ និងប្រពលភាពស្មើគ្នាក៏ដោយ ពីព្រោះវត្ថុលំញ័រទាំងពីរដែលបានបង្កើតសូរនោះ មានធាតុ(ធ្វើពីដែក, ពី ស្ពាន់, ពីឈើ,...)ខុសគ្នា និង មានកម្ទរខុសគ្នា (កម្ទរ < ខ្ទរ) ។

**២ - ធាតុភូតឧបសម្ព័ន្ធនៃសូរ :**

**២.១ - សូរទោល និង សូរល្បាយ :**

សូរអាចជាសូរទោល ឬ ជាសូរល្បាយ ÷

- សូរទោលកើតចេញពីលំញ័រស្មើមិនផ្លាស់ប្តូរ ដែលមានលំញាប់តែមួយ។
- សូរល្បាយកើតពីលំញ័រច្រើនរួមគ្នា ដែលមានលំញាប់ជាច្រើនលាយគ្នា។

សូរដែលត្រចៀកយើងឮច្រើនតែជាសូរល្បាយ ពីព្រោះកាលណាវត្ថុណាមួយមានលំញ័រ ចំណែកនៃ វត្ថុនោះក៏មានលំញ័រផងដែរ ដូច្នេះហើយ វាតែងតែមានលំញាប់ជាច្រើនលាយគ្នា ហើយ យើងបានដឹងថា លំញាប់មួយបែបជាលក្ខណៈនៃរលកមួយបែប ឬ នៃសូរមួយបែប។ បើមានលំញាប់ច្រើនបែបលាយគ្នា គឺ

វាមានសូរច្រើនបែប (លាយគ្នា) ដែរ ។ ចំណែក ដែលជាភាគពាក់កណ្តាលនៃវត្ថុលំញ័រ មានលំញ័រ២ដង លើសវត្ថុលំញ័រទាំងមូល ។ ចំណែក ដែលជាចំណែកមួយភាគបី មានលំញ័រ៣ដងលើសវត្ថុលំញ័រទាំងមូល - ល - ។




<u>រូបតាងទី៤</u>[១០]

- $A_0A_1$, $A_0A_2$ = លំញ័ររបស់ខ្សែ
- $a_0a_1$, $a_0 a_2$, $a'_0a'_1$ & $a'_0a'_2$ = លំញ័ររបស់ចំណែកពាក់កណ្តាលនៃខ្សែ ។

- លំញ័ររបស់វត្ថុទាំងមូល (ខ្សែ) អោយកំណើតជាសូរគ្រឹះ (fondamental) : សូរគ្រឹះនេះ ឯងផ្តល់កម្ពស់ដល់សូរល្បាយ ។

- លំញ័ររបស់ចំណែកនៃខ្សែអោយកំណើតជាសូរសាខា (harmoniques) ហើយ សូរសាខានេះ ផ្តល់ល្បឺដល់សូរល្បាយ ។

## **២.២ - <u>គម្ងរនៃសូរ</u>** <u>(résonance du son)</u> :

វត្ថុ ដែលមានឃ្មឹត (ឃ្មឹត < ឃឹត : ដែលឃឹតដូចកៅស៊ូ) ហើយ ដែលនៅតាមផ្លូវរលករបស់សូរណាមួយតែងតែញ័រក្រោមឥទ្ធិពលនៃរលកសូរនោះ ។ លំញ័ររបស់វត្ថុដែលឃឹតនោះមានលំញាប់ដូចលំញាប់របស់សូរមេដែលមានឥទ្ធិពលលើវត្ថុឃ្មឹតដែរ : គឺនេះហើយ ដែលជាបាតុភូតគម្ងរ (phénomène de résonance) ។ វត្ថុដែលមានលំញ័របែបនេះហៅថា វត្ថុគម្ងរ/ គម្ងរករ (Résonateur) ។

---

១០ : រូបតាងខ្ចីពី Bertil Malmberg, La phonétique, PUF 1975, p.11 ។

**២.៣ - <u>លំញាប់បំប៉ន</u>** <u>(formant)</u> :

ដោយសារគម្ពុរករ គេអាចបំប៉នលំញាប់ណាមួយក្នុងសូរល្បាយ តាមចំណង់ ពីព្រោះលំញ័រពីរដែលមានលំញាប់ដូចគ្នា បញ្ចូលកម្លាំងគ្នាអោយទៅជាលំញ័រមួយថ្មីដែលខ្លាំងពីរដងលើសលំញ័រទាំងពីរដាច់គ្នា ។




<u>រូបតាងទី៥</u>

<u>អក្សរកាត់</u> - ញ = លំញាប់នៃសូររបស់វត្ថុលំញ័រ, ញ១, ញ២,... = លំញាប់នៃសូររបស់ចំណែកនៃវត្ថុលំញ័រ ។

ឧបករណ៍ធ្វើសម្រាប់បំប៉នលំញាប់នៃសូរល្បាយហៅថាតម្រង ។ លំញាប់ ដែលបានប្តូរសណ្ឋាន ហើយ ដែលផ្តល់លក្ខណៈល្បីបែបណាដល់សូរ ហៅថាលំញាប់បំប៉ន ។ សូរនីមួយៗនៃភាសា (សូរល្បាយនីមួយៗ) មានលំញាប់បំប៉នពីរ :

- សូរមួយបណ្តាលមកពីគ្រសនី[១១] [គ្រៈសៈនី] , (le pharynx) ដែលមានមុខងារជាគម្ពុរករ ។
- សូរមួយទៀតបណ្តាលមកពីមាត់ដែលមានមុខងារជាគម្ពុរករ ។

តាមលោក ដឺឡាត្រ (Delattre) លំញាប់បំប៉នទាំងពីរនៃស្រៈបារាំងមានដូចតទៅ :

---

[១១] ពាក្យ "គ្រសនី" (pharynx) ក៏ជាពាក្យខ្ចីពីវចនានុក្រមបារាំង-ខ្មែរ របស់លោក គិប យក់ & ថាវ៉ គន្ធ ដែរ ។ គ្រសនីជា "ទន្លេចតុមុខ" នៅខាងក្រោយផ្លូវមាត់ និង ផ្លូវច្រមុះ ចូលទៅរកបំពង់.ក និង បំពង់សួត (សូមមើល រូបតាងទី៦, ទី៧, ទី៨ និង ទី៩) ។

| F1 | F2 | F1 | F2 | F1 | F2 |
|---|---|---|---|---|---|
| [ i ] = 240 | 2500 | [y] = 240 | 1850 | [u] = 240 | 750 |
| [e] = 350 | 2200 | [ø] = 350 | 1600 | [o] = 350 | 865 |
| [ɛ] = 510 | 1950 | [œ] = 510 | 1400 | [ɔ] = 510 | 1000 |
| [a] = 725 | 1350 | | | [ɑ] = 650 | 1200 |

អក្សរកាត់ F= Formant (សូរបំប៉ន)

តារាងទី១

ដោយផ្អែកលើលំញាប់បំប៉ន គេអាចចាត់ថ្នាក់ស្រៈបារាំងដូចតទៅ :

(១) - បន្លែករវាងសូរធូរនិងសូរណែន :

- [i] ជាសូរធូរ ពីព្រោះ F1 ( = 240 Hz) ខុសឆ្ងាយពី F2 ( = 2.500 Hz)

- [a] ជាសូរណែន ពីព្រោះ F1 ( = 725 Hz) ខុសតិចពី F2 ( = 1.350 Hz)

(២) - បន្លែករវាងសូរគ្រលួច (តូច/ឆ្មារ) និងសូរគ្រលរ (ធំ) :

[i] គ្រលួចជាង [u] ពីព្រោះស្រៈទាំងពីរមាន F1 ដូចគ្នា តែ

[i] មាន F2 (2.500 Hz) ខ្ពស់ជាង F2 របស់ [u] (750 Hz)...

------------

# សូរវិទ្យាបន្លឺ

**(Phonétique articulatoire)**

**១ - <u>ប្រដាប់បន្លឺសំឡេង : ទ្រង់ទ្រាយ & ដំណើរការ</u> (<u>description et fonctionnement de l'appareil phonatoire</u>).**

មុននឹងពណ៌នាពីប្រដាប់បន្លឺសំឡេងរបស់មនុស្ស គប្បីយើងពិនិត្យប្រដាប់នេះ តាមគំនូរតាងសិន ដូចខាងក្រោមនេះ :

ប្រដាប់បន្លឺសំឡេងរបស់មនុស្សមានពាចំណែក ÷

(១) - ប្រដាប់ដកដង្ហើមដែលផ្តល់ចរន្តខ្យល់ ដែលមានមុខងារជាកម្លាំងក្នុងការផលិតសូរ ;

(២) - ដើមបំពង់សួតដែលជាវត្ថុលំញ័រដែលបង្កើតសូរក្រោមឥទ្ធិពលនៃខ្យល់ដែលចេញពីសួត ;

(៣) - គម្ពុរករ(វត្ថុមានគម្ពុរ) មួយចំនួន ដែលមានមុខងារជាតម្រង ដែលអាចកែសំឡេងតាមចំណង់ គឺមាន ÷

- បបូរមាត់ ;
- គុហាផ្លូវច្រមុះ ;
- គុហាផ្លូវមាត់និងគ្រឿងឧបសម្ព័ន្ធជាប់ជាមួយដែលមានអណ្តាត, ធ្មេញ, ក្រអូមមាត់, ដើម.ក ។

ដើម្បីពិនិត្យចលនានិងដំណាក់នៃសរីរាង្គរបស់ប្រដាប់បន្លឺក្នុងការបង្កើតសូរ គេប្រើឧបករណ៍ផ្សេងៗ[១២] មាន ÷

- វិទ្យុលេខន: (radiographie) សម្រាប់ឆ្លុះមើលនិងវាស់រង្វះមាត់ ;
- លំញ័រលេខនី (kymographe) សម្រាប់ស្ទង់លំញ័រខ្សែសំឡេង និង របិត់ (< រត់)ខ្យល់ដែលចេញពីសួត ;
- ក្រអូមលេខនី (palatographe) សម្រាប់អោយដឹងថា តើអណ្តាតបានប៉ះនឹងក្រអូមឬទេ ហើយ បើប៉ះ តើប៉ះបែបណា -ល- ។

---

[១២] : ឧបករណ៍ទាំងប៉ុន្មាននេះជាឧបករណ៍ចាស់ ដែលគេប្រើនៅពេលមុនមានឧបករណ៍អេឡិកត្រូនិក ប៉ុន្តែ សូរវិទ្យាបន្លឺ ដែលខ្ញុំរៀបរៀងក្នុងសិក្សាកថានេះ ស៊ីគ្នានឹងឧបករណ៍ចាស់ទាំងនេះ (នៅអនាគត គប្បីអ្នកជំនាញបង្កើតសូរវិទ្យាថ្មីមួយអោយស៊ីគ្នានឹងទិន្នន័យបានពីឧបករណ៍ទំនើបផងទៅ) ។

# ប្រដាប់ដកដង្ហើម ប្រើជាប្រដាប់បន្លឺសូរ

( គំនូរប្រៀបធៀប ការដកដង្ហើម ការបរិភោគ និង ការបន្លឺសូរ)




រូបភាពទី៦ : ការដកដង្ហើម



រូបភាពទី៧ : ការបរិភោគ



រូបភាពទី៨ : ការបន្លឺសូរនាសិកជះ



រូបភាពទី៩ : ការបន្លឺសូរមុខជះ

ដូច្នេះហើយចំពោះសូរនីមួយៗ ដែលបន្លឺចេញមក គេអាច ៖

(១) - ដឹងថា តើមានលំញ័រខ្សែសំឡេង ឬ គ្មាន ;

(២) - ដឹងថា តើខ្យល់ដែលមកពីសួត វាចេញតែតាមមាត់ ឬ តាមមាត់ផង តាមច្រមុះផង ;

(៣) - ដឹងកម្រិតរង្វះមាត់ ;

(៤) - ដឹងទីបន្លឺ កន្លែងជំនួបរវាងសរីរាង្គខាងក្រោមនិងសរីរាង្គខាងលើនៃគុហាផ្លូវមាត់ ដើម្បីបណ្ដាលអោយសូរ ដែលបានកើតឡើង មានលក្ខណៈពិសេសជាស្ថាពរ ។

កំណត់សម្គាល់ : ឥឡូវនេះ គេប្រើកូនប្រអប់អេឡិកត្រូនិក ដូចជា CECIL ជាដើម ដែលគេភ្ជាប់ជាមួយកុំព្យូទ័រ ដើម្បីយកព័ត៌មានស្ទើរតែទាំងអស់ខាងលើនេះ ។

## ២ - **ចំណាត់ថ្នាក់រវាងសូរ** :

### ២.១ - **ចំណាត់ថ្នាក់រវាងសូរដែលកើតឡើងដោយបន្លឺទោល**
(classification des sons à articulations simples).

សូរបន្លឺទោលជាសូរដែលមានរង្វះខ្យល់តែមួយនិងទីបន្លឺតែមួយ ផ្ទុយពីសូរបន្លឺល្បាយដែលមានរង្វះខ្យល់ពីរនិងទីបន្លឺមួយ ឬ រង្វះខ្យល់មួយនិងទីបន្លឺពីរ ។

### ២.១.១ - **ចំណាត់ថ្នាក់ផ្អែកលើផ្លូវដែលខ្យល់ចេញពីសួតមកក្រៅ** (classification fondée sur les voies de sortie de l'air).

រនាំងក្រអូម (le voile du palais) អាចបិទផ្លូវច្រមុះ ឬ បើកចំហ (សូមមើលរូបតាងលេខ៨ និងលេខ៩) :

- កាលណាវាបិទផ្លូវច្រមុះ ខ្យល់ចេញតែតាមមាត់ ហើយ សូរដែលកើតឡើងជាសូរមាត់/មុខជៈ (consonnes orales) ដូច [p] , [b] , [f] , [v] , [s] ជាដើម ។
- កាលណាវាបើកចំហ ខ្យល់ចេញតាមមាត់ផងនិងតាមច្រមុះផង ហើយ សូរដែលកើតឡើងជាសូរច្រមុះ/នាសិកជៈ (consonnes nasales) ដូច [m] , [n] , [ɲ], [ŋ],...

កាលណាយើងឈឺផ្ដាសាយខ្លាំង ច្រមុះយើងត្រូវស្ទែស្ទបិទជិត ហើយ ខ្យល់មិនអាចចេញតាម ច្រមុះបានទេ ។ កាលណា យើងចង់បន្លឺសូរនាសិកជៈណាមួយ ( [m] ឬ [n] ឬ [ɲ] ឬ [ŋ] ) យើងមិនអាចសម្រេចបំណងយើងបានទេ : បើយើងចង់ថា "je suis enrhu<u>m</u>é" គេឮយើងថា "je suis enrhu<u>b</u>é" ទៅវិញ[១៣] ។

**២.១.២ - <u>ចំណាត់ថ្នាក់ផ្អែកលើមុខងារខ្សែសំឡេង</u>** <u>(classification fondée sur le rôle des cordes vocales)</u>.

កាលណាសាច់ដុំខ្សែសំឡេងខំប្រឹង ខ្សែសំឡេងក៏ត្រូវតឹងរឹងឡើង (ហាក់បីដូចខ្សែចាប៉ី) ហើយ កាលណាខ្យល់មកពីសួតបានរត់កាត់ វាក៏មានលំញ័រឡើង ។ ក្នុងស្ថានភាពផ្ទុយពីនេះ ខ្សែសំឡេងឥតមានលំញ័រទេ កាលណាខ្យល់រត់កាត់ ។

មុនពេលមានឧបករណ៍អេឡិកត្រូនិក គេប្រើលំញ័រលេខនី (kymographe) ដើម្បីស្ទង់មើលលំញ័រនៃខ្សែសំឡេង ។ ឧបករណ៍នេះមានចំណែកសំខាន់ពីរ : ១- ស៊ីឡាំង (cylindre) រាងដូចកំប៉ុងទឹកដោះគោ ពាសដោយក្រដាសពណ៌ស ប្រឡាក់ដោយម្សៅធ្យូង បង្វិលដោយម៉ូទ័រអគ្គិសនី មានល្បឿនយឺតនិងនិយ័ត (régulier) & ២- ស្ទីឡេ (ចំពុះប៉ាកកា) គងលើក្រដាសនៃស៊ីឡាំង ភ្ជាប់ទៅខ្សែសម្រាប់នាំចលនាក្នុងការបន្លឺសូរ (សូមមើលរូបភាពខាងក្រោម) :

- កាលណាខ្សែសំឡេងមានលំញ័រ ស្ទីឡេក៏មានលំញ័រដែរ ហើយ វាគូសគំនូសជាខ្សែរលកលើក្រដាសរបស់ស៊ីឡាំង ដោយកោសម្សៅធ្យូងចេញអោយលេចគំនូសឡើង : ក្នុងករណីនេះ សូរដែលកើតឡើងជាព្យញ្ជនៈឃោសៈ/លឺ (sonore) ដូច : [b], [d], [g], ...

- កាលណាខ្សែសំឡេងគ្មានលំញ័រ ស្ទីឡេក៏គ្មានលំញ័រដែរ ហើយ វាគូសគំនូសជាបន្ទាត់ត្រង់លើក្រដាសរបស់ស៊ីឡាំង : ក្នុងករណីនេះ សូរដែលកើតឡើងជាព្យញ្ជនៈអឃោសៈ/ថ្លង់ (sourde) ដូច : [p], [t], [k], ...

[១៣] : ឧទាហរណ៍ខ្ចីពីលោក J. Marouzeau, Lexique de la terminologie linguistique, Editions Paul Geuthner, 1961.



<u>រូបភាពទី១</u>

រូបភាពខាងលើនេះបង្ហាញរបៀបប្រើប្រាស់នៃលំញ័រលេខនី ( kymographe)

ខ្ចីពី Bertil Malmberg, Les nouvelles tendances de la linguistique , PUF 1966 .




<u>រូបភាពទី២</u>

រូបភាពខាងលើជាគំនូសដែលលំញ័រលេខនីបង្ហាញលក្ខណៈលំញ័ររបស់សូរដែលមានក្នុងពាក្យ pappa, tiga & tala នៃភាសាស៊ុយអែត ។

<u>ការបញ្ជាក់</u> : ចំពោះពាក្យទីមួយ១ :

- គំនូសលើបំផុតជាលំញាប់សម្រាប់ប្រើជារង្វាស់រង្វាល់ ដែលមានលំញាប់ ១០០ ហឺត្ស ( គឺមាន១០០វដ្ត/វេលា ក្នុង១វិនាទី)

- គំនូសខាងក្រោមតាងលំញ័រនៃស្វរនីមួយៗ ( ជាគំនូសបានពីលំនាំចលនាចេញពីមាត់ ) ។

ការពន្យល់ : ខ្ញុំមិនពន្យល់ពីស្វរក្នុងពាក្យទាំងបីទេ ខ្ញុំពន្យល់តែពីស្វរក្នុងពាក្យ tiga ដែលខ្ញុំជឿជាក់ថា វានឹងអាចអោយយើងយល់ពីស្វរក្នុងពាក្យពីរទៀតមិនខាន : ក្នុងពាក្យ tiga នេះ គេសង្កេតឃើញ ( ពីឆ្វេងទៅស្តាំ) :

- បន្ទាត់ត្រង់មួយដែលតាងស្វរ [ t ] ;
- ខ្សែរលកដំបូងមួយ (ខ្សែរលកទី១) ដែលតាងស្វរ [ i ] ;
- បន្ទាត់កោងមួយ (ចន្លោះគំនូសស្វរ [ t ] និង គំនូសស្វរ [ i ]) ដែលតាងបន្ទុះនៃស្វរ [ t ] ;
- ខ្សែកោងចុះក្រោមមួយដែលតាងស្វរ [ g ] ( ភាសាស៊ុយអែតជាភាសានៅក្នុងក្រុមជាមួយភាសាអាល្លឺម៉ង់ ដែលក្នុងនោះ ព្យញ្ជនៈឃោសៈផ្ទុះមិនពេញជាឃោសៈដូចព្យញ្ជនៈឃោសៈផ្ទុះនៃភាសាឯទៀតទេ មានភាសាបារាំង ជាដើម ដូច្នេះហើយ គំនូសតាងក៏មិនសូវមានភាពជាខ្សែរលកទេដែរ ( សូមប្រៀបធៀបគំនូសតាងរបស់ [ g ] ជាមួយគំនូសតាងរបស់ [ l ] ដែលនៅពាក្យ tata) ;
- ខ្សែរលកមួយខាងចុងដែលតាងស្វរ [ a ] ។




រូបភាពទី៣[១៤]

បង្ហាញគំនូសដែលតាងស្វរនៃពាក្យ mamma នៃភាសាស៊ុយអែត :

- លំញោប់រង្វាស់រង្វាល់ឋិតនៅកណ្តាល ;

---

[១៤] : រូបភាពទី៣ ( ដូចរូបភាពទី១ & ទី២ដែរ) ជារូបភាពខ្ចីពីសៀវភៅរបស់សូរវិទូ ដែលបានប្រាប់ឈ្មោះរួចហើយ : op.cit , Bertil Malmberg, Les nouvelles tendances de la linguistique, pp. 159 & 161 .

- គំនូសតាងសូរមុខជៈ ( ផ្តល់ដោយខ្សែនាំចលនាចេញពីមាត់) នៅខាងលើបង្អស់ ;
- គំនូសតាងសូរនាសិកជៈ ( ផ្តល់ដោយខ្សែនាំចលនាចេញពីច្រមុះ) នៅក្រោមបង្អស់ ។

**២.១.៣ - <u>ចំណាត់ថ្នាក់ផ្អែកលើវង្វះខ្យល់</u>** <u>(classification fondée sur l'aperture)</u>.

**២.១.៣.១ - <u>ឈ្មោះសូរតាមវង្វះខ្យល់</u>** <u>(dénomination des sons d'après leur degré d'aperture)</u>.

ក្នុងការបង្កើតសូរ មាត់មានវង្វះសូន្យ ឬ បើកវង្វះតូចឬធំ ÷

(១) - វង្វះសូន្យ/ស្ទើរសូន្យ : របិត់ខ្យល់ ដែលចេញពីសួត ត្រូវប៉ះខ្លាំងនឹងគ្រឿងប្រដាប់បន្លឺសំឡេង បណ្តាលអោយមានបន្ទុះ ដូច្នេះ សូរដែលកើតឡើងជា <u>សូរបន្ទុះ</u> (១៥) គឺសូរ [p], [b], [t], [d], [k], [g], [m], [n], [ɲ], [ŋ].

(២) - វង្វះ១ : របិត់ខ្យល់ត្រដុសនឹងផ្ទៃនៃគុហាផ្លូវមាត់, អណ្តាត, ធ្មេញ ហើយបង្កើតសូរត្រដុស ដូច : [f] , [v] , [s] , [z], ...

(៣) - វង្វះ២ : របិត់ខ្យល់ស្ទើរតែមិនត្រដុសនឹងផ្ទៃគុហាផ្លូវមាត់, អណ្តាត, ធ្មេញ ឡើយ ហាក់បីដូចជាមានលំហូរ ហើយ បង្កើតសូរលំហូរ ដូច : [ l ], [ r ], etc...

(៤) - វង្វះ៣ : ចាប់ពីវង្វះនេះទៅ របិត់ខ្យល់ឈប់ប៉ះនឹងផ្ទៃគុហាផ្លូវមាត់ , អណ្តាត , ធ្មេញ ទៀតហើយ ហើយ ចំពោះវង្វះប៉ុននេះ គេបានសូរស្រៈកន្លះ ( ឬ ព្យញ្ជនៈកន្លះ) គឺ ÷ [j] , [ɥ] , [w].

(៥) - វង្វះ៤ : សូរដែលកើតឡើងគឺសូរស្រៈបិទ ÷ [i] , [y] , [u] , ...

(៦) - វង្វះ៥ : សូរដែលកើតឡើងគឺសូរស្រៈបិទកន្លះ ÷ [e], [ø], [ə], [o].

(៧) - វង្វះ៦ : សូរដែលកើតឡើងគឺសូរស្រៈបើកកន្លះ ÷ [ɛ], [œ], [ɔ].

(៨) - វង្វះ៧ : សូរដែលកើតឡើងគឺសូរស្រៈបើក ÷ [a], [ɑ].

---

១៥ : ខ្ញុំប្រើថា "សូរបន្ទុះ" អោយស្របនឹងភាពជាក់ស្តែង : កាលណាខ្យល់ប៉ះខ្លាំង ការប៉ះទង្គិចនោះបានបង្កើតជាបន្ទុះតូចមួយដែលសូរវិទូបារាំងហៅថា occlusion ( ឬ plosion ហៅតាមសូរវិទូ អង់គ្លេ-សាក្សុង) : សូរទាំងនោះមិនមែន ជាសូរស្ទះចេញមិនរួចនោះទេ ។

**២.១.៣.២ - បន្លែករវាងព្យញ្ជនៈ និង ស្រៈ** (différenciation entre les consonnes et les voyelles) .

បន្លែករវាងព្យញ្ជនៈនិងស្រៈនៅត្រង់ ÷

(១) - ក្នុងការបង្កើតព្យញ្ជនៈ គុហាផ្លូវមាត់, អណ្តាត & ធ្មេញ មានរង្វះសូន្យឬតូច ( តូចតិចឬតូចច្រើន តាមព្យញ្ជនៈ ) ខ្យល់ដែលចេញពីសួតត្រូវមានកម្លាំងខ្លាំង ដើម្បីគំហុកបើកផ្លូវ ហើយ ក៏ចេញអស់ភ្លាមទៅ ។

(២) - ចំពោះការបង្កើតស្រៈវិញ គុហាផ្លូវមាត់, អណ្តាត, ធ្មេញ មានរង្វះធំគ្រប់គ្រាន់ ដើម្បីអោយខ្យល់ដែលចេញពីសួតមិនបាច់ប្រឹងបើកផ្លូវទេ ហើយ អាចចេញតាមសម្រួល និង មិនអស់ភ្លាមៗទេ ។

ពិសោធន៍ ÷

ការបន្លឺ —
- ព្យញ្ជនៈ ÷ ខ្យល់គំហុកបើកផ្លូវហើយចេញភ្លាមអស់ទាំងអស់ ដូច្នេះហើយ ការបន្លឺមិនអាចបន្តដំណើរយូរតទៅទៀតទេ ។
- ស្រៈ .... ÷ ខ្យល់ចេញតាមសម្រួល ដូច្នេះហើយ ការបន្លឺអាចបន្តដំណើរបានយូរ ។

រូបភាពខាងក្រោមនេះ ដែលបានពីសៀវភៅរបស់សូរវិទូដែលបានប្រាប់ឈ្មោះរួចហើយដែរ ជារូបថតដែលថតដោយវិទ្យុលេខនៈ (radiographie) :




រូបភាពទី៤

បង្ហាញរង្វះមាត់ក្នុងការបន្លឺស្រៈ [e] អេស្ប៉ាញ៉ុល




រូបភាពទី៥

បង្ហាញរង្វះមាត់ក្នុងការបន្លឺស្រៈ [o] អេស្ប៉ាញ៉ុល




រូបភាពទី៦

បង្ហាញរង្វះមាត់ក្នុងការបន្លឺស្រៈ [a] អេស្ប៉ាញ៉ុល

**២.១.៤ - ចំណាត់ថ្នាក់នៃសូរ ផ្អែកលើទីបន្លឺ** (classification fondée sur le point d'articulation) .

- ទីបន្លឺជាកន្លែងដែលសរីរាង្គខាងលើនិងសរីរាង្គខាងក្រោមជួបគ្នា ដើម្បីច្នៃសូរអោយទៅជាសូរបែបណាៗ ។

- សរីរាង្គទាំងនោះឈ្មោះហៅថាគ្រឿងបន្លឺ ដែលមាន ÷
  - ខាងក្រោម : បបូរមាត់ក្រោម, ធ្មេញក្រោម, អណ្ដាត , កន្ទើត
  - ខាងលើ : បបូរមាត់លើ, ក្រអូម, ចុងរបាំងក្រអូម , ...

- ក្នុងជំនួប គឺសរីរាង្គខាងក្រោមដែលទៅរកសរីរាង្គខាងលើ ដូច្នេះហើយ ÷

- ទីបន្លឺឋិតនៅជាប់នឹងសរីរាង្គខាងលើ ( លើកលែងតែសូរបបូរមាត់ដែលបបូរមាត់លើនិងបបូរមាត់ក្រោម ជាទីបន្លឺតែម្តង) ។
- ដោយអាចមានចលនានិងដោយមានលទ្ធភាពដូររាង សរីរាង្គក្រោមជាគ្រឿងបន្លឺដើមហេតុនៃបែបបន្លឺ។

**២.១.៤.១ – <u>អំណោយឈ្មោះព្យញ្ជនៈ</u>** <u>(dénomination des consonnes)</u>.

| គ្រឿងបន្លឺក្រោម | គ្រឿងបន្លឺលើ | ព្យញ្ជនៈ |
|---|---|---|
| ១) - បបូរមាត់ក្រោម | បបូរមាត់លើ | សូរបបូរមាត់ [p, b, m, ...] |
| ២) - បបូរមាត់ក្រោម | ធ្មេញលើ | សូរបបូរ-ធ្មេញ [f, v, ...] |
| ៣) - ចុងអណ្តាត | ធ្មេញមុខ | សូរធ្មេញ [t, d, n, ...] |
| ៤) - ចុងអណ្តាត | ជើងធ្មេញ | សូរជើងធ្មេញ [ʈ, ɖ, ...] |
| ៥) - មុខខ្នងអណ្តាត | ដើមក្រអូម | សូរដើមក្រអូម [ʃ, ʒ] |
| ៦) -ខ្នងអណ្តាត | ផ្នែកកណ្តាលក្រអូម | សូរក្រអូម [c, ɟ, ...] |
| ៧) - ខ្នងអណ្តាត | របាំងក្រអូម | សូររនាំងក្រអូម [k, g,...] |
| ៨) -ផ្នែកក្រោយ នៃអណ្តាត | ចុងរបាំងក្រអូម | សូរចុងរបាំងក្រអូម)[ q, G, ...] |
| ៩) - ................... កន្លើត ....................... | | សូរកន្លើត [ ʔ, h, ...] |

<u>តារាងទី២</u>

**២.១.៤.២ – <u>អំណោយឈ្មោះស្រៈ</u>** <u>(dénomination des voyelles)</u>.

អំណោយឈ្មោះស្រៈមានដូចខាងក្រោម ÷

(១) - ស្រៈមុខ :

- សូរបបូរមាត់វែង : [ i, e, ɛ, a, æ ] .

- សូរបបូរមាត់វង់ : [ y, ø, œ] .

(២) - ស្រៈកណ្ដាល ( បបូរមាត់វែងទាំងអស់ ) : [ ɯ, ə] .

(៣) - ស្រៈក្រោយ :

- សូរបបូរមាត់វែង : [ ʌ, ɑ] .

- សូរបបូរមាត់វង់ : [ u, o, ɘ] .

កំណត់ចំណាំ ÷ នៅក្នុងភាសាខ្លះ គេមានស្រៈនាសិកជះ ដែលចារឹកដោយសញ្ញា : [ ã, ɑ̃, õ, ... ] ។
ស្រៈនាសិកជះនិងស្រៈមុខជះ ដែលជាគូនឹងគ្នាមានទីបន្លឺនិងរង្វះមាត់ដូចគ្នា :
( ឧ. [o] & [õ] មានទីបន្លឺនិងរង្វះមាត់ដូចគ្នា ) ។

**២.១.៥ - អំណោយឈ្មោះទាំងមូលដល់ព្យញ្ជនៈនិងស្រៈ នីមួយៗ** (dénomination complète de chaque consonne et voyelle).

នៅខាងលើ ខ្ញុំបានអោយឈ្មោះព្យញ្ជនៈនិងស្រៈតែមួយជ្រុងសិន ពីព្រោះជាឈ្មោះផ្អែកលើគ្រឿងបន្លឺសូរមួយម្ដងៗ ។ អំណោយឈ្មោះទាំងមូលត្រូវធ្វើឡើងដោយផ្អែកលើសញ្ញាតាបន្លឺទាំងបួនរួមគ្នា ។

ឧទាហរណ៍ :

- [ p ] = ព្យញ្ជនៈមុខជះ, សូរបន្ទុះ, សូរបបូរមាត់,
និង សូរអឃោសៈ ( ឬសូរថ្លង់ ) ។

- [ i ] = ស្រៈមុខជះ, ស្រៈបិទ, ស្រៈមុខ, ស្រៈបបូរមាត់វែង ។

សេចក្ដីបញ្ជាក់ ÷

ដើម្បីអោយឈ្មោះដល់សូរនីមួយៗ គេត្រូវគោរពលំដាប់លំដោយដូចនេះ ÷

( ១ ) - សម្រាប់ព្យញ្ជនៈ : ផ្លូវចេញរបស់ខ្យល់ ( ខ្យល់មាត់ ឬ ខ្យល់ច្រមុះ ),
រង្វះមាត់ , ទីបន្លឺ , មានឬគ្មានលំញ័ររបស់ខ្សែសំឡេង ។

(២) - <u>សម្រាប់ស្រៈ</u> : ផ្លូវចេញរបស់ខ្យល់, រង្វះមាត់, ទីបន្លឺ, ភាពវង់ឬវែងនៃ
បបូរមាត់ ។

**២.២ - <u>សូរកើតពីបន្លឺល្បាយ</u>** <u>(sons à articulations complexes)</u>.

សូរដែលកើតឡើងដោយបន្លឺល្បាយគឺជាសូរដែលមានរង្វះពីរឬទីបន្លឺពីរ ។

**២.២.១ - <u>ព្យញ្ជនៈ</u>** <u>(consonnes)</u>.

**២.២.១.១ - <u>ព្យញ្ជនៈដែលមានរង្វះខ្យល់មួយនិងទីបន្លឺពីរ</u>** :

- មានព្យញ្ជនៈបន្លឺល្បាយដែលមានរង្វះសូន្យ ហើយ ដែលប្រើទីបន្លឺពីរ គឺ
  បបូរមាត់និងរនាំងក្រអូម គឺព្យញ្ជនៈបបូរ-រនាំងក្រអូម (labio-vélaires)
  ដូចជា : k͡p, g͡b, ŋ͡b,... ។

- ដើម្បីបន្លឺព្យញ្ជនៈជំពូកនេះ គេត្រូវប្រើបបូរមាត់និងរនាំងក្រអូមស្មើរតែក្នុង
  ពេលដំណាលគ្នា ហើយ គេមិនអាចចាត់ទុកថាជាខ្យល់ "k + p ", "g + b ",...
  ទេ : បើយើងបន្លឺ "kp" , "gb",... ម្ចាស់ភាសាដែលមានសូរ k͡p , g͡b ,...
  គេមិនព្រមទទួលយកទេ ។

**២.២.១.២ - <u>ព្យញ្ជនៈដែលមានរង្វះខ្យល់ពីរនិងទីបន្លឺមួយ</u>** :

មានព្យញ្ជនៈដែលមានបន្លឺល្បាយចាប់ផ្ដើមដូចសូរបន្ទុះនិងបញ្ចប់ដូចសូរត្រដុស (ទីបន្លឺនៅដដែល)
គឺ :

- affriquées : [p͡f, b͡v, t͡s, d͡z,...].
- semi-nasales: [n͡z, ŋ͡v,...].

**២.២.២ - <u>ស្រៈ</u>** <u>(voyelles)</u>

- ស្រៈដែលមានបន្លឺល្បាយគឺ :

- ទោស្វរៈ (diphtongues) ដូចជា : [ai, ei, au, ...];
- ត្រីស្វរៈ (triphtongues) ដូចជា : [aiə, auə, ...].

## ៣ - សរុបនិទ្ទេស[១៦] អំពីស្វរ ដោយតារាង :

ក្រោយពីបានបង្ហាញចំណាត់ថ្នាក់វវាងសូរ ហូរហែសព្វគ្រប់មក គប្បីយើងធ្វើសរុបនិទ្ទេសមួយតាមរយៈតារាងខាងស្តាំ ដើម្បីអោយងាយដល់ការចងចាំ ពីព្រោះ គ្រាន់តែក្រឡេកមើលភ្លាម យើងអាចឃើញចំណាត់ថ្នាក់វវាងសូរ ព្រមទាំងសញ្ញាតាបន្លឺ (traits articulatoires) សព្វគ្រប់របស់វាផង ។ ម្យ៉ាងទៀត ឈ្មោះសញ្ញាតាបន្លឺសូរជាភាសាបារាំងជាជំហានទី១ឆ្ពោះទៅរកអំណានសៀវភៅជាភាសាបរទេស ។

ដូចខ្ញុំបានពោលក្នុងបុព្វកថារួចហើយ បើនិស្សិតខ្មែរមិនអានសៀវភៅភាសាវិទ្យាជាភាសាបរទេសទេ គាត់ប្រាកដជាមុជមិនជ្រៅទៅមិនឆ្ងាយឡើយ ពីព្រោះសៀវភៅភាសាវិទ្យាជាភាសាខ្មែរមិនទាន់មានគ្រប់គ្រាន់ទេ ( ស្ទើរតែគ្មានផង បើនិយាយអោយចំទៅ ពីព្រោះសៀវភៅដែលសិក្សាពីភាសាខ្មែរមិនមែនសុទ្ធតែជាសៀវភៅភាសាវិទ្យាទេ ) ។

តារាងនៅទំព័របន្ទាប់ ដែលមានសុទ្ធតែពាក្យបច្ចេកទេសបារាំង ជំរុញអ្នកអានអោយប្រឹងស្វែងរកសមមូលរវាងពាក្យខ្មែរនិងពាក្យបារាំង ដោយផ្អែកលើសញ្ញាតាបន្លឺសូរដែលខ្លួនបានប្រទះរួចមកហើយផង និង ដោយផ្អែកលើតារាងទី១៧/២០ដែលអោយឈ្មោះសញ្ញាតាបន្លឺសូរ/សទ្ទតាជាភាសាខ្មែរផង។ ខ្ញុំសុំបញ្ជាក់ថា ភាសាបារាំងនិងភាសាអង់គ្លេសប្រើពាក្យដូចគ្នាស្ទើរតែទាំងអស់ : ចេះពាក្យបច្ចេកទេសតាមភាសាបារាំងក៏ជាចំណេះនៃពាក្យបច្ចេកទេសក្នុងភាសាអង់គ្លេសផងដែរ ។ ការប្រឹងប្រែងស្វែងរកយល់លក្ខណៈសូរទាំងប៉ុន្មានដែលមានក្នុងតារាងនៅទំព័របន្ទាប់ ជាលំហាត់មួយដ៏ស័ក្តិសិទ្ធិ សម្រាប់សម្រួចប្រាជ្ញាស្មារតី ដើម្បីបន្តការសិក្សាភាសាវិទ្យា ។

នេះជាតារាងសរុបនិទ្ទេស ទាក់ទងនឹងឈ្មោះសញ្ញាតាបន្លឺសូរជាភាសាបារាំង ដែលយើងបានយល់អត្ថប្រយោជន៍សព្វគ្រប់មកហើយ :

---

[១៦] ពាក្យ "សរុបនិទ្ទេស" ត្រូវនឹងពាក្យបារាំង "récapitulatif" ក៏ជាពាក្យខ្ចីពីវចនានុក្រមបារាំង-ខ្មែរ របស់ លោក តិប យក់ & ថាវ គន្ធ ដែរ បណ្ណាគារ ប៊ុតនាង ភ្នំពេញ ឆ្នាំ ១៩៦២ ។

## TABLEAU DE PHONÉTIQUE GÉNÉRALE SIMPLIFIÉE

| Point d'articulation / Aperture | | bilabiales | labio-dentales | apico-inter-dentales | apico-dentales | apico-alvéolaires | prédorso-pré palatales | dorso-palatales | dorso-vélaires | dorso-uvulaires | glottales |
|---|---|---|---|---|---|---|---|---|---|---|---|
| Consonnes | plosives – orales | p / b | | | t / d | ʈ / ɖ | | c / ɟ | k / g | q / G | ʔ |
| | plosives – nasales | m | ɱ | | n | | | ɲ | ŋ | N | |
| | fricatives | ɸ / β | f / v | θ / ð | s / z | ʂ / ʐ | ʃ / ʒ | | x | | h / ɦ |
| | liquides | | | | | | l (lat.)<br>r (méd.) | | R | ʁ | |
| | semi-consonnes | | | | | | | j (-AR)<br>ɥ (+ AR) | w | | |

| Point d'articulation / Aperture | | Ant. -AR | Ant. +AR | cent. -AR | cent. +AR | post. -AR | post. +AR |
|---|---|---|---|---|---|---|---|
| Voyelles | fermées | i | y | ɯ | | | u |
| | mi-fermées | e | ø | ə | | | o |
| | mi-ouvertes | ɛ | œ | | | ʌ | ɔ |
| | ouvertes | a æ | | | | ɑ | |

ຕາຣາງທີ ໓

Notes :

1- + AR = arrondi ; - AR = non arrondi ; lat. = latérale ; méd. = mediane.

2- Les consonnes se trouvant au-dessus de la barre oblique sont des consonnes sourdes et celles se trouvant au-dessous sont des consonnes sonores .

3- Les consonnes figurant dans les cases sans barre oblique sont toutes des consonnes sonores .

4- Toutes les voyelles sont sonores; les voyelles orales et les voyelles nasales correspondantes ont le même point d'articulation et la même aperture (Ex. [ɛ̃] doit se trouver dans la même case que [ɛ] )

# សូរវិទ្យាបន្សំធាតុ

**(Phonétique combinatoire)**

ក្នុងការនិយាយស្តី សូរទាំងឡាយកម្រលេចដាច់ចេញតែឯងណាស់។ ព្យញ្ជនៈតែងតែរួមគ្នាជាមួយស្រៈ ដើម្បីបង្កើតជាព្យាង្គ។ ព្យាង្គរួមនិងព្យាង្គ ដើម្បីបង្កើតជាពាក្យ។ ក្នុងការផ្គុំធាតុនេះ សូរតែងតែជះឥទ្ធិពលអោយគ្នាទៅវិញទៅមក ដោយបែបមួយយ៉ាង១។

## ១- <u>កម្សោយសូរ (amuissement)</u>.

ដើម្បីសម្រួលអំណាន គេច្រើនតែទម្លាក់ចោលនូវសូរណាដែលពិបាកអាន :

<u>ឧទាហរណ៍</u> :

- notre livre : [nɔtrəlivrə > nɔt livr] ;
- quelque chose : [kɛlkəʃoz > kɛkʃoz] ;
- table d'honneur : [tablə dɔnœr > tab dɔnœr].

## ២- <u>ការសម្រុបសូរ (assimilation)</u>.

### ២.១- <u>និយមន័យ និង ឧទាហរណ៍ (définition et exemples)</u>.

សូរណាមួយត្រូវបានទទួលការសម្រុបសូរពីសូរផ្សេងណាមួយទៀត កាលណាសូរនោះបោះបង់សញ្ញា-តាបន្លឺរបស់វា (១ ឬ លើសពី១) ដើម្បីទទួលយកសញ្ញាតាបន្លឺរបស់សូរដែលនៅជាប់នឹងវាមកជំនួសសញ្ញាតាបន្លឺរបស់ខ្លួន។

### ២.១.១- <u>ការសម្រុបសូររវាងព្យញ្ជនៈនិងព្យញ្ជនៈ (assimilation de consonne à consonne)</u>.

<u>ឧទាហរណ៍</u> : Une heure et demie : [ ynœre<u>d</u>mi > ynœre<u>n</u>mi]

<u>ការពន្យល់</u> : ដើម្បីយល់ថាតើហេតុអ្វីក៏ [yn̥œre<u>d</u>ḿi] ប្រែទៅជា [yn̥œre<u>n</u>ḿi] យើងត្រូវផ្អែកលើសញ្ញាតាបន្លឺរបស់សូរ [d] , [m] និង [ n ] ដូចតទៅ :

[d]
- មុខជៈ
- រង្វះបន្ទុះ
- បន្លឺធ្មេញ
- ឃោសៈ (លឺ)

[m]
- នាសិកជៈ
- រង្វះបន្ទុះ
- បន្លឺបបូរមាត់
- ឃោសៈ (លឺ)

[ n ]
- នាសិកជៈ
- រង្វះបន្ទុះ
- បន្លឺធ្មេញ
- ឃោសៈ (លឺ)

<u>កំណត់សម្គាល់</u> : សញ្ញា " ´ " ជាសញ្ញាសម្គាល់សូរសង្កត់ចម្បង ។
សញ្ញា " ` " ជាសញ្ញាសម្គាល់សូរសង្កត់រាយរង ។

ក្នុងកន្សោម [yɔ̀œre<u>d</u>ḿi] ព្យញ្ជនៈ [d] (ដែលមានគំនូសពីក្រោម) បានបាត់បង់សញ្ញាតាបន្លឺរបស់ខ្លួនដែលជាសូរមុខជៈ ពីព្រោះវានៅជាប់នឹង [m] នៃព្យាង្គ [mi] ដែលទទួលការអានសង្កត់ខ្លាំង : [d] ក៏ទទួលយកសញ្ញាតាបន្លឺនាសិកជៈរបស់ [m] មកជំនួសសញ្ញាតាបន្លឺមុខជៈដែលជាសញ្ញាតារបស់ខ្លួន ។ សញ្ញាតា<u>បន្លឺថ្មីដែលកើតពីការសម្រុបសូរ គឺ : នាសិកជៈ រង្វះបន្ទុះ បន្លឺធ្មេញ ឃោសៈ</u> ។ បើយើងពិនិត្យមើលឡើងវិញនូវសញ្ញាតាបន្លឺរបស់ [d], [m], [n] យើងឃើញថា សញ្ញាតាបន្លឺថ្មី (នាសិកជៈ រង្វះបន្ទុះ បន្លឺធ្មេញ ឃោសៈ) ជាសញ្ញាតាបន្លឺរបស់ [n] ហើយ យើងយល់ថា [d] បានប្រែរូបទៅជា [n] បាត់ទៅហើយ ដូច្នេះហើយបានជាកន្សោម [yɔ̀œre<u>d</u>ḿi] ត្រូវក្លាយទៅជា [yɔ̀œre<u>n</u>ḿi] ។

**២.១.២ - <u>ការសម្រុបសូររវាងស្រៈនិងព្យញ្ជនៈ</u>** <u>(assimilation entre voyelle et consonne</u>).

<u>ឧទាហរណ៍</u> : transitif [trã<u>si</u>tif > trã<u>zi</u>tif] .

<u>ការពន្យល់</u> : ក្រោមឥទ្ធិពលនៃស្រៈ [ã] & ស្រៈ [i] ដែលជាសូរឃោសៈ (ពីព្រោះស្រៈទាំងអស់សុទ្ធតែជាសូរឃោសៈ) ព្យញ្ជនៈ[s] ដែលជាសូរ<u>អ</u>ឃោសៈបានក្លាយទៅជា [z] ដែលជាសូរឃោសៈ ដូចស្រៈ [ã] ឬ ស្រៈ [i] ដែរ ។

<u>ឧទាហរណ៍មួយទៀត</u> : ឡាតាំង caballum [kabalum] > **បារាំង** cheval [ʃəval] .

<u>ការពន្យល់</u> : ក្នុងភាសាឡាតាំង ព្យាង្គចុងក្រោយមិនទទួលអំណានខ្លាំងទេ ដូច្នេះហើយ ព្យាង្គចុងក្រោយ [um] នៃ [kabalum] ក៏បានជ្រុះបាត់ទៅក្នុងការវិវត្តពីឡាតាំងមកបារាំង ។ ក្រោយពី [um] បានជ្រុះបាត់ទៅ ព្យាង្គ [bal] ក្លាយទៅជាព្យាង្គចុងពាក្យវិញ ហើយព្យាង្គចុងពាក្យត្រូវទទួលអំណានខ្លាំងក្នុងភាសាបារាំង ។ រីឯ [k] ដែលនៅដើមពាក្យ

ហើយ ដែលជាព្យញ្ជនៈក្រោយ ក៏បានក្លាយទៅជា [c] ដែលជាព្យញ្ជនៈមុខ ដោយទទួលឥទ្ធិពលពី [b] ដែលជាព្យញ្ជនៈមុខ ពីព្រោះ [b] ជាសូរខ្លាំងនៅក្នុងព្យាង្គខ្លាំង ដូចមានការពន្យល់ខាងលើស្រាប់[១៧] ( [b] ទាញ [k] មកមុខអោយដល់កន្លែង [c] នេះឯង) ។ ព្យញ្ជនៈ[c]ក៏បានក្លាយទៅជា [ʃ] ក្រោមឥទ្ធិពលនៃស្រៈ[a]របស់ព្យាង្គ [bal] : [a] បានធ្វើអោយ [c] មានរង្វះធំ ហើយ ក្លាយទៅជា [ʃ]ដូច្នេះឯង) ។ ឯស្រៈ [a] របស់ព្យាង្គ [ca] ឬ [ʃa] ក៏បានក្លាយទៅជា [ə] ដោយមានបាតុភូតបន្លែកសូរ ។

## ២.១.៣- ការសម្របសូររវាងស្រៈនិងស្រៈ (assimilation entre voyelles).

ឧទាហរណ៍ :

- extraordinaire [ɛkstraɔrdinɛr > ɛkstrɑɔrdinɛr > ɛkstrɑɑdinɛr] > [ɛkstrɑ:dinɛr] .
- inamicus > [ inami > ɛnami > ɛnəmi > ɛnmi] .

ការពន្យល់ :

ដើម្បីជាជំនួយក្នុងការពន្យល់/ការស្វែងយល់ យើងត្រូវការតារាងស្រៈបារាំង ដូចខាងក្រោមនេះ :




តារាងទី៤

- [ɛkstraɔrdinɛr] : ក្រោមឥទ្ធិពលនៃស្រៈក្រោយ[ɔ] ស្រៈមុខ [a] ក្លាយទៅជាស្រៈក្រោយ [ɑ] ហើយ បន្ទាប់មក [a] ក៏ទាញ [ɔr] អោយចុះមកក្រោម និងអោយក្លាយទៅជា [ɑ] ។ នៅទីបញ្ចប់ គេបាន [ɑɑ > ɑ:] ដូចមានក្នុងពាក្យខាងស្ដាំបំផុត ។
- [inami] : ក្រោមឥទ្ធិពលនៃស្រៈបើក [a] ស្រៈបិទ [i] ( [i] ទីមួយ) ក៏បើកឡើង ហើយ ក្លាយទៅជាសូរ

[១៧] : ក្នុងការសម្របសូរ គឺ សូរខ្លាំងជាអ្នកនាំសូរខ្សោយអោយតាមខ្លួន ។

[ɛ] ។ បន្ទាប់មក ស្រៈ [a] ដែលនៅជាប់នឹងព្យាង្គ [mi] ដែលជាព្យាង្គខ្លាំង (ពីព្រោះ ក្នុងភាសាបារាំង គេអានសង្កត់លើព្យាង្គចុងពាក្យ) ក៏ត្រូវទទួលប្រពលភាពខ្សោយបំផុត ហើយ ក៏ក្លាយទៅជាសូរ [ə] រួចក៏រលាយបាត់ទៅ ។

**២.២ - <u>បែបផ្សេងៗនៃការសម្រួបសូរ</u>** <u>(divers types d'assimilation)</u>.

**២.២.១ - <u>ការសម្រួបសូរតាមសូរខាងមុខ</u>** <u>(assimilation progressive)</u>.

មានការសម្រួបសូរតាមសូរខាងមុខ កាលណាសូរខាងក្រោយបានទទួលការសម្រួបសូរតាមសូរខាងមុខ (ខាងឆ្វេង) ដែលនៅជាប់នឹងវា ឧ. : sanskrit [ag<u>n</u>i] > pali [ag<u>g</u>i] (= feu)[១៨] ។

**២.២.២ - <u>ការសម្រួបសូរតាមសូរខាងក្រោយ</u>** <u>(assimilation régressive)</u>.

មានការសម្រួបសូរតាមសូរខាងក្រោយ កាលណាសូរខាងមុខបានទទួលការសម្រួបសូរតាមសូរខាងក្រោយ (ខាងស្តាំ) ដែលជាប់នឹងវា ។ ឧ. : obtenir [ɔ<u>b</u>tənir] > [ɔptənir] ។

<u>សេចក្តីបញ្ជាក់</u> : សូមកុំច្រឡំអក្ខរាវិរុទ្ធ និង អំណាន : គេសរសេរ "obtenir" តែគេអាន [ɔptənir] ។

**២.២.៣ - <u>ការសម្រួបសូរទ្វេគុណ</u>** <u>(assimilation double)</u>.

មានការសម្រួបសូរទ្វេគុណ កាលណាសូរណាមួយបានទទួលការសម្រួបសូរពីសូរពីរដែលស្ថិតនៅជុំវិញវា ។

<u>ឧទាហរណ៍</u> : [ pãd̲ã > pãn̲ã ]

<u>ការពន្យល់</u> : [d]មានស្រៈនាសិកជៈនៅអមសងខាង ដូច្នេះហើយ ស្រៈនាសិកជៈទាំងពីរ
នេះបានធ្វើអោយ[d] នេះ ដែលជាមុខជៈ ក្លាយទៅជាព្យញ្ជនៈនាសិកជៈ
គឺក្លាយទៅជា [n] (ដូចនៅ ចំណុច ២.១.១.ដែរ) ។

<u>កំណត់សម្គាល់</u> : កាលណាការសម្រួបសូរកើតឡើងរវាងសូរដែលមិនជាប់គ្នា គេហៅថា "dilation" ដែលយើងអាចប្រែជាខ្មែរថា "ការសម្រួបសូរពីចម្ងាយ" ដូចមានឧទាហរណ៍ខាងក្រោមនេះ :
vieux frs "cercher" [kɛrʃe] > "chercher" [ʃɛrʃe ] , en frs moderne.

---

[១៨] : cf. Maurice Grammont, Traité de phonétique, Delagrave, 1960, p. 188.

<u>ការពន្យល់</u> : សូរ [k] ខាងដើមពាក្យ បានក្លាយទៅជាសូរ [ʃ] ក្រោមឥទ្ធិពលនៃសូរ [ʃ] ដែលនៅចុងពាក្យ ហើយ ដែលឥតនៅជាប់នឹងសូរ [k] នេះទេ ។

**៣- <u>បំប្លែកសូរ</u>** <u>(différenciation)</u>

គឺជាបាតុភូតផ្ទុយពីការសម្រួបសូរ ។ វាបង្កើតភាពខុសគ្នារវាងសូរពីរដែលនៅជាប់គ្នា ។ បាតុភូតធម្មជាតិបំប្លែកសូរកកើតឡើងឯកឯង ហើយ តាមធម្មតា វាបណ្តាលមកពីការពិបាកអាន ដូចពាក្យខ្មែរ "នំនាំ" (ពិបាកអាន) បានក្លាយទៅជា "លំនាំ" (ងាយអាន)[១៩] ប៉ុន្តែ ក្នុងករណីខ្លះ បាតុភូតបំប្លែកសូរបានកើតឡើង ដោយឥតមានការចាំបាច់ ដូចមានឧទាហរណ៍ខាងក្រោម :

- rei > roi [ rei > roi > roɛ > rwa ]

<u>ការសង្កេត</u> : តាមរយៈអក្ខរាវិរុទ្ធ យើងឃើញមានការវិវត្តតែពីរដំណាក់កាលទេ តែតាមរយៈសូរ ការវិវត្តមានដល់ទៅ៤ដំណាក់កាលឯណោះ (ដូចមានក្នុងការកត់ត្រាតាមសញ្ញាសូរវិធី (transcription phonétique) ខាងលើនេះស្រាប់) ។

<u>ការពន្យល់</u> : ស្រះ[e]និងស្រះ[i] (ក្នុងទ្វេស្វរៈ[ei] ) ជាស្រះពីរ ដែលមានទីបន្លឺដូចគ្នា ហើយ ដែលមានរង្វះជាប់គ្នា (រង្វះ៤និងរង្វះ៥) ។ ក្រោមឥទ្ធិពលនៃបាតុភូតបំប្លែកសូរស្រះ [e] បានឃ្លាតចេញឆ្ងាយពីស្រះ[i] (ឃ្លាតពីមុខទៅក្រោយ ហើយ ក៏ក្លាយទៅជាសូរ[o]ទៅ) ។ បន្ទាប់មក ស្រះ[o]បានទាញស្រះ[i] អោយមានរង្វះធំ អោយក្លាយទៅជាស្រះ [ɛ] ហើយ កន្សោម [oɛ] ក៏ក្លាយទៅជា [wa] នៅទីបញ្ចប់ ។

<u>កំណត់សម្គាល់</u> : ប្រសិនបើបំប្លែកសូរបានកើតឡើងរវាងសូរដែលមិនជាប់គ្នាទេ គេហៅថា "dissimilation" ដែលយើងអាចហៅជាខ្មែរថា" បំប្លែកសូរពីចម្ងាយ" ។
ឧ. Cou<u>r</u>oi<u>r</u> > cou<u>l</u>oi<u>r</u>[២០] .

**៤- <u>បំលាស់ទីតាំង (រវាងសូរ)</u>** <u>(interversion)</u>.

---

[១៩] : ពាក្យ "នំនាំ" ជាពាក្យកម្លាយចេញពីពាក្យ "នាំ" បូកនឹងអន្តែបទ /-អំម្ន-/ : នាំ + /-អំម្ន-/ > ន. អំម្ន. ាំ > នអំម្នាំ > នម្នាំ > នំនាំ (> លំនាំ) ។

[២០] : Op.cit. Maurice Grammont,Traité de phonétique, p. 296.

ជួនកាល សូរពីរ ដែលនៅជាប់គ្នា បានដូរកន្លែងគ្នា ។

<u>ឧទាហរណ៍</u> : ឡាតាំង pro > por ហើយ ក្នុងភាសាបារាំង គេបានសង្កេតឃើញថាមាន
ការវិវត្ត ដូចតទៅ : [ **po**r > **pu**r] ;

<u>កំណត់សម្គាល់</u> : រូប [pro] ជារូបចាស់របស់ [pur] : គេនៅប្រើ [pro] ជាបុព្វស័ព្ទ
ដូចក្នុង "sentiments pro-américains" ជាដើម ។

<u>ការពន្យល់</u> : [r] ដែលនៅខាងឆ្វេង [o] បែរជាទៅនៅខាងស្តាំវិញ
ពីព្រោះ ព្យញ្ជនៈទាំងពីរនេះបានដូរទីតាំងគ្នា ។

<u>កំណត់សម្គាល់</u> : បើតំណូរទីតាំងបានកើតឡើងរវាងសូរដែលមិនជាប់គ្នា គេហៅជាបារាំងថា
"métathèse" ហើយ យើងអាចហៅជាខ្មែរថា "ដំណូរទីតាំងពីចម្ងាយ"
ដូចមានឧទាហរណ៍ខាងក្រោមនេះ :

lat. pe<u>r</u>icu<u>l</u>um > pe<u>l</u>icu<u>r</u>um > pe<u>l</u>ic<u>r</u>um > pe<u>l</u>ic<u>r</u>o > pe<u>l</u>ig<u>r</u>o [២១]
( = danger , en espagnol)

## <u>សទ្ទតាវិទ្យា</u>
(Phonologie)

### ១- <u>បន្ថែករវាងសូរវិទ្យា & សទ្ទតាវិទ្យា តាមរយៈភាសាអឺរ៉ុប</u>

ខ្ញុំផ្អែកលើភាសាអឺរ៉ុបសិនដោយមូលហេតុពីរ : ១-ពីព្រោះខ្មែរសឹងសុទ្ធតែចេះភាសាណាមួយនោះទាំងអស់គ្នា និង ២-ពីព្រោះភាសាទាំងនោះប្រើអក្សរឡាតាំងដែលមានលក្ខណៈបែបសូរវិធី គឺសូរនិងអក្សរមានចំនួនប្រហាក់ប្រហែលគ្នា ( ខុសគ្នាបន្តិចបន្តួច ដូចជា សូរ[ʃ] ដែលគ្មានអក្សរសម្រាប់កត់ត្រាទេ ហើយគេត្រូវផ្គុំអក្សរដល់ទៅពីរសម្រាប់កត់ត្រា គឺ [ch] / [sh] ឬ ដូចអក្សរ "o" ដែលកត់ត្រាសូរ [o] ផង និងសូរ [ɔ] ផង -ល-) ។ ទោះយើងមិនផ្អែកលើអក្ខរាវិរុទ្ធក៏ដោយ ក៏ជនម្នាក់ៗនៅតែភ្ជាប់អារម្មណ៍ទៅអក្ខរាវិរុទ្ធដែរ ។ អក្ខរាវិរុទ្ធបែបសូរវិធីអាចនាំស្មារតីអោយចាប់សូរជាប់តាមលក្ខណៈពិតរបស់វា ដូចគេអាចយល់

---

២១ : Op. cit. Maurice Grammont, Traité de phonétique, p.353 .

ថា ក្នុង"ki" និង ក្នុង"key" មានសូរព្យញ្ជនៈ[k] ដូចគ្នា ហើយ អ្វីដែលប្លែកគ្នា គឺសូរស្រៈ[i] ក្នុង "ki" និង សូរព្យាង្គ " ey " ក្នុង"key" (ផ្ទុយពីអក្សរខ្មែរ ដែលត្រូវប្រើសញ្ញាព្យញ្ជនៈដល់ទៅពីរ គឺ "គ" និង "ក" ដើម្បីកត់សូរព្យញ្ជនៈតែមួយ) ។

បើយើងចេញពីអក្ខរាវិរុទ្ធបារាំង/អង់គ្លេស យើងមានស្មារតីមិនសូវវិលវល់ពេកទេ ពីព្រោះអក្ខរា-វិរុទ្ធទាំងពីរនេះមិនសូវឃ្លាតឆ្ងាយពីសូរខ្លាំងពេក ដោយសូរដែលបន្លឺឡើងមុនសូរឯទៀតត្រូវគេដាក់មុន នៅខាងឆ្វេង ហើយ សូរដែលបន្លឺឡើងជាបន្តបន្ទាប់ត្រូវគេដាក់ខាងស្តាំជាបន្តបន្ទាប់ដែរ : យើងអាចយល់ពីសូរ/ពីសទ្ទតារបស់ភាសាទាំងពីរនេះបានដោយងាយ ។

## **១.១- <u>បន្ថែករវាងសូរវិទ្យា និង សទ្ទតាវិទ្យា</u> :**

សូរវិទ្យាសិក្សាពីសូរ (ដូចយើងបានឃើញមកស្រាប់) រីឯសទ្ទតាវិទ្យា វាជាវិជ្ជាដែលសិក្សាពីសទ្ទតា ប៉ុន្តែ ការកំណត់ន័យអោយសទ្ទតាត្រូវការការប្រៀបធៀបជាមួយនឹងសូរ ដូច្នេះហើយ ការរៀបរាប់ពីសទ្ទតាវិទ្យាក៏ត្រូវការវត្តមាននៃសូរវិទ្យា ជាចាំបាច់ផងដែរ ។

### **១.១.១-<u>បញ្ញត្តិគន្លឹះ : បរិបទ</u> :**

ដើម្បីអោយមានការងាយយល់ពីបន្ថែករវាងសូរវិទ្យានិងសទ្ទតាវិទ្យា គប្បីយើងស្គាល់ជាដំបូងនូវន័យរបស់បញ្ញត្តិ "បរិបទ" (contexte/environnement) ។ សូរ/សទ្ទតាក្នុងពាក្យសម្តីតែងតែនៅក្នុងបរិបទណាមួយ ។ បរិបទនៃសូរណាមួយ/សទ្ទតាណាមួយ គឺសូរទាំងឡាយណា/សទ្ទតាទាំងឡាយណាដែលនៅឆ្វេងនិង/ឬនៅខាងស្តាំនៃសូរ/សទ្ទតា នោះ ។

<u>ឧទាហរណ៍</u> : ក្នុងពាក្យបារាំង "gare" [gar] :

- បរិបទរបស់ [g] គឺ [-ar] ( មាន [ar] នៅខាងស្តាំ) ;
- បរិបទរបស់ [r] គឺ [ga-] ( មាន [ga]នៅឆ្វេង) ;
- បរិបទរបស់ [a] គឺ [g- r] ( មាន [g]នៅឆ្វេង និង [r]នៅខាងស្តាំ) ។

<u>ការបញ្ជាក់</u> : គេប្រើ "និង/ឬ" ដើម្បីគ្របដណ្តប់ស្ថានភាពពីរប្លែកគ្នា :

- ជួនកាល បរិបទរបស់ឯកតាណាមួយ (សូរ/សទ្ទតា) គឺជាសូរ/សទ្ទតា ដែលនៅខាងឆ្វេង ដូចបរិបទរបស់ [r] ដែលជា [ga-] **ឬ** គឺជាសូរ/សទ្ទតាដែលនៅខាងស្តាំ ដូចបរិបទរបស់ [g] ដែលជា [-ar] (ក្នុងករណីទាំងពីរនេះគេប្រើធ្នាក់ "**ឬ**") ។
- ជួនកាល បរិបទរបស់ឯកតាណាមួយ (សូរ/សទ្ទតា) គឺជាសូរ/សទ្ទតា ដែលនៅខាងស្តាំផង **និង** ខាងឆ្វេងផង ដូចបរិបទរបស់ [a] ដែលជា [g--r] (ក្នុងករណីនេះគេប្រើធ្នាក់ "**និង**" ។

សទ្ទតាពីរប្លែកគ្នាជាសូរពីរប្លែកគ្នា ដែលអាចប្រើក្នុងបរិបទដូចគ្នា ដើម្បីបង្កើតពាក្យពីរម៉ាត់ប្លែកគ្នា : បើសូរណាមួយអាចប្រើក្នុងបរិបទណាមួយជាមួយគ្នានឹងសូរណាមួយទៀតដែរដើម្បីបង្កើតពាក្យពីរម៉ាត់ប្លែកគ្នានោះ សូរទាំងពីរនោះជាសទ្ទតាពីរប្លែកគ្នា។ ផ្ទុយទៅវិញ បើសូរណាមួយមិនអាចប្រើក្នុងបរិបទណាមួយជាមួយគ្នានឹងសូរណាមួយទៀតដើម្បីបង្កើតពាក្យពីរម៉ាត់ប្លែកគ្នាទេនោះ សូរទាំងពីរនោះជាកាឡាសូរចែកមុខគ្នារបស់សទ្ទតាណាតែមួយ ហើយ បើសូរពីរប្លែកគ្នាណាអាចប្រើជំនួសគ្នាបានក្នុងបរិបទដដែលណាមួយ ដោយឥតបង្កើតពាក្យពីរម៉ាត់ប្លែកគ្នាទាំងរូបទាំងន័យនោះ វាជាកាឡាសូរសេរី ។

### **១.១.២ - <u>លក្ខណៈវិនិច្ឆ័យ សម្គាល់ សទ្ទតា</u> :**

### **១.១.២.១ - <u>លក្ខណៈវិនិច្ឆ័យ ផ្អែកលើ គូអប្បបរិមាណ</u>** <u>(paires minimales)</u> **:**

**(១) - <u>សូរ និង សទ្ទតា</u> :**

សូរវិទ្យាសិក្សាពីទម្រង់និងពីសញ្ញាតាបន្លឺនៃសូរ យ៉ាងជាក់លាក់និងយ៉ាងល្អិតល្អន់។ ការសិក្សាយ៉ាងល្អិតល្អន់បែបនេះបាននាំសូរវិទូអោយសង្កេតឃើញថា ក្នុងភាសានីមួយៗ មានបាតុភូតកម្សោយសូរ, បាតុភូតសម្របសូរ , ... ថា ភាសាបារាំងមានស្រៈ "I" ដល់ទៅពីរប្រភេទ គឺស្រៈ [i:] វែង និង ស្រៈ [i] ខ្លី -ល- ។

ប៉ុន្តែ ក្នុងភាសាបារាំង គេមិនអាចប្រើស្រៈ[i:]វែងនិងស្រៈ[i]ខ្លី ក្នុងបរិបទដដែលណាមួយដើម្បីអោយបានជាពាក្យពីរប្លែកគ្នានោះទេ ផ្ទុយពីភាសាអង់គ្លេស ដែលមានជាអាទិ៍ ពាក្យ "ship" [ʃip] (= កប៉ាល់) ដែលប្រើស្រៈ[i]ខ្លី និង ពាក្យ "sheep" [ʃi:p] (= សត្វចៀម) ដែលប្រើស្រៈ[i:]វែង ។

ផ្ទុយពីសូរវិទ្យា សទ្ទតាវិទ្យាយកចិត្តទុកដាក់តែលើបន្ទែករវាងសូរដែលអាចបង្កើតពាក្យប្លែកគ្នាក្នុងបរិបទដដែលណាមួយ ដូចបរិបទ [ʃ-- p] ទាក់ទងនឹងពាក្យអង់គ្លេស [ʃip] និង [ʃi:p] ខាងលើនេះ

ជាដើម ។ ក្នុងភាសានេះ ស្រៈ[i]ខ្លីនិងស្រៈ[i:]វែងមិនមែនគ្រាន់តែជាសូរពីរផ្សេងគ្នានោះទេ តែគឺជាសទ្ទតាពីរផ្សេងគ្នាផងទៀត : សទ្ទតាពីរផ្សេងគ្នា គឺជាសូរពីរផ្សេងគ្នា ដែលអាចបណ្តាលអោយមានពាក្យពីរម៉ាត់ផ្សេងគ្នា ក្នុងបរិបទដដែលណាមួយ ។

<u>កំណត់សម្គាល់</u> ÷ ពាក្យ [ʃip] និង [ʃi:p] ដែលជាពាក្យពីរម៉ាត់ប្លែកគ្នា ដែលនៅក្នុងបរិបទដដែល ឬ ដូចគ្នា [ʃ--p] ហើយ ដែលប្លែកគ្នាតែក្នុងមួយកន្លែងនៅចន្លោះ [ʃ] & [p] (ក្នុងពាក្យមួយមាន [i ] ក្នុងពាក្យមួយទៀតមាន [ i: ] ។ ពាក្យ [ʃip] និង ពាក្យ[ʃi :p] នេះត្រូវគេអោយឈ្មោះថា "គូអប្បបរមា" (paire minimale) ។

ចំពោះភាសាបារាំង យើងក៏អាចយកបរិបទណាមួយ ដូច [--ol] ជាដើម ។ កាលណាយើង ដាក់ [s] ក្នុងបរិបទនេះ យើងបានពាក្យ [sol] ។ បើយើងដាក់ [b] យើងបានពាក្យ [bol] ។ ដូច្នេះហើយ [s] et [b] ជាសទ្ទតាពីរប្លែកគ្នា ដែលយើងកត់ត្រាតាមសទ្ទតាវិធី /s/ & /b/ ។

ដើម្បីជាសរុបនិទ្ទេស យើងអាចពោលថា សូរវិទ្យាយកចិត្តទុកដាក់នឹងបន្លែកគ្រប់បែបយ៉ាង រីឯសទ្ទតាវិទ្យាវិញ វាជាវិជ្ជាដែលយកចិត្តទុកដាក់តែលើបន្លែកណាដែលមានមុខងារបង្កើតពាក្យផ្សេងគ្នាក្នុងបរិបទដដែលណា/ទាំងឡាយណា របស់ភាសាណាមួយ ។ ដូច្នេះហើយ ÷

- ក្នុងភាសាបារាំង ស្រៈ "i:" (វែង) និង ស្រៈ "i" (ខ្លី) ជាសូរពីរនៃសទ្ទតា / i / តែមួយ ដែលគេត្រូវកត់ត្រាតាមសូរវិធី [ i:] & [ i ] .
- ក្នុងភាសាអង់គ្លេស ផ្ទុយទៅវិញ ស្រៈ "i:" (វែង) និង ស្រៈ "i" (ខ្លី) មិនមែនជាសូរពីរនៃសទ្ទតា / i /តែមួយទេ គឺជាសទ្ទតាពីរដាច់គ្នា ដែលគេត្រូវកត់ត្រាតាមសទ្ទតាវិធី / i: / និង / i / ។

**(២) - <u>សទ្ទតា និង កាឡាសូរ</u>** <u>(phonèmes et allophones)</u> .

សូរពីរនៃភាសាណាមួយ ថ្វីបើមានភាពខុសគ្នាតាមត្រចៀកយើង អាចគ្មានមុខងារសម្រាប់ធ្វើអោយមានពាក្យពីរម៉ាត់ប្លែកគ្នា សម្គាល់អ្វីប្លែកគ្នា ក្នុងបរិបទដដែលណាមួយទេ ។ ក្នុងករណីនេះ សូរទាំងពីរជាកាឡាសូរ<u>នៃសទ្ទតាតែមួយ</u> គឺមិនមែនសទ្ទតាពីរដាច់គ្នាទេ ។ កាឡាសូរពីរអាចជាកាឡាសូរចែកមុខងារគ្នា (មួយប្រើក្នុងព្យាង្គបើក មួយទៀតប្រើក្នុងព្យាង្គបិទ ជាដើម) ដែលគេសន្មតហៅថា "បដិកាឡាសូរ"

(allophones en distribution complémentaire)... ឬ ជាកាឡាសូរជំនួសគ្នាបានដោយសេរី (allophones en variation bibre) ។

យើងបានឃើញហើយថា សូរព្យញ្ជនៈឬសូរស្រៈនីមួយៗមានសញ្ញាតាបន្លឺបួន។ សូរពីរអាចមានសញ្ញាតាបន្លឺប្លែកគ្នាតែមួយ ( ឧ. [k] & [g] មានសញ្ញាតាបន្លឺបីដូចគ្នា ខុសគ្នាតែត្រង់ [k] ជាសូរអឃោសៈ ហើយ [g] ជាសូរឃោសៈ) ហើយ សូរសំខាន់ៗផៅសន្តាននឹងគ្នាបែបនេះអាចជាកាឡាសូររបស់សទ្ទតាណាមួយ ។ តាមលោក H.A. Gleason[២២] សូរផៅសន្តាន ដែលអាចជាកាឡាសូរ មាន :

១- សូរអឃោសៈ និង ឃោសៈ ផៅសន្តាន : [k , g] , [s , z] ;

២- សូរផ្ទុះ និង សូរត្រដុស ផៅសន្តាន : [k , x] ;

៣- សូរផ្ទុះបបូរមាត់ និង សូរបន្ទុះបបូរមាត់-ធ្មេញ : [b , b̦ ] ;

៤- សូរច្រមុះបបូរមាត់ និង សូរច្រមុះបបូរមាត់-ធ្មេញ : [m ,ɱ] ;

៥- សូរផ្ទុះ និង សូរត្រដុស : [p , f] ;

៦- សូរផ្ទុះធ្មេញ សូរផ្ទុះគល់ធ្មេញ និង សូរផ្ទុះក្រអូម : [t , ţ] , [ţ, t];

៧- សូរផ្ទុះធ្មេញ និង សូរលំហូររលោត : [d , l] ;

៨- សូរផ្ទុះ និង សូរត្រដុស : [t , ɵ] ;

៩- សូរត្រដុសគល់ធ្មេញ និង សូរត្រដុសក្រអូម : [s , ʃ] ;

១០- សូរផ្ទុះឬសូរត្រដុសក្រអូម/រនាំងក្រអូម : [k , k] , [k , ḳ] , [x , x̣] ;

១១- សូរផ្ទុះសិថិល & ធនិត ផៅសន្តាន : [p , ph] , [t , th] , [k , kh] ;

១២- រវាងសូរច្រមុះ ( លើកលែងតែ [m] ដោយឡែកពីគេ) : [n , ŋ] , [n , ɲ] ;

១៣- រវាងសូរលំហូរទាំងប៉ុន្មាន [r] / [l] : [r , R] , [R, ʁ] , [r, l] ;

១៤- រវាងសូរត្រដុសរនាំងក្រអូម និង សូរត្រដុសកន្ទើត : [h , x] ;

១៥- រវាងស្រៈផៅសន្តាន ដូច : [i , y] , [ɨ , i] , [æ , a] , [o, ɔ] , [e, ɛ] , etc ;

[២២] : H.A. Gleason, Introduction à la linguistique, traduit de l'anglais par Françoise Dubois-Charlier, Larousse 1969, p. 219 .

១៦- រវាងព្យញ្ជនៈកន្លះរនាំងក្រអូម និង សូរត្រដុសបបូរមាត់-ធ្មេញឃោសៈ : [w , v]

-ល- ។

**(២.១)- បដិកាឡាសូរ** (allophones en distribution complémentaire).

គួររំលឹកឡើងវិញថា ក្នុងពាក្យផ្សេងៗរបស់ភាសាណាមួយ សទ្ទតាណាមួយក៏អាចស្ថិតនៅក្នុងស្ថានភាពផ្សេងៗដែរ : ដើមពាក្យ, កណ្តាលពាក្យ, ចុងពាក្យ, ក្នុងព្យាង្គបិទ ឬ ក្នុងព្យាង្គបើក,... ។

សូរពីរនៃភាសាណាមួយត្រូវគេហៅថាជាបដិកាឡាសូរ កាលណាសូរទាំងពីរនោះមិនអាចប្រើក្នុងស្ថានភាពដូចគ្នា គឺមិនអាចនៅក្នុងបែបព្យាង្គដូចគ្នា (បើមួយនៅក្នុងព្យាង្គបិទ មួយទៀតត្រូវនៅក្នុងព្យាងបើក) ឬ មិនអាចមានទីតាំងដូចគ្នាក្នុងពាក្យ (បើមួយនៅដើមពាក្យ មួយទៀតត្រូវនៅកណ្តាលពាក្យ ឬ ចុងពាក្យ) ។

(១) ក្នុងភាសាបារាំងនៃតំបន់ខាងត្បូង សូរ [o] & សូរ [ɔ] ពីព្រោះ :

- [o] ប្រើប្រាស់តែក្នុងព្យាង្គបើក ដូចជាពាក្យ : pot [po] , chaud [ʃo] ហើយមិនត្រូវប្រើប្រាស់ទាល់តែសោះនៅក្នុងព្យាង្គបិទ ។
- [ɔ] ប្រើប្រាស់តែក្នុងព្យាង្គបិទ ដូចជាពាក្យ : chose [ʃɔz] , pauvre [pɔvr] ហើយមិនត្រូវប្រើប្រាស់ទាល់តែសោះនៅក្នុងព្យាង្គបើក ។

ដូច្នេះ [o] & [ɔ] ជាកាឡាសូរពីរដែលជាបដិកាឡាសូរ (2 sons en distribationnaire)[២៣] របស់សទ្ទតាតែមួយ គឺសទ្ទតា / o / ។

(២) ក្នុងភាសាបារាំងកណ្តាល(ស្តង់ដា) ស្រៈ [e] & ស្រៈ [ɛ] មានទំនោរទៅរកកាឡាសូរ (បដិកាឡាសូរ) ពីព្រោះ :

- [e] ប្រើប្រាស់ក្នុងព្យាង្គបើក ដូចជាពាក្យ : bêtise[២៤] [betiz], chantais / chantai [ʃãte][២៥] ,.

---

[២៣] : បដិកាឡាសូរគឺជាកាឡាសូរពីរដែលចែកមុខគ្នា/បង្គ្រប់គ្នាក្នុងព្យាង្គ, ក្នុងពាក្យ.... បើមួយប្រើក្នុងព្យាង្គបើក មួយទៀតប្រើក្នុងព្យាង្គបិទ បើមួយនៅដើមពាក្យ មួយទៀតនៅក្នុងកណ្តាលពាក្យឬចុងពាក្យជាដើម ។

[២៤] : ទោះមាន " ê " ដែលត្រូវគេអាន [ɛ] ក្នុងករណីឯទៀតៗក៏ដោយ គេត្រូវអាន [e] ក្នុងពាក្យ "bêtise" នេះ ពីព្រោះ" ê នៅក្នុងព្យាង្គបើក ។

- [ɛ] ប្រើប្រាស់ក្នុងព្យាង្គបិទ ដូចជាពាក្យ : bête [bɛt] , sec[២៦] [sɛk] ,...

<u>កំណត់ចំណាំ</u> : ប៉ុន្តែ ក្នុងករណី [e] & [ɛ] នេះ ការចែកមុខងារគ្នាបែបខាងលើនេះ មិនទាន់ជាទូទៅនៅឡើយទេ : វាគ្រាន់តែជាទំនោរសិនទេ ។

**(២.២) - <u>កាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី</u>** <u>(allophones en variation libre)</u>.

មានកាឡាសូរសេរី កាលណាសូរពីរ ( ឬលើសពីពីរ) អាចជំនួសគ្នាបានក្នុងពាក្យណាមួយ ដោយឥតបណ្តាលអោយមានការប្រែប្រួលក្នុងន័យរបស់ពាក្យនោះឡើយ ។

<u>ឧទាហរណ៍</u> : ដូចក្នុងពាក្យបារាំង "riz" ជាដើម ទោះគេបញ្ចេញសូរថា [ri] ឬ ថា [Ri][២៧] ពាក្យនេះ នៅតែមានន័យដដែល ។ ដូច្នេះហើយ [r] & [R] ជាកាឡាសូរពីររបស់សទ្ទតា /R/តែមួយ ។ សូរទាំងពីរនេះជាកាឡាសូរសេរីរបស់សទ្ទតា /R/ ។

<u>សេចក្តីបញ្ជាក់</u> : - គេយកសញ្ញា "R"សម្រាប់តាងសទ្ទតា / R/ ពីព្រោះ [R]ជាសូរ នៃតំបន់រដ្ឋធានីទីក្រុងប៉ារីស ដែលគេទុកជាចម្បង ។

**១.១.២.២ - <u>លក្ខណៈវិនិច្ឆ័យ ផ្អែកលើ គូ.ក្រោមអប្បបរមា</u>** <u>(paires sous-minimales)</u>

គេកំណត់ន័យអោយគូអប្បបរមាថា ជាពាក្យពីរដែលមានន័យពីរប្លែកគ្នា និង ដែលមានសូរប្លែកគ្នាតែត្រង់មួយកន្លែង ក្នុងបរិបទណាមួយ ដូចក្នុងបរិបទ [ --ar] សម្រាប់ពាក្យ [kar] & [gar] ក្នុងភាសាបារាំង ជាដើម ។

ចំពោះគូ.<u>ក្រោម</u>អប្បបរមាវិញ លោក H.A. Gleason[២៨] បានកំណត់ន័យថា ជាពាក្យពីរដែលមានន័យពីរប្លែកគ្នា ហើយ ដែលមានសូរប្លែកគ្នាត្រឹមពីរបីកន្លែង ក្នុងបរិបទណាមួយ ដូច :

---

២៥ : តាមក្បួនវេយ្យាករណ៍បារាំង គេត្រូវអានពាក្យ "chantais" ថា [ʃɑ̃tɛ] និងពាក្យ "chantai" ថា [ʃɑ̃te] ប៉ុន្តែឥឡូវនេះ បារាំងភាគច្រើនអានពាក្យទាំងពីរថា [ʃɑ̃te] ដូចគ្នា ពីព្រោះ "ais" & "ai " នៅក្នុងព្យាង្គបើក ដូចគ្នា ។

២៦ : ទោះគ្មាន " è " ឬ " ê " ក៏ដោយ ក៏គេអានសញ្ញាស្រៈ " e " ថា [ɛ] ដែរ ពីព្រោះ វានៅក្នុងព្យាង្គបិទ ។

២៧ : ខ្ញុំសុំរំលឹកថា ក្នុងសញ្ញាសូរវិធី សញ្ញា [r] និង [R]សម្គាល់សូរផ្សេងគ្នា ( សូមកុំច្រឡំសញ្ញាសូរវិធីនិងអក្សរ) ។

២៨ : Op.cit. , H.A. Gleason, Introduction a la linguistique, p. 231 .

- [treʒər] (<treasure) & [preʃər] (< pressure) ;
- [pleʒər] (<pleasure) & [træʃi] (< trashy) .

ក្នុងភាសាអង់គ្លេស គេប្រើសូរ [ʒ] & [ʃ] តិចតួចណាស់ ដែលជាហេតុអោយពិបាករកគូអប្ប-បរមា។ គូ.ក្រោមអប្បបរមាមិនអនុញ្ញាតអោយសន្និដ្ឋានផ្ទាល់ថា "ʒ" និង "ʃ" ជាសទ្ទតាទេ : គេត្រូវធ្វើសម្មតិកម្ម/ការឧបមាសិនថា វាជាកាឡាសូរ ប៉ុន្តែ ក្រោយពីបានពិនិត្យហើយ បើយើងឃើញថាសម្មតិកម្មនេះខុសស្រឡះ យើងអាចសន្និដ្ឋានដោយត្រឹមត្រូវថា ([ʒ] និង [ʃ]) ជាសទ្ទតាដាច់គ្នា។

- <u>សម្មតិកម្ម</u> - [ʒ] & [ʃ] ជាកាឡាសូរ ហើយ រវាងសូរទាំងពីរនេះ :

  - បើពាក្យណាមាន [t] គឺមាន [ʒ] ទៅជាមួយ
  - បើពាក្យណាមាន [p] គឺមាន [ʃ] ទៅជាមួយ

  } ដូចក្នុងគូទី១

- <u>ការពិនិត្យ</u> : ការឧបមានេះមិនស្របនឹងការពិតទេ ពីព្រោះ ក្នុងគូទី២ គេឃើញ [p] ប្រើជាមួយ [ʒ] និង [t] ជាមួយ [ʃ] ។

- <u>សេចក្តីសន្និដ្ឋាន</u> : [ʒ] & [ʃ] មិនមែនជាកាឡាសូរទេ តែជាសទ្ទតាដាច់គ្នា /ʒ/ & /ʃ/ ។

### ១.១.២.៣ - <u>លក្ខណៈវិនិច្ឆ័យ ផ្អែកលើ បំបិទ-បំបើកនៃព្យាង្គ និង ទីតាំងក្នុងព្យាង្គ (ព្យាង្គមុខ/ព្យាង្គកណ្តាល/ព្យាង្គក្រោយ)</u> :

<u>កំណត់សម្គាល់</u> : បច្ចេកទេសប្រើខាងក្រោមនេះ យកលំនាំតាមបច្ចេកទេសរបស់ លោក A.H. Gleason .

ដើម្បីអនុវត្តលក្ខណៈវិនិច្ឆ័យខាងលើនេះ ខ្ញុំសុំយកសំរាំងពាក្យក្នុងភាសាប្រឌិតមួយមកប្រើប្រាស់ ។ ភាសាប្រឌិត ពីព្រោះក្នុងករណីនេះ យើងមានលទ្ធភាពដាក់កម្រិតអោយមានសូរតិចតួច ដើម្បីងាយស្រួលក្នុងការវិភាគ ។ សំរាំងដែលយើងត្រូវការ មានដូចតទៅនេះ :

| | | |
|---|---|---|
| ១- [kadegɛ] = ដំឡូង | ៩- [kɑd] = ធ្យូង | ១៧- [ta] = កន្ទេល |
| ២- [ogedek] = ជើង | ១០- [tɑgɑ] = ម្ចាយ | ១៨- [tɛ] = ផ្លែ |
| ៣- [tedega] = ដី | ១១- [kado] = ឪពុក | ១៩- [to] = ផ្ទះ |
| ៤- [taga] .... = ម្តាយ | ១២- [tɑg] ... = ឆ្នាំ | ២០- [ak] = ដៃ |

៥- [tagɛ] .... = ឆ្មា　　១៣- [koda] = ឈើ　　២១- [et] = សក់
៦- [tego] ..... = ឆ្នាំង　　១៤- [kedɛ] = ទឹក　　២២- [ok] = ពោះ
៧- [todɛ] ... = ភ្លើង　　១៥- [kot] ... = ស្តេ　　២៣- [kɛ] = ក្បាល
៨- [kat] ...... = បាយ　　១៦- [tek] ... = ពោត　　២៤- [ɑk] = ដៃ

**១.១.២.៣.១- សិក្សាអំពីសូរ :**

(១) - សម្រង់សូរ :

យើងអាចស្រង់សូរទាំងប៉ុន្មាននៅក្នុងសំរាំងខាងលើ ដូចនេះ :




សេចក្តីបញ្ជាក់ : ខ្ញុំមិនស្រង់សូរដែលមានក្នុងពាក្យទាំងប៉ុន្មាននៃសំរាំងខាងលើនេះទេ ខ្ញុំគ្រាន់តែបង្ហាញរបៀបស្រង់តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ខ្ញុំសុំបញ្ជាក់ថា បើយើងប្រទះសូរដដែលៗក្នុងសម្រង់របស់យើង យើងមិនរក្សាទុកសូរដដែលៗទាំងអស់នោះទេ : យើងរក្សាទុកតែសូរប្លែកគ្នា ។

(២) - បញ្ជីសូរ ដែលស្រង់បាន មានដូចតទៅ :

(២.១) - សូរព្យញ្ជនៈប្លែកគ្នាដែលស្រង់បាន គឺ : [ d ] , [ g ] , [ k ] & [ t ] .

(២.២) - សូរស្រះប្លែកគ្នាដែលស្រង់បាន គឺ : [ a ] , [ ɑ ] , [ e ] , [ ɛ ] & [ o ] .

(៣) - តារាងសូរដែលស្រង់បាន :

(៣.១) - តារាងព្យញ្ជនៈ :

| ទីបន្លឺ / រង្វះខ្យល់ | សូរបបូរមាត់ | សូរចុងអណ្តាត-ធ្មេញ | សូរខ្នងអណ្តាត-ក្រអូម |
|---|---|---|---|
| សូរផ្ទុះ | | t / d | k / g |
| សូរត្រដុស | | | |

តារាងទី៥

(៣.២) - តារាងស្រៈ




តារាងទី៦

### ១.១.២.៣.២ - វិភាគរកសទ្ទតា :

កំណត់ចំណាំ : ជាដំបូង យើងត្រូវកត់ចំណាំថា [a] & [α ] ជាកាឡាសូរសេរី ពីព្រោះ សូរស្រៈទាំងពីរនេះមិនអាចបង្កើតពាក្យពីរដែលមានន័យពីរ ក្នុងបរិបទដដែលណាមួយទេ : taga = tαgα : ម្ដាយ / ak = αk : ដៃ ។

(១) - ពិនិត្យមើលក្នុងព្យាង្គបិទ/បើក (ក្រែងមានលក្ខណៈកាឡាសូរ) :

(១.១) - ពិនិត្យមើលព្យញ្ជនៈ :

| បំណិទ-បំណើក / ព្យញ្ជនៈ | ព្យាង្គបិទ | ព្យាង្គបើក |
|---|---|---|
| t ………….. | ………../……….. | …………// |
| d …………. | ………../……….. | …………/// |
| k …………. | ………../……….. | …………/// |
| g ..........…... | ………../……….. | ………..//// |

តារាងទី៧

កំណត់សម្គាល់ :

(១) - បន្ទាត់ទ្រេតនីមួយៗក្នុងតារាងខាងលើ (ក៏ដូចក្នុងតារាងបន្តបន្ទាប់ដែរ) សម្គាល់វត្តមានមួយនៃសូរមួយក្នុងពាក្យដែលមានក្នុងសំរាំងខាងលើ ឆ្លើយតបនឹងស្ថានភាពដែលគេ

កំពុងពិនិត្យ ( ព្យាង្គបិទ/បើក ដើមព្យាង្គ/កណ្តាលព្យាង្គ -ល- ) ។

(២) - កាលណាយើងស្រង់បានសូរព្យញ្ជនៈណាមួយ ក្នុងបែបព្យាង្គណាមួយហើយ យើងអាចឈប់ស្រង់សូរព្យញ្ជនៈនោះតទៅទៀត : បើយើងស្រង់សូរនេះបានម្តងក្នុងស្ថានភាពណាមួយ វាគ្រប់គ្រាន់ទៅហើយដើម្បីសន្និដ្ឋានថាជាកាឡាសូរឬជាសទ្ទតា ។

ការពិនិត្យពិចារណា : ព្យញ្ជនៈទាំងអស់អាចនៅក្នុងបែបព្យាង្គទាំងពីរ ដូច្នេះហើយ វាមិនអាចជាកាឡាសូរចែកមុខគ្នា ( ឬ បដិកាឡាសូរ) ទេ ។

(១.២) - ពិនិត្យមើលស្រៈ :

| ស្រៈ \ បំណិទ-បំណើក | ព្យាង្គបិទ | ព្យាង្គបើក |
|---|---|---|
| e ................................ | ................./................. | …………../ |
| ɛ……………....................... | ................................... | …………../ |
| o ................................ | ................./................. | …………../ |
| a ................................ | ................./................. | …………../ |
| ɑ ……………........................ | ................................... | ………….. |

តារាងទី៨

ការពិនិត្យពិចារណា : សូរស្រៈ [ɛ] មានប្រើតែក្នុងព្យាង្គបើក : វាទំនងជាកាឡាសូរជាមួយ [e] ។ ចំណែកសូរ [o] ដែលមានប្រើក្នុងព្យាង្គទាំងពីរបែប ជាសទ្ទតាស្រៈ /o/ ពេញលក្ខណៈ ។ គួរកត់ចំណាំឡើងវិញថា [a] & [ɑ] ជាកាឡាសូរសេរី ។

(២) - ពិនិត្យមើលតាមទីតាំងក្នុងពាក្យ : ព្យាង្គមុខ/ព្យាង្គកណ្តាល/ព្យាង្គក្រោយ ( ក្រែងមានលក្ខណៈកាឡាសូរ) :

(២.១) - ពិនិត្យមើលព្យញ្ជនៈ :

| ព្យញ្ជនៈ | ដើម | កណ្ដាល | ចុង |
|---|---|---|---|
| [ t ] ……… | ……/////////…… | ………………… | ……. /// |
| [d ] ……… | ………………… | ………////……. | ………. |
| [ k ] ……. | ……./////……. | ………………… | ………// |
| [ g ] ……. | ………………… | ……./////……. | ………. |

តារាងទី៩

ការពិនិត្យពិចារណា : យើងសង្កេតឃើញថា មានបដិកាឡាសូរពីរគូ :

- គូទី១ : [t] & [d] : [t] ស្ថិតនៅខាងដើមពាក្យ និង ចុងពាក្យ រីឯ [d] ស្ថិតនៅកណ្ដាលពាក្យ ។ សូរ [t] & សូរ [d] ជាកាឡាសូររបស់សទ្ទតា /t/ ។
- គូទី២ : [k] & [g] : [k] ស្ថិតនៅខាងដើមពាក្យ និង ចុងពាក្យ រីឯ [g] វិញស្ថិតនៅកណ្ដាលពាក្យ ។ សូរ [k] & សូរ [g] ជាកាឡាសូររបស់សទ្ទតា /k/ ។

(២.២) - ពិនិត្យមើលស្រៈ :

| ស្រៈ | ដើម | កណ្ដាល | ចុង |
|---|---|---|---|
| [ e ] ………. | …………/……….. | …………///……….. | …………… |
| [ɛ ]……….. | ………………….. | …………………….. | ……… ///// |
| [ a ] ………. | …………/……….. | ………..////………. | ……….. // |
| [ɑ ] ……….. | …………/………… | ………..//………… | ………… / |
| [ o ] ………. | ………..//……….. | …………///………. | ………../// |

តារាងទី១០

ការពិនិត្យពិចារណា : មានបដិកាឡាសូរមួយគូ : [e] & [ɛ] : សូរ [e] ប្រើនៅដើមព្យាង្គ និង នៅកណ្ដាលព្យាង្គ រីឯ សូរ [ɛ] ប្រើនៅចុងព្យាង្គ ។ សូរ [e] & សូរ [ɛ] ជាកាឡាសូររបស់សទ្ទតា /e/ ។ រីឯ សូរស្រៈ [o] ដែលមាន

វត្តមានគ្រប់ទីតាំង ជាសទ្ទតាស្រៈ /o/ គ្រប់លក្ខណៈ ។

សេចក្តីសន្និដ្ឋានលើការវិភាគរកសទ្ទតា :

តាមរយៈទីតាំងក្នុងពាក្យ យើងបានសង្កេតឃើញថា មានបាតុភូតកាឡាសូរចែកមុខងារគ្នា :

- រវាងសូរព្យញ្ជនៈ [ t ] និង សូរព្យញ្ជនៈ [d] ក្នុងផ្ទៃសទ្ទតាព្យញ្ជនៈ / t / តែមួយ
- រវាងសូរព្យញ្ជនៈ [k] និង សូរព្យញ្ជនៈ [g] ក្នុងផ្ទៃសទ្ទតាព្យញ្ជនៈ / k / តែមួយ
- រវាងសូរស្រៈ [e] និង សូរស្រៈ [ɛ] ក្នុងផ្ទៃសទ្ទតាស្រៈ / e / តែមួយ ។

**១.១.២.៣.៣ - តារាងសទ្ទតា :**

**(១) - តារាងសទ្ទតាព្យញ្ជនៈ :**

| ព្យញ្ជនៈមុខ | ព្យញ្ជនៈក្រោយ |
|---|---|
| / t / | / k / |

តារាងទី១១

**(២) - តារាងសទ្ទតាស្រៈ :**




តារាងទី១២

កំណត់សម្គាល់ : ការយល់ដឹងពីបន្លែករវាងសូរនិងសទ្ទតា ការពារយើងមិនអោយច្រឡំថា ភាសាខ្មែរ មានសទ្ទតា /f/ , /g/ , etc ... ពីព្រោះ សូរដែលចូលក្នុងភាសាខ្មែរតាមរយៈពាក្យ បរទេសមិនអាចក្លាយទៅជាសទ្ទតាបានដោយងាយទេ : វាគ្រាន់តែជាសូរ ហើយ ជាសូរមិនឋិតថេរ ផងទៀត ។

**១.១.២.៤ - លក្ខណៈវិនិច្ឆ័យ ផ្អែកលើ ទំនាក់ទំនង ព្យញ្ជនៈ-ស្រៈ & ស្រៈ-ព្យញ្ជនៈ :**

លក្ខណៈវិនិច្ឆ័យនេះជាលក្ខណៈវិនិច្ឆ័យបម្រុងការ ដែលគេកម្រប្រើណាស់ ពីព្រោះលក្ខណៈវិនិច្ឆ័យខាងលើមានចំនួនច្រើនគ្រប់គ្រាន់ណាស់ទៅហើយ ប៉ុន្តែ គប្បីយើងដឹងផងដែរថា គេនៅមានបច្ចេកទេសបម្រុងការសម្រាប់ករណីពិសេស។ ក្នុងភាសាខ្លះ :

- ព្យញ្ជនៈខ្លះប្រើតែជាមួយស្រៈខ្លះ ហើយ ដាក់តែពីមុខ/ដាក់តែពីក្រោយ ;
- ស្រៈខ្លះប្រើតែជាមួយព្យញ្ជនៈខ្លះ ហើយ ដាក់តែពីមុខ/ដាក់តែពីក្រោយ ។

(១) - <u>វិភាគរកសទ្ធតាព្យញ្ជនៈ</u> :

(១.១) - <u>ប្រើនៅមុខស្រៈ</u> :

| ព្យញ្ជនៈ | មុខ [e] | មុខ [ɛ] | មុខ [a] | មុខ [ɑ] | មុខ [o] |
|---|---|---|---|---|---|
| [ t ] .......... | ........//...... | ......../....... | .......///...... | .......//....... | ........// |
| [d ] .......... | ......../....... | ........//...... | ......../....... | ......../....... | …… / |
| [ k ] ......... | .......//....... | ......././...... | ......../....... | ......../....... | ……// |
| [ g ] …...... | ......../....... | ........//...... | ......../....... | ......../....... | …… / |

<u>តារាងទី១៣</u>

<u>ការពិនិត្យពិចារណា</u> : សូរព្យញ្ជនៈទាំងអស់អាចប្រើនៅមុខស្រៈទាំងអស់ :
គ្មានបាតុភូតកាឡាសូរចែកមុខគ្នាទេ។

(១.២) - <u>ប្រើនៅក្រោយស្រៈ</u> :

| ព្យញ្ជនៈ | ក្រោយ [e] | ក្រោយ [ɛ] | ក្រោយ [a] | ក្រោយ [ɑ] | ក្រោយ [o] |
|---|---|---|---|---|---|
| [ t ] .......... | ……/…… | …………... | ……/....... | ………...… | ......../ |
| [d ] .......... | ……/...... | …………... | ……/....... | ………...… | .......// |
| [ k ] ......... | ……/...... | ..........… | ……/...... | ……/....... | ......../ |
| [ g ] …...... | ……/...... | ..........… | ……//...... | ……//...... | ......../ |

<u>តារាងទី១៤</u>

<u>ការពិនិត្យពិចារណា</u> : សូរព្យញ្ជនៈទាំងអស់អាចប្រើនៅក្រោយស្រៈទាំងអស់ :
គ្មានបាតុភូតបដិកាឡាសូរទេ។

(២) - <u>វិភាគរកសទ្ទតាស្រះ</u> :

(២.១) - <u>ប្រើនៅក្រោយព្យញ្ជនៈ</u>

| ស្រះ | ក្រោយ [ t ] | ក្រោយ [d] | ក្រោយ [ k ] | ក្រោយ [ g ] |
|---|---|---|---|---|
| [ e ] …….. | ………//……… | ………../………. | ………../………. | ………./ |
| [ε ]……… | ………./………. | ………//………. | ………../……….. | ………// |
| [ a ] …….. | ………///……… | ………./……….. | ……….//………. | ……… / |
| [α ] ……… | ………//………. | ………../………. | ………./……….. | ……… / |
| [ o ] …….. | ……….//……… | ………../………. | ………//………. | ……… / |

<u>តារាងទី១៥</u>

<u>ការពិនិត្យពិចារណា</u> : សូរស្រះទាំងអស់ប្រើនៅក្រោយព្យញ្ជនៈទាំងអស់ : គ្មានបាតុភូតកាឡាសូរចែកមុខគ្នា (ឬ បដិកាឡាសូរ) ទេ។

(២.២) - <u>ប្រើនៅមុខព្យញ្ជនៈ</u> :

| ស្រះ | មុខ [ t ] | មុខ [d] | មុខ [ k ] | មុខ [ g ] |
|---|---|---|---|---|
| [ e ] ……. | ……….//……… | ………//………. | ………../………. | ………../ |
| [ε ] …….. | ………………… | ………………….. | ………………….. | ……….. |
| [ a ] ……. | ………./………. | ………./……….. | ………………….. | ……….// |
| [α ] …….. | ………………….. | ………………… | ………………….. | ………// |
| [ o ] ……. | ………./………. | ………//……… | …………/…….. | ………./ |

<u>តារាងទី១៦</u>

<u>ការពិនិត្យពិចារណា</u> : សូរស្រះទាំងអស់អាចប្រើនៅមុខព្យញ្ជនៈទាំងអស់ : គ្មានបាតុភូតកាឡាសូរចែកមុខគ្នាទេ។

**១.២ - <u>សទ្ទតា និង អតិសទ្ទតា</u>** <u>(phonèmes et archiphonèmes)</u>.

ផ្ទុយពីកាឡាសូរ ដែលជាសូរច្រើនរបស់សទ្ទតាតែមួយករណី "អតិសទ្ទតា" ជាករណីដែលសទ្ទតាច្រើន (ពីរ តាមធម្មតា) ត្រូវរលាយចូលគ្នា បន្ទាប់ពីសូរទាំងពីរ/ទាំងនោះបានបាត់សញ្ញាតាបន្លឺពិសេសរបស់ខ្លួន។

ឧទាហរណ៍ ÷

- ក្នុងភាសាអាល្លឺម៉ង់ ពាក្យ "rad" និង ពាក្យ "rat" ត្រូវគេអានដូចគ្នា ហើយ ភាសាវិទូតាងពាក្យទាំងពីរនេះតាមសញ្ញា /raT/ ។ ព្យញ្ជនៈ / d / និង ព្យញ្ជនៈ / t / មានសញ្ញាតាបន្លឺបីដូចគ្នា ហើយខុសគ្នាតែត្រង់លក្ខណៈទី៤ ( /d/ ជាសូរឃោសៈ , /t/ ជាសូរអឃោសៈ) ។ ក្នុងពាក្យ "rad" និង "rat" សញ្ញាតាបន្លឺ "ឃោសៈ" និង សញ្ញាតាបន្លឺ "អឃោសៈ" ត្រូវរលាយបាត់ទៅ ហើយ គេមិនដឹងថាសំឡេងខាងចុងជាខ្យល់ឃោសៈឬអឃោសៈ ឡើយ ។

- ក្នុងភាសាខ្មែរ ពាក្យ "កោដ្ឋ" និង ពាក្យ "កោត" ត្រូវគេអានដូចគ្នា ដូច្នេះហើយ តាមភាសាវិទ្យា គេក៏អាចតាងដោយសញ្ញា /kaoT/ ស្របតាមវិធីដែលគេបានប្រើសម្រាប់ភាសាអាល្លឺម៉ង់ នោះដែរ ។

- ប៉ុន្តែ លើសពីនេះទៅទៀត ព្យញ្ជនៈប្រកបក្នុងភាសាខ្មែរសុទ្ធតែជាអតិសទ្ទតា : ព្យញ្ជនៈទាំងនោះរក្សាទុកតែសញ្ញាតាបន្លឺបីទេ រីឯសញ្ញាតាបន្លឺទី៤ (ឃោសៈ/លឺ ~ អឃោសៈ/ថ្លង់) ត្រូវបាត់បង់ជាស្វ័យប្រវត្តិ ។ បាតុភូតនេះជាទម្លាប់អំណានរបស់ខ្មែរដែលមានសភាពប្រហាក់ប្រហែលនឹងទម្លាប់អំណានរបស់អាល្លឺម៉ង់ដែរ ។ ដោយព្យញ្ជនៈប្រកបក្នុងភាសាខ្មែរមានសញ្ញាតាបន្លឺតែបី ដូច្នេះ ព្យញ្ជនៈទាំងនោះមានឈ្មោះមិនសូវលឺទេ ហើយ ជនជាតិអឺរ៉ុបខ្លះ ដែលរៀនខ្មែរដំបូង ច្រើនមានការភាន់ច្រឡំ ហើយ ពោលពាក្យថា ខ្មែរមិនអានព្យញ្ជនៈនៅចុងពាក្យ (ព្យញ្ជនៈប្រកប) ទេ ។

**២- <u>បន្លែករវាងសូរនិងសទ្ទតា ក្នុងភាសាខ្មែរ</u>.**

សាធារណជនខ្មែរភាគច្រើននៅច្រឡំភាសាខ្មែរនិងអក្សរឬអក្ខរាវិរុទ្ធរបស់ភាសាខ្មែរនៅឡើយ : ដូច្នេះយើងត្រូវដឹងជាមុនថា ភាសាខ្មែរមានសូរប៉ុន្មាន សទ្ទតាប៉ុន្មាន មុននឹងប្រៀបធៀបជាមួយនឹងអក្សរខ្មែរ ដើម្បីអោយបន្លែកវាលេចធ្លោឡើង ។

## ២.១ - សូរ និង សទ្ទតា នៃភាសាខ្មែរ :

### ២.១.១ - សូរនៃភាសាខ្មែរ

ប៉ានីនី (Panini) បានប្រើតែត្រចៀកគាត់ប៉ុណ្ណោះ ដើម្បីស្រង់សូរដែលមានក្នុងភាសាសំស្ក្រឹត តាំងពីប៉ុន្មានរយឆ្នាំមុនគ្រិស្តសករាជមកម៉្លេះ។ ពិតមែនតែនៅសម័យយើងនេះ គេមានម៉ាស៊ីនផ្សេងៗ សម្រាប់ស្រង់សូរក៏ដោយ គេមិនអាចចៀសផុតពីការភាន់ច្រឡំបន្តិចបន្តួចឡើយ។ ចំពោះខ្ញុំវិញ ខ្ញុំនៅតែត្រូវការប្រើត្រចៀកតទៅទៀតសិន។ ជាដំបូង ខ្ញុំសុំពឹងផ្អែកលើសម្រង់សូរភាសាខ្មែរធ្វើដោយបណ្ឌិត ឃួន សុខម្ភូ ដែលបានប្រើម៉ាស៊ីននៃឡាបូសូរវិទ្យា របស់សកលវិទ្យាល័យហ៊ុមប៊ុល (Humboldt) នៅក្រុងប៊ែរឡាំង (Berlin)[២៩]។ បន្ទាប់មក ខ្ញុំពិនិត្យ ផ្ទៀងផ្ទាត់មើលថា តើសូរទាំងនោះស្របតាមពិតភាពឬទេ។

ដូចមានខាងលើស្រាប់ គ្រាន់តែដោយសារត្រចៀក យើងអាចស្តាប់យល់និងសង្កេតឃើញថា អក្សរដែលមានដល់ទៅពាពត្តូវបុព្វបុរសខ្មែរយកមកកត់ត្រាសូរព្យញ្ជនៈខ្មែរដែលមានតែ១៦សទ្ទតា (១៧ បើយើងរាប់បញ្ចូល /ʔ/ ផង)។

ចំពោះសូរព្យញ្ជនៈ ខ្ញុំយល់ស្របនឹងគាត់ស្ទើរតែទាំងអស់ (លើកលែងតែសូរ [v] ពីព្រោះអក្សរ "វ"របស់យើងមានសូរដូចសូរភាសាបារាំង/អង់គ្លេស ដែលគេតាងដោយសញ្ញា/អក្សរ [w] ទៅវិញទេ។ ចំពោះសូរស្រៈវិញ ខ្ញុំមិនយល់ស្របលើច្រើនចំណុច។ ដើម្បីអោយអស់លោកអ្នកមានលទ្ធភាពប្រៀបធៀបតាមសេចក្តីត្រូវការ ខ្ញុំសុំដាក់តារាងរបស់គាត់ក្នុងឧបសម្ព័ន្ធខាងចុងនៃសិក្សាកថានេះ។

#### ២.១.១.១ - តារាង(សូរ)ព្យញ្ជនៈ

---

[២៩]: Khuon Sokhamphu, le système phonétique de la langue khmère, thèse de doctorat préparée à l'université de Humboldt, Berlin, 1969.

| ទីបន្លឺ / រង្វះខ្យល់ | បន្លឺបបូរមាត់ | | | | បន្លឺបបូរមាត់&ធ្មេញ | | បន្លឺធ្មេញ | | | | បន្លឺក្រអូម | | | | បន្លឺរបាំងក្រអូម | | | | បន្លឺកន្លើត | | បន្លឺដើមក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សិថិល | | ធនិត | | សិថិល | | សិថិល | | ធនិត | | សិថិល | | ធនិត | | សិថិល | | ធនិត | | សិថិល | | សិថិល | |
| | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + |
| សូរឱស្ឋជៈ (រង្វះបន្ទះ...) | p | b | ph | | | | t | d | th | | c | | ch | | k | | k | | | | ʔ | |
| សូរនាសិកជៈ (រង្វះបន្ទះ...) | | m | | | | | | n | | | | ɲ | | | | ŋ | | | | | | |
| រង្វះត្រដុស | | | | | | | s | | | | | | | | | | | | h | | | |
| រលាស់ (រង្វះលំហូរ...) | | | | | | | | r | | | | | | | | | | | | | | |
| រលាត (រង្វះលំហូរ...) | | | | | | | | l | | | | | | | | | | | | | | |
| រង្វះព្យញ្ជនៈកន្លះ (ព្យញ្ជនៈកន្លះ) | | | | | | w | | | | | | j | | | | | | | | | | |

<u>តារាងទី១៧</u>

( យកតាមបណ្ឌិត ឃួន សុខម្ភ ដោយជំនួស [v] ដោយ [w] និង ដោយប្រើតារាងផ្សេងពីគាត់ :
ទីបន្លឺពីមុខទៅក្រោយ & រង្វះមាត់ពីលើទៅក្រោម )

<u>សន្មតសញ្ញា</u> : សញ្ញា (-) = សូរអឃោសៈ/ថ្លង់ ; សញ្ញា (+) = សូរឃោសៈ/លឺ

<u>ការពិនិត្យពិចារណា</u> :

(១) - សូរព្យញ្ជនៈខ្មែរដែលកត់ត្រាដោយអក្សរ "វ" មិនមែនជាសូរត្រដុសដូចសូរ [v] បារាំងទេ។ ក្នុងភាសានេះ [v] ជាគូជាមួយ [f] : បើយើងអាន [fi] យើងនឹងដឹងថា [f] ជាសូរត្រដុសពិតមែន រីឯ [v] ក៏មានសូរត្រដុសដូចគ្នានេះដែរ ប្លែកគ្នាតែត្រង់ [f] ជាសូរអឃោសៈ [v]ជាសូរឃោសៈ ។ ពីព្រោះសូរខ្មែរដែលកត់ត្រាដោយអក្សរ "វ" មិនមែនជាសូរត្រដុស គេក៏យក [w] មកកត់ត្រាតាមប្រព័ន្ធនៃអក្ខរក្រមសូរវិស័យអន្តរជាតិទៅ។

លោក Jacques Rongier បានអះអាងថា តាមលោក Jean-Michel Filippi ( សូរវិទូដែលបានបង្រៀនសូរវិទ្យានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមួយរយៈពេល) អក្សរ"វ"ខ្មែរត្រូវខ្មែរអានប្លែកពី[v]ឬ[w] នៃភាសាបារាំង/អង់គ្លេស គឺយើងអាន[β] ។ ដោយសូរវិទ្យាមិនមែនជាឯកទេសរបស់ខ្ញុំ ខ្ញុំមិនហ៊ានថាគេយល់ច្រឡំទេ ប៉ុន្តែ ខ្ញុំទាញអារម្មណ៍អ្នកសូរវិទ្យាលើបញ្ហាពីរ :

(១.១)- អក្សរ "ស" ខ្មែរ ប្រើក្នុងតួប្រកប ត្រូវបានសូរវិទូបរទេសជំនួសដោយសញ្ញា [h] នៃអក្ខរ-ក្រមសូរវិស័យអន្តរជាតិ, ឧ.ចាស់ [cah] ពីព្រោះគេយល់ថា អក្សរ "ស" ខ្មែរដែលជាតួប្រកប ត្រូវខ្មែរអានបន្ទើរ (តាមពិតអក្សរប្រកបក្នុងភាសាខ្មែរត្រូវខ្មែរអានបន្ទើរទាំងអស់ រហូតដល់គ្រូបារាំងម្នាក់ដែលចេះខ្មែរស្ទើរៗ ហើយ ដែលជាគ្រូបង្រៀនភាសាអង់គ្លេសដល់ពួកខ្ញុំ បានពោលថា: "ក្នុងភាសាអង់គ្លេស ផ្ទុយពីភាសាខ្មែរ គេអានអក្សរប្រកប, ឧ. ក្នុងពាក្យ "big" គេត្រូវអានព្យញ្ជនៈ "g" នៅខាងចុង") ។

(១.២) - សទ្ទតាវិទ្យាអាចមិនគោរពសុខុមភាព (subtilités) នៃសូរវិទ្យា, ឧ. សញ្ញា [p], [t],... ត្រូវបានគេបន្លឺសូរប្លែកគ្នាក្នុងភាសាអង់គ្លេសនិងក្នុងភាសាបារាំង ។

(២) - អ្នកខ្លះបាននិយាយថា ភាសាខ្មែរគ្មានសូរឃោសៈ/អឃោសៈទេ មានតែមូលភេទ អ/អ៊ ។ យោបល់បែបនេះជាការភាន់ច្រឡំ[៣០] ។ ពិតមែនតែវេយ្យាករណ៍ខ្មែរមួយចំនួនបានចម្លងតាមវេយ្យាករណ៍បាលី/សំស្ក្រឹត ដោយបានចាត់ទុកព្យញ្ជនៈអឃោសៈខ្មែរខ្លះថាជាព្យញ្ជនៈឃោសៈ ប៉ុន្តែ ភាសាខ្មែរក៏មានព្យញ្ជនៈឃោសៈ(លឺ) និង ព្យញ្ជនៈអឃោសៈ (ថ្លង់) ដូចភាសាឯទៀតៗ ក្នុងលោកដែរ :

- <u>ក្នុងចំណោមអក្សរសម្គាល់ព្យញ្ជនៈពួក.អ មាន</u> :
  - អក្សរកត់ត្រាព្យញ្ជនៈឃោសៈ ដូច ប [b], ដ [d] -ល- ។
  - អក្សរកត់ត្រាព្យញ្ជនៈអឃោសៈ ដូច ក [k], ត [t] -ល- ។
- <u>ក្នុងចំណោមអក្សរសម្គាល់ព្យញ្ជនៈពួក.អ៊ មាន</u> :
  - អក្សរកត់ត្រាព្យញ្ជនៈឃោសៈដូច ឌ [d], ម [m] -ល- ។
  - អក្សរកត់ត្រាព្យញ្ជនៈអឃោសៈ ដូច គ [k], ជ [c] -ល- ។

---

[៣០] ព្យញ្ជនៈពួក.អ/ពួក.អ៊ ជាលទ្ធផលនៃស្រៈនិស្ស័យឥតសូរផ្ទាល់ខ្លួន ដែលយកសូរតាមព្យញ្ជនៈ (ឧ.បើសញ្ញា "ា" មិនយកសូរតាមព្យញ្ជនៈ ហើយ ពិតជាមាន សូរ "អា [a] ដោយខ្លួនវាពិតប្រាកដមែន ទោះបីគេដាក់វាជាមួយ "គ" ក៏គេបាន"[ka] ឬ ជាមួយ "ក" ក៏គេបាន"[ka] ដែរ ហើយ បើគេចង់បាន [kẹa:] គេត្រូវមានសញ្ញាស្រៈមួយទៀតដែលមានសូរ "អ៊ា" ដោយខ្លួនឯង ។ ក្នុងករណីនេះ ទោះបីគេប្រើវាជាមួយ "ក" ក្តីឬជាមួយ "គ" ក្តី ក៏គេបាន [kẹa:] ដូចគ្នា : ដូច្នេះ មូលភេទ.ក/គ (ក៏ដូច ជាមូលភេទ.អ/អ៊ទាំងមូល) ឈប់មានន័យទៀតហើយ ។ ប៉ុន្តែ សូមសាធារណជនកុំច្រឡំអំណះអំណាងដើម្បីបង្ហាញ ថា ស្រៈនិស្ស័យគ្មានសូរផ្ទាល់ខ្លួន និង គោលបំណងអាក្រក់ចង់កែប្រែអក្សរខ្មែរ ។ ម្យ៉ាងទៀត គប្បីយល់ថា ព្យញ្ជនៈ ពួក.អ/ពួក.អ៊និងព្យញ្ជនៈឃោសៈ/អឃោសៈ ជាប្រព័ន្ធពីរដាច់គ្នា ។

### ២.១.១.២ - តារាងសូរស្រះ :

#### (១)- តារាងសូរស្រះទោល :

| ស្រះមុខ (បបូរមាត់វែង) | ស្រះកណ្ដាល (បបូរមាត់វែង) | ស្រះក្រោយ | |
|---|---|---|---|
| | | បបូរមាត់វែង | បបូរមាត់វង់ |
| i - អ៊ិ .......... iː - អ៊ី | ɯ - អ៊ឹ ....... ɯː - អ៊ឺ | ........................ | u - អ៊ុ ..... uː - អ៊ូ |
| e - អិ ........ eː - អេ | ........................... | ..... ɣ - អ៊ើ ....... | o - អុ ..... o ː - អូ |
| ẹ -អ៊ើ ................. | ........................... | ........................ | ọ - អ៊ោ ........... |
| ɛ - អែ ............... | œ/ə - អឹ ...... œː -អឺ | ........................ | ɔ - អ៊ំ .... ɔː - អ៊ៅ |
| ẹ - អ៊ែ ................ | ........................... | ........................ | ........................ |
| a - អាំ ....... aː - អា | ........................... | α - អ៉ .... αː - អ | ........................ |

តារាងទី១៨

កំណត់សម្គាល់ : កាលណាមានស្រះវែងនិងស្រះខ្លីសន្ធាននឹងគ្នា គេប្រើចំណុចពីរ ( : ) សម្រាប់ សម្គាល់ស្រះវែង ។ បើស្រះណាជាស្រះឯកោ គេមិនបាច់ប្រើចំណុចពីរ ដើម្បី សម្គាល់ស្រះវែងទេ ទោះស្រះឯកោទាំងនោះជាស្រះវែងក៏ដោយ ។

#### (២ ) - តារាងសូរស្រះល្បាយ :

លោក ឃួន សុខម្ភ បានចាត់ទុកកន្សោមសូរមួយចំនួនថាជាទ្វេស្វរៈ (diphtongues) ឬ ស្រះផ្សំ ហើយ ដែលគាត់បានកត់ត្រាដូចនេះ : [ɛi], [ei], [ɔu], [au], [ai] ។ គាត់បានបញ្ជាក់ថា ស្រះផ្សំរបស់គាត់ទាំងប៉ុន្មាននោះឥតទទួលព្យញ្ជនៈប្រកបទេ ។ បើយើងស្វែងរកស្រះផ្សំទាំងប៉ុន្មានរបស់គាត់នោះ ក្នុងភាសាខ្មែរ យើងឃើញវាត្រូវនឹងសំឡេង[៣១] អ៊ែ , អី , អ៊ៅ , អៅ និង អៃ ដែលយើងត្រូវកត់ត្រាជាព្យាង្គបែបនេះវិញ : [ɛj], [ej], [ɣw], [aw] និង [aj] ។ ខ្ញុំយល់ថា សូរផ្សំទាំងប៉ុន្មាន មិនប្រាកដជាស្រះផ្សំទេ ។ សូរផ្សំដែលតាងដោយសញ្ញា ី (ជាមួយព្យញ្ជនៈពួក.អ)[៣២] , ៃ , ៅ សុទ្ធតែជាព្យាង្គដែលមាន

---

[៣១] : សូមកុំច្រឡំ "សំឡេង" (ដែលមានន័យទូទៅ) និង "សូរ" (ដែលមានន័យជាក់លាក់ក្នុងសូរវិទ្យា) ។

[៣២] : ជាមួយព្យញ្ជនៈពួកអ៊ សញ្ញាស្រះនិស្ស័យ ី នេះមានសូរ [iː] (ដែលជាសូរស្រះពិតប្រាកដ) ដូច "មី " [miː] ដែលអាចទទួលព្យញ្ជនៈប្រកបបាន ដូច "មីង" ជាដើម ។

សូរព្យញ្ជនៈប្រកបរួចទៅហើយ ដូចមានការកត់ត្រាខាងលើស្រាប់[៣៣] ។ ដោយមានព្យញ្ជនៈប្រកប [j] ( យ ) និង [w] ( វ ) រួចទៅហើយ យើងមិនអាចថែមព្យញ្ជនៈប្រកបមួយទៀតបានទេ ពីព្រោះខ្មែរយើងមិនអាចអានព្យញ្ជនៈប្រកបពីរជាប់គ្នាឡើយ ។

យើងមិនអាចអានពាក្យ "សន្និសីទ" ដោយគោរពសូរ [ej] របស់សញ្ញា ី ឡើយ យើងត្រូវប្តូរសូរ [ej] អោយទៅជាសូរ [e] / [œ] ទើបយើងអានចេញ យើងអានថា [sɑnis<u>e</u>t] / [sɑnis<u>œ</u>t] គឺមិនមែន [sɑnis<u>ej</u>t] ទេ ( ដែលយើងអានមិនចេញ ) ។

ស្រៈនាសិកជៈនៃភាសាបារាំង ([ɛ̃], [ɔ̃], [ɑ̃],...) ត្រូវភាសាខ្មែរសងជាព្យាង្គបិទ "ស្រៈ + ង" ដូច្នេះហើយ ពាក្យបារាំង ដូច sens [sɑ̃s], ដូច Lecomte [ləkɔ̃t] ( ឈ្មោះមនុស្ស ), ដូច France [frɑ̃s] ,... ត្រូវភាសាខ្មែរសងដោយប្រើព្យញ្ជនៈប្រកបដល់ទៅពីរ [sɑŋs], [ləkoŋt], [frɑŋs] ដែលជាស្ថានភាពខុសពីទម្លាប់អំណានរបស់ខ្មែរ ហើយ ខ្មែរធម្មតា ( ខ្មែរដែលមិនទាន់ចេះភាសាបារាំងល្អិតល្អន់ ) ក៏ជម្រុះព្យញ្ជនៈមួយចោលជាស្វ័យប្រវត្តិ ( ព្យញ្ជនៈចុងបំផុត ) : ពាក្យសម្គាល់ឈ្មោះមនុស្ស Lecomte [ləkɔ̃t] ត្រូវខ្មែរអានថា [ləkɔ̃ / ləkoŋ] ដែលមានន័យមិនល្អក្នុងភាសាបារាំង ( [ləkɔ̃] = le con ) គឺ "មនុស្សថោកទាប"[៣៤] ។

ដូចយើងមិនអាចចាត់សញ្ញាព្យាង្គ ុំ ំ ាំ ះ ុះ េះ ោះ ថាជាស្រៈរួចមកហើយនោះ យើង<u>ក៏មិន</u>អាច ដូចគ្នានោះដែរ ចាត់<u>សញ្ញា</u>ព្យាង្គ ី [ej] , ៃ [aj , ẹj] , ៅ [aw , ɣw] ថាជាស្រៈបានដែរ ហើយ ក្រៅពីនេះ ខ្ញុំក៏មិនយល់ស្របនឹងបណ្ឌិត ឃួន សុខម្ភ លើចំណុចខ្លះទៀតផងដែរ ដូច្នេះហើយ ស្រៈដែលយើងគប្បីហៅថា "ស្រៈល្បាយ" ខ្មែរមានចំនួនតិចជាងចំនួនដែលមានក្នុងតារាងស្រៈផ្សំរបស់គាត់ ( សូមមើលតារាងរបស់គាត់នៅក្នុងឧបសម្ព័ន្ធ ) ។

---

៣៣ : ខ្ញុំឥតកត់ត្រាសូរតាមបណ្ឌិត ឃួន សុខម្ភ ទេ ។

៣៤ : នៅប្រទេសបារាំង លោក Lecomte តែងខកចិត្តជាមួយខ្មែរខ្លះ ដែលធ្វើការជាមួយគាត់ ពីព្រោះខ្មែរទាំងនោះហៅគាត់ថា លោក [ləkɔ̃ / ləkoŋ] (le con) ។

ដោយគេហៅស្រៈផ្សំក្នុងភាសាអឺរ៉ុប មានភាសាអង់គ្លេសជាដើម ថា"ទោស្វៈ"[diphtongue]/ "ត្រីស្វរៈ" [triphtongue] ដែលគេអានប្លែកពីស្រៈល្បាយយើងខាងលើ ខ្ញុំសុំយកពាក្យអង់គ្លេស "time" និង "power" មកពិនិត្យ ។ គេមិនគិតពីតួអក្សរដែលមានក្នុងអក្ខរាវិរុទ្ធនៃពាក្យទាំងនេះទេ ។ ពាក្យ "time" ត្រូវគេកត់ត្រាអំណានរបស់វាដូចនេះ : [taim] ហើយ ក្នុងអំណាននេះ [a] ត្រូវទទួលថិរវេលា ⅔ និង [i] ⅓ នៃថិរវេលាទាំងមូល : [a] វែងជាង [i] ។ ចំពោះពាក្យ "power" ត្រូវគេអានដូចនេះ : [pauə] ដែលក្នុងនោះស្រៈ [a] ត្រូវគេអានវែងជាងស្រៈ [u] ឬ ស្រៈ [ə] ។

ស្រៈល្បាយខ្មែរដែលមិនមែនជាទោស្វៈពិតប្រាកដទេនោះ ត្រូវគេអានស្រៈទាំងពីរ (ដែលជាធាតុផ្សំ) ដោយប្រើថិរវេលាស្មើគ្នា ។ ដើម្បីកុំអោយគេច្រឡំនឹងទោស្វៈ/ត្រីស្វរៈពិតប្រាកដ យើងគប្បីដាក់សញ្ញានេះ [⁀] ពីលើស្រៈល្បាយរបស់យើង ។

តាមការវិភាគរបស់ខ្ញុំ សូរខ្មែរដែលអាចចាត់ទុកថាជាស្រៈល្បាយមានដូចខាងក្រោម (ហើយស្រៈទាំងនេះឥតមានលក្ខណៈគ្រប់សព្វដូចស្រៈផ្សំនៃភាសាឯទៀត មានស្រៈផ្សំនៃភាសាអង់គ្លេស ជាដើម ពីព្រោះខ្មែរអានស្រៈរបស់ខ្លួនទាំងប៉ុន្មាននេះ ដោយមិនបង្ហួសលើស្រៈទី១ឡើយ) :

| ស្រៈមុខ | ស្រៈកណ្ដាល | ស្រៈក្រោយ |
|---|---|---|
| ie – អៀ ......... | ɯə - អឿ .......... | uo - អួ ............ |
| e̜a - អ៊ា់ ......... | ......................... | ......................... |
| e̜a: - អ៊ា ......... | ......................... | ......................... |
| ....................... | ......................... | ɔɑ - អ៊័រ ............. |
| αo - អៅ ........ | ......................... | ......................... |
| aə - អើ .......... | ......................... | ......................... |

<u>តារាងទី១៩</u>

គួរបញ្ជាក់ថា សញ្ញាប្រើដើម្បីកត់ត្រាស្រៈផ្សំខាងលើ (ឬ បើនិយាយឱ្យចំទៅ គឺជាស្រៈល្បាយ) ជាសញ្ញានៃអក្ខរក្រមសូរវិស័យអន្តរជាតិ (API) គឺយកតាមបណ្ឌិត ឃួន សុខម្ភ ដែលបានពិសោធក្នុងឡាបូ

សូរវិទ្យានៅសាកលវិទ្យាល័យ Humboldt, ក្រុង Berlin ដោយខ្ញុំបានបន្ថយសូរស្រៈល្បាយមួយចំនួនដែលខ្ញុំយល់ថាជាព្យាង្គ ។

**២.១.២ - <u>សទ្ទតានៃភាសាខ្មែរ</u> :**

ភាសាខ្មែរមានគូអប្បបរមាជាច្រើន យើងអាចប្រើវា ដើម្បីវិភាគរកសទ្ទតាខ្មែរដោយចៀសវិធីឯទៀត ដែលជាវិធីពិបាកប្រើ ។ម្យ៉ាងទៀត យើងបានដឹងមកហើយថា មានតែសូរផៅសន្តានទេ ដែលអាចជាកាឡាសូរ ដូច្នេះហើយ យើងពិនិត្យតែសូរជំពូកនេះទេ តាមរយៈគូអប្បបរមា ដើម្បីអោយឃើញថាតើសូរផៅសន្តានណាជាកាឡាសូរជាមួយគ្នា និង សូរផៅសន្តានណាជាសទ្ទតាផ្សេងគ្នា ។

**២.១.២.១ - <u>សទ្ទតាព្យញ្ជនៈ</u> :**

(១) - <u>វិភាគរកសទ្ទតា</u>

យោងតាមសេចក្តីរំលឹកខាងលើ ខ្ញុំនឹងស្រង់តែគូអប្បបរមាដែលទាក់ទងនឹងសូរផៅសន្តានទេ ដូចមានឧទាហរណ៍ខាងក្រោមនេះ :

- គូអប្បបរមាណ [pej] (ឧបករណ៍ភ្លេង) ~ [bej] (សំខ្យាស័ព្ទ) អនុញ្ញាតអោយយើងសន្និដ្ឋានថា ភាសាខ្មែរមានសទ្ទតា /p/ & /b/ ពីរដាច់គ្នា ។
- គូអប្បបរមាណ [pu:t] (ធ្វើអោយទៅជាដុំ) ~ [phu:t] (និយាយកុហក) អនុញ្ញាតអោយយើងសន្និដ្ឋានបណ្តោះអាសន្នថា ភាសាខ្មែរមានសទ្ទតា /p/ & /ph/ ពីរដាច់គ្នា ។

<u>ការពិចារណា & សន្និដ្ឋាន</u> :

(១) - យើងអាចរកគូអប្បបរមាណបានតាមសេចក្តីត្រូវការ ដើម្បីបង្ហាញអោយឃើញថា តើភាសាខ្មែរមានសទ្ទតាព្យញ្ជនៈចំនួន២១ ដូចចំនួនសូរព្យញ្ជនៈដែរឬទេ ប៉ុន្តែ ខ្ញុំសុំមិនរកតទៅទៀតទេ ខ្ញុំសុំទុកចិត្តលើអព្ភន្តរញ្ញាណម្តង ដែលញ្ញាក់ស្មារតីខ្ញុំអោយជឿជាក់លើលទ្ធភាពរកគូអប្បបរមាណបានតាមសេចក្តីត្រូវការ ។

(២) - ខ្ញុំគ្រាន់តែបញ្ចូលគំនិតលោក François Martini សាស្ត្រាចារ្យបារាំងបង្រៀនភាសាខ្មែរ នៅវិទ្យាស្ថានភាសាបរទេសនៅក្រុងប៉ារីស ដើម្បីបង្ហាញអោយឃើញថា [ph] , [th] , [ch] & [kh] មិន

មែនជាព្យញ្ជនៈទោលដែលមានបន្លឺល្បាយ ដូច k͡p & g͡b , ... នៃភាសាខ្លះនោះទេ តែជាសូរផ្សំ ពីព្រោះកាលណាគេដាក់អន្តេបទ / - ɑm / ɔm- / ខាងក្នុងដើម្បីបង្កើតពាក្យកម្លាយ កន្សោម [ph] / [th] / [ch] / [kh] ត្រូវបែកចេញជា [p] + [h] / [t] + [h] / [c] + [h] / [k] + [h] ដូចមានឧទាហរណ៍តទៅ :

- [thɔm] ( ធំ ) + /-ɔm-/ > [ tɔmhɔm > tumhum[៣៥] ] ;
- [chɛa:n] ( ឈាន ) + /-ɔm-/ > [ cɔmhɛa:n ] ;
- [kho:c] ( ខូច ) + /-ɑm-/ > [ kɑmho:c ] .
- [phu:t] ( ភូត )+ /-ɔm-/ > [*pɔmhu:t] ។ សញ្ញាផ្កាយ [*] ប្រាប់ថា ពាក្យនេះគ្មានទេក្នុងភាសាខ្មែរ ប៉ុន្តែ វាជាសក្តានុពលក្នុងប្រព័ន្ធវេយ្យាករណ៍ខ្មែរ ។

បើ [ph] / [th] / [ch] / [kh] ជាព្យញ្ជនៈទោលមែននោះ ( ដែលមានបន្លឺល្បាយ ដូច k͡p, g͡b,... ) គេគួរតែបានជាលំដាប់លំដោយនូវពាក្យកម្លាយ [*thɔmnɔm], [*chɔmnɛa:n], [*khɑmno:c] ប៉ុន្តែផ្ទុយទៅវិញ ពាក្យកម្លាយខ្មែរពិតប្រាកដជាពាក្យដែលមានក្នុងឧទាហរណ៍ជាក់ស្តែងខាងលើ ( គឺមិនមែនពាក្យសម្មតិកម្មដែលមានសញ្ញាផ្កាយនៅខាងឆ្វេងនេះទេ) ដូច្នេះហើយ [ph] / [th] / [ch] / [kh] ពិតជាសូរផ្សំ ( ព្យញ្ជនៈ + ព្យញ្ជនៈ ) មែន ហើយព្យញ្ជនៈខ្មែរនៅសល់តែ១៧សទ្ទតាទេ ( ២១-៤ ) គឺ :

**/ b , p , d , t , c , k , ʔ, m , n , ɲ , ŋ , s , h , r, l , w, j /** ។

( ២ ) - តារាងសទ្ទតាព្យញ្ជនៈ

| **ទីបន្លឺ** → | បន្លឺបបូរមាត់ | | បន្លឺបបូរមាត់&ធ្មេញ | | បន្លឺធ្មេញ | | បន្លឺក្រអូម | | បន្លឺរនាំងក្រអូម | | បន្លឺកន្ទេត | | បន្លឺដើមក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អឃោសៈ/ឃោសៈ | - | + | - | + | - | + | - | + | - | + | - | + | - | + |
| **វង្គះខ្យល់** ↓ | | | | | | | | | | | | | | |
| សទ្ទតាឱស្ឋជៈ | p | b | | | t | d | c | | k | | | | ʔ | |
| **វង្គះបន្ទុះ** | | | | | | | | | | | | | | |
| សទ្ទតានាសិកជៈ | | m | | | | n | | ɲ | | ŋ | | | | |
| **វង្គះព្រដុស** | | | | | s | | | | | | h | | | |

---

៣៥ : [tɔmhɔm] បានក្លាយទៅជា [tumhum] ពីព្រោះមានបាតុភូតបម្រែសូរ ( changement phonétique ) ។

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សទ្ទតារលាស់ **វង្គះល៉ហ្សូរ ........** | | | | | | r | | | | | | | | |
| សទ្ទតារលាត | | | | | | l | | | | | | | | |
| **វង្គះព្យញ្ជះកន្លះ** សទ្ទតាព្យញ្ជនះកន្លះ | | | | w | | | | j | | | | | | |

<u>តារាងទី២០</u>

<u>កំណត់សម្គាល់</u> : (១) - សញ្ញា (+) សម្គាល់សទ្ទតាព្យញ្ជនះឃោសៈ ; សញ្ញា (-) សម្គាល់សទ្ទតាព្យញ្ជនះអឃោសៈ ។
(២) - លោកសាស្ត្រាចារ្យបណ្ឌិត នៅ ស៊ុន យល់ថា ភាសាខ្មែរគ្មានសទ្ទតា /ʔ/ ទេ ។ /ʔ/ គ្រាន់តែជាសូរ ដែលអាចបន្លឺឡើងក្នុងបរិបទខ្លះ ។ ខ្ញុំក៏យល់ស្របនឹងគាត់ដែរ ។

### ២.១.២.២ - <u>សទ្ទតាស្រៈ</u> :

(១) - <u>វិភាគរកសទ្ទតា</u> :

យើងបានឃើញរួចមកហើយថា គូអប្បបរមាណអាចអោយយើងសន្និដ្ឋានថា សូរពីរប្លែកគ្នា ក្នុងគូអប្បបរមាណនោះ ជាសទ្ទតាពីរប្លែកគ្នាដែរ ។ តារាងខាងក្រោមនេះបង្ហាញគូអប្បបរមាណនិងសទ្ទតាស្រះ ដែលចេញជាលទ្ធផល តាមលំដាប់លំដោយបន្តបន្ទាប់គ្នា ។ រីឯ ការកំណត់ន័យរបស់ពាក្យនីមួយៗ គឺជាសម្រង់ចេញពីវចនានុក្រមរបស់សម្ដេចសង្ឃរាជ ជួន ណាត ។

| ល.រ | គូអប្បបរមាណ | សទ្ទតា |
|---|---|---|
| ១ | ពាក្យ [cib] (ជិប = ផ្ទឹបបបូរមាត់បឺតយកតែបន្តិច)<br>ពាក្យ [ci:b] (ជីប = រឹមរួមបត់បង្រួមជាផ្នត់) | / i / ~ / i: /<br>អ៊ិ ~ អ៊ី |
| ២ | ពាក្យ [jɯt] (យឺត = ទាញអោយដាបមកជិត)<br>ពាក្យ [jɯ:t] (យឺត = ដែលមិនរហ័ស) | /ɯ/ ~ /ɯ:/<br>អ៊ឹ ~ អ៊ឺ |
| ៣ | ពាក្យ [truŋ] (ទ្រុង = ប្រដាប់សម្រាប់ដាក់សត្វ)<br>ពាក្យ [tru:ŋ] (ទ្រូង = អវយវៈត្រង់ប៉ែកខាងមុខ ពីក្រោមដងកាំបិត ចុះមកដល់ចុងដង្ហើម) | /u/ ~ /u:/<br>អ៊ុ ~ អ៊ូ |

| | | |
|---|---|---|
| ៤ | ពាក្យ [crec] ( ច្រិចៗ = សូរទឹកចេញពីប្រហោងតូចៗមានអាក់ម្តងៗ)<br>ពាក្យ [cre:c] ( ច្រេច/ច្រេចៗ = សូរសម្រែកតូចស្រួយ) | /e/ ~ /e:/<br>អិ ~អេ |
| ៥ | ពាក្យ [pœŋ]( ប៊ឹង = ស្លៀកវិណ្ណបាំងកេរ្តិ៍ខ្មាស់ដោយសំពត់មួយផ្ទាំងតូច)<br>ពាក្យ [pœ:ŋ] ( ប៊ឹង = សូរព្ទដោយស្នាថ្លោះជាដើម) | /œ/ ~ /œ:/<br>អឺ~ អឺ |
| ៦ | ពាក្យ [cok] ( ចុក = បិទដោយឆ្នុក)<br>ពាក្យ [co:k] ( ចូក = កាយយកដោយចបជីក ) | /o/ ~ /o:/<br>អុ ~ អូ |
| ៧ | ពាក្យ [ lɔŋ ] ( លង់ = ជ្រុល ហួស)<br>ពាក្យ [ lɔ:ŋ] ( លង = ល្បួង) | /ɔ/ ~ /ɔ:/<br>អ៊ ~ អ៊ |
| ៨ | ពាក្យ [cak] ( ចាក់ = បុកដោយគ្រឿងប្រហារមានមុខស្រួច)<br>ពាក្យ [ca:k] ( ចាក = បែកគ្នា ឃ្លាតគ្នា ) | /a/ ~/a:/<br>អា់ ~ អា |
| ៩ | ពាក្យ [bɑk] ( បក់ = ធ្វើអវយវៈដែលអាចកម្រើកបានអោយកម្រើក)<br>ពាក្យ [bɑ:k] ( បក = យកសំបកចេញ) | /ɑ/ ~ /ɑ:/<br>អ់ ~ អ |
| ១០ | ពាក្យ [ri:ŋ] ( រីង = ហួត ខះ)<br>ពាក្យ [rɯŋ] ( រឹង = ទីទៃពីទន់) | / i: / ~ /ɯ/<br>អ៊ី ~ អ៊ឹ |
| ១១ | ពាក្យ [ke:] ( កេរ = ដំណែល)<br>ពាក្យ [ke̜] ( គេ = សម្រាប់និយាយចំពោះអ្នកដទៃដោយមិនចេញ ចំឈ្មោះអ្នកណាមួយ) | /e:/ ~ /e̜/<br>អេ ~ អ៊េ |
| ១២ | ពាក្យ [ke̜] ( គេ = ដូចមានខាងលើ)<br>ពាក្យ [kɛ̜:] ( គែ = អវយវៈរបស់សត្វ ដែលសម្រាប់ដាក់អាហារថ្មី នៅផ្ទាប់នឹងគល់ក) | /e̜/~ /ɛ̜/<br>អ៊េ ~ អ៊ែ |
| ១៣ | ពាក្យ [pɛn]( ប៉ែន = ប្រដាប់ធ្វើដោយដែកមានរន្ធតូចសម្រាប់ហូតលួស)<br>ពាក្យ [pen] ( ប៊ិន = ប្រសប់ ស្ទាត់) | /ɛ/ ~ /ɛ̜/<br>អែ ~ អិ |
| ១៤ | ពាក្យ [kɛŋ]( កែង = ប្រដាប់ជាងឈើសម្រាប់ផ្ទៀងអោយត្រឹមត្រង់ជ្រុង)<br>ពាក្យ [ke:ŋ] ( កេង = កាត់តម្រុយដេញរកគំនិតគ្នា) | /ɛ/ ~ /e:/<br>អែ ~ អេ |

| | | |
|---|---|---|
| ១៥ | ពាក្យ [ko:] ( កូរ = ធ្វើវត្ថុរាវអោយកម្រើក)<br>ពាក្យ [kọ] ( គោ = សត្វពាហនៈសម្រាប់ប្រើទឹម ដឹក អូស) | /o:/ ~ / ọ/<br>អូ ~ អ៊ោ |
| ១៦ | ពាក្យ [pọŋ] ( ពោង = ប្រដាប់សម្រាប់ទម្លាក់បណ្តែតទឹកហែលតោង)<br>ពាក្យ [pɔ:ŋ] ( ពង = ស្បែក ឬ សាច់ ដែលប៉ោងឡើងដោយចំហាយក្តៅ) | /ọ/ ~ /ɔ:/<br>អ៊ោ ~ អ៊ |
| ១៧ | ពាក្យ [tœ:] ( តើ = ពាក្យសម្រាប់និយាយប្រថ្មូនបំពេញអោយលះសេចក្តី សង្ស័យ)<br>ពាក្យ [tɤ] ( ទើរ = ជាប់នៅពីខាងលើដោយមានអ្វីទ្រមិនអោយធ្លាក់) | /œ:/ ~ /ɤ/<br>អើ ~ អ៊ើ |
| ១៨ | ពាក្យ [kuo] ( គួរ = សម គប្បី ឥតទាស់)<br>ពាក្យ [ko:] ( កូរ = ធ្វើវត្ថុរាវអោយកម្រើក) | /uo/ ~ /o:/<br>អួ ~ អូ |
| ១៩ | ពាក្យ [kuo] ( គួរ = ដូចមានខាងលើ )<br>ពាក្យ [ku:] ( គូរ = ធ្វើអោយកើតជាគំនូរតំណាងរូបរាងសរពើ ) | /uo/ ~ /u:/<br>អួ ~ អ៊ូ |
| ២០ | ពាក្យ [cao] ( ចោរ = ជនអ្នកលួចគេ)<br>ពាក្យ [cọ] ( ជោរ = រីកចិត្ត ដោយពាក្យបញ្ចោរ) | /ao/ ~ /ọ/<br>អោ ~ អ៊ោ |
| ២១ | ពាក្យ [kaot] ( កោត = ស្ញែង ស្ញើច)<br>ពាក្យ [ko:t] ( កូត = រូតកោសចុះឡើងៗ) | /ao/ ~ /o:/<br>អោ ~ អូ |
| ២២ | ពាក្យ [daə] ( ដើរ = លើកជើងឈានទៅ)<br>ពាក្យ [dɛ] ( ដែរ = ដូចគ្នា បានដូចគ្នា) | /aə/ ~ /ɛ/<br>អើ ~ អែ |
| ២៣ | ពាក្យ [kieŋ] ( កៀង = ប្រមូលនាំទៅ)<br>ពាក្យ [kɯəŋ] ( កឿង = កើល) | /ie/ ~ /ɯə/<br>អៀ ~ អឿ |
| ២៤ | ពាក្យ [mẹa:ŋ] ( មាន = បាន កប បរិបូរដោយ)<br>ពាក្យ [mien] ( មៀន = ឈ្មោះឈើមួយប្រភេទ ជាដំណាំស្រុក ផ្លែមូលៗ វេលាទុំមានក្លិនសាច់ក្រអូប មានរសផ្អែម) | /ẹa:/ ~ /ie/<br>អ៊ា ~ អៀ |
| ២៥ | ពាក្យ [wɔɑt] ( វ៉ាត់ = រលាស់ចុងឡើង)<br>ពាក្យ [wẹa:t] ( វាត = ធ្វើអោយទូលាយ អោយធំ) | /ɔɑ/ ~ /ẹa:/<br>អ៊័ ~ អ៊ា |

| | | |
|---|---|---|
| ២៦ | ពាក្យ [pe̤ak] ( ពាក់ = ដាក់ព្យួរ ឬ ដាក់បន្ដោក)<br>ពាក្យ [pe̤a:k] ( ពាក្យ = ប្រយោគសម្ដី) | /e̤a/~/e̤a:/<br>អ៊ា់ ~ អ៊ា |

តារាងទី២១

(២) សម្រង់សទ្ទតាស្រៈ

តាមអក្ខរាវិរុទ្ធ ពាក្យ "ជាប់" ត្រូវភ្ជាប់ទៅក្រុមពាក្យ ដូច "ជ្រាប" ដូច "ទាប" ។ តាមសទ្ទតាវិទ្យា និងតាមជាតិសព្ទ ការភ្ជាប់នេះជាការត្រឹមត្រូវ ពីព្រោះ នៅតាមតំបន់ខ្លះ ដូចនៅខេត្តសៀមរាបជាដើម គេនៅអាន [ce̤ap] នៅឡើយ ប៉ុន្ដែ នៅតាមខេត្តឯទៀត ពាក្យ "ជាប់" នេះត្រូវគេអានថា [cɔap] ហើយត្រូវភ្ជាប់ទៅក្រុមពាក្យ ដូច "ជ័រ" [cɔa] ដូច "ទំព័រ" [tumpɔa] ទេវិញ ។ ម្យ៉ាងទៀត តារាងទី១៩បានបង្ហាញអោយឃើញថា សូរស្រៈ [ɔa] ឥតមានជាប់ផៅសន្ដានអ្វីនឹងសូរស្រៈឯទៀតក៏ទេដែរ ដូច្នេះហើយ [ɔa] ប្រាកដជាសទ្ទតាមួយប្លែកពីគេក្នុងភាសាខ្មែរ ។ ដោយយើងមានគូអប្បបរមាគ្រប់គ្រាន់សម្រាប់សូរទាំងប៉ុន្មានដែលមានក្នុងតារាង ទី១៨ និង ទី១៩ យើងអាចសន្និដ្ឋានថា សូរទាំងនោះជាសទ្ទតា[៣៦] :

**- សទ្ទតាស្រៈទោលមាន ២៣ ;**

**- សទ្ទតាស្រៈល្បាយមាន ៨ ។**

**២.២ - ព្យាង្គ** (syllabe).

តាមលោកសូស្សៀរ (Saussure) "ព្យាង្គជាសម្ព័ន្ធគ្រឹះដែលជាមូលដ្ឋានក្នុងការផ្គុំសទ្ទតាអោយកើតជាពាក្យ ។ សម្ព័ន្ធគ្រឹះនេះឋិតនៅលើភាពខុសគ្នារវាងសទ្ទតាដែលគេហៅថា ព្យញ្ជនៈ និង ស្រៈ" ។

គាត់បានបញ្ជាក់ថា ព្យញ្ជនៈរួមជាមួយស្រៈ តាមលំដាប់នៃកម្រិតរង្វះខ្យល់ ។ គេអាចតាងព្យាង្គតាមសញ្ញាបែបនេះ : < > (< = បំណើក + > = បំណិទ) ។ ព្រំដែនរវាងព្យាង្គឋិតនៅត្រង់កន្លែងដែល

[៣៦] : - គូអប្បបរមាបង្ហាញបន្លែករវាង / e̤a / & / e̤a:/ និង រវាង / i / & / i:/ ជាគូពិបាករកក្នុងភាសាខ្មែរ ហើយគូដែលមានក្នុងតារាងខាងលើអាចមិនត្រឹមត្រូវ ។ ចំពោះករណីនេះក្ដី និង ចំពោះចំណុចត្រង់ណាទៀតក្ដី សូមអស់លោកអ្នានមេត្ដាជួយ កែតម្រូវតាមការគួរ : ខ្ញុំអរគុណជាមុន ។

គេចេញពីសូរបិទ ហើយ ចូលទៅសូរបើក។ រាល់ទីណាដែលមានសូរបិទនិងសូរបើកបន្ទាប់គ្នា ដូចសញ្ញាបែបនេះ : >< (បំណិទ + បំណើក) គឺ ទីនោះហើយដែលជាព្រំដែនរវាងព្យាង្គ។

គេអាចដាក់ព្យាង្គនានាជារូបមន្ត ដោយប្រើអក្សរកាត់ ( ស = ស្រៈ; ព = ព្យញ្ជនៈ) ដូចតទៅនេះ :

(១) - ព្យាង្គបើក ( ឥតមានព្យញ្ជនៈនៅខាងចុង) : ស , ពស , ពពស , ពសពស ,... ។

(២) - ព្យាង្គបិទ ( មានព្យញ្ជនៈនៅខាងចុង) : សព , ពសព , ពពសព , ពសពសព ,... ។

<u>កំណត់ចំណាំ</u> : ព្យាង្គបើកជាលក្ខណៈសកល ដែលគេប្រទះក្នុងភាសាទាំងអស់ក្នុងលោក ។ ចំពោះព្យាង្គបិទវិញ គេប្រទះតែក្នុងភាសាខ្លះ ហើយ បណ្ដាភាសាទាំងនោះ មានតែភាសាខ្លះទេដែលប្រើកន្សោមព្យញ្ជនៈ "ព + ព" ដូច : សពព, ពសពព, ពពសព, ពពពសព,... ។

## ២.៣ - <u>អក្សរខ្មែរ និង សូរនៃភាសាខ្មែរ</u>

តាមធម្មតា គេបង្កើតអក្សរមួយសម្រាប់កត់ត្រាសទ្ទតាមួយ : សទ្ទតានិងអក្សរមានចំនួនស្មើគ្នា ប៉ុន្តែ ដោយអក្សរខ្មែរដែលបុព្វបុរសយើងបានខ្ចីពីប្រទេសឥណ្ឌាមកមានចំនួនមិនដូចគ្នានឹងចំនួនសទ្ទតាខ្មែរសព្វថ្ងៃ យើងត្រូវផ្ទៀងមើលតាមរយៈប្រតិចារឹកអក្សរ( បន្ទាត់ទី២) ឱ្យឃើញថា តើសូរសទ្ទតាដើមណា ( របស់សំស្ក្រឹត) នៅជាសូរសទ្ទតាក្នុងភាសាខ្មែរ ( ទោះមានការប្រែប្រួលក្នុងសញ្ញាតាបន្លឺ (traits articulatoires) ក៏ដោយ ហើយ តើសូរសទ្ទតាណាខ្លះបានបាត់សញ្ញាតាបន្លឺមូលដ្ឋានរបស់ខ្លួន ហើយ នៅសល់តែរូប និង បានក្លាយជាសូរសទ្ទតាក្នុងភាសាខ្មែរដែលច្រឡំនឹងសូរសទ្ទតាមួយណាឬខ្លះណាទៀត ( ដូច "គ" ពិតមែនតែរូបវាប្លែកពី "ក" តែខាងផ្លូវសូរសទ្ទតាវិញ វាច្រឡំនឹងសូរសទ្ទតារបស់ "ក" ពីព្រោះ "គ" បានបាត់ ( ក្នុងភាសាខ្មែរសព្វថ្ងៃ) សញ្ញាតាបន្លឺឃោសៈរបស់វា , ... ជាដើម) ។

ដោយសារបន្ទាត់ទី២និងទី៣ យើងអាចសង្កេតឃើញការប្រែប្រួលនេះបានដោយងាយ. ឧ. "ក" ( បន្ទាត់ទី១) ត្រូវអានតាមភាសាបាលី/សំស្ក្រឹតថា [ka] ( បន្ទាត់ទី២) និង តាមភាសាខ្មែរថា [kɑ] ( បន្ទាត់ទី៣) ហើយ "គ" ( បន្ទាត់ទី១) ត្រូវអានតាមភាសាបាលី/សំស្ក្រឹតថា [ga] ( បន្ទាត់ទី២) និង តាមភាសាខ្មែរថា [kɔ] ( បន្ទាត់ទី៣) ។ល ។

## ២.៣.១- សញ្ញាព្យញ្ជនៈ និង សូរព្យញ្ជនៈ[៣៧] នៃភាសាខ្មែរ តាងដោយសទ្ទតាសំស្ក្រឹតតាមរយៈ ប្រតិចារឹកអក្សរ (translitération) & តាមរយៈអក្ខរក្រមសូរវិស័យអន្តរជាតិ (Alphabet phonétique international > API)

**ការបញ្ជាក់ឡើងវិញ :**

បន្ទាប់ពីអក្សរដែលខ្មែរបានខ្ចីពីភាសាបាលី/សំស្ក្រឹតទៅ បន្ទាត់ទី២គឺជាប្រតិចារឹកអក្សរ (សូរដើមនៃភាសាបាលី/សំស្ក្រឹតនេះ) បន្ទាត់ទី៣ជាអក្ខរក្រមសូរវិស័យអន្តរជាតិ (កត់តាមការអានរបស់ខ្មែរសព្វថ្ងៃ) :

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1- | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ | | | |
| 2- | ka | kha | ga | gha | na | ca | cha | ja | jha | ña | | | |
| 3- | kα | khα | kɔ | khɔ | ŋɔ | cα | chα | cɔ | chɔ | ɲɔ | | | |
| 1- | ដ្ដ | ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន | | | |
| 2- | ṭa | ṭha | ḍa | ḍha | ṇa | ta | tha | da | dha | na | | | |
| 3- | dα | thα | dɔ | thɔ | nα | tα | thα | tɔ | thɔ | nɔ | | | |
| 1- | ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ្ឡ | អ្អ ។ |
| 2- | pa | pha | ba | bha | ma | ya | ra | la | va | sa | ha | ḷa | a |
| 3- | bα | phα | pɔ | phɔ | mɔ | jɔ | rɔ | lɔ | vɔ | sα | hα | lα | α/ʔα |

ដោយមានប្រតិចារឹកអក្សរនិងអក្ខរក្រមសូរវិស័យអន្តរជាតិជាខ្សែលំនាំនិងជាបង្អែក យើងអាចធ្វើការពិចារណាវិភាគ ដូចតទៅ :

(១)- អ្នកបង្កើតប្រតិចារឹកអក្សរបានគិតថា សទ្ទតាក្រអូមសំស្ក្រឹត ដែលគ្មានក្នុងភាសាឡាតាំង អាចចាត់ទុកជាផៅសន្ដានជាមួយ t , th , d , dh , n (គ្រាន់តែមានទីបន្លឺនៅខាងក្រោយ t, th, d, dh, dh, n) : ដូច្នេះ គេបានសម្រេចចុចមួយពីក្រោម t , th , d , dh , n ដែលជាសទ្ទតាជើងធ្មេញ ដើម្បីឱ្យបានសូរសទ្ទតាក្រអូម ṭ, ṭh, ḍ, ḍh, ṇ នេះឡើង។

---

[៣៧] : កាលណាសាធារណជនប្រើពាក្យ "ព្យញ្ជនៈ" គេច្រើនប្រើក្នុងន័យ "អក្សរ/សញ្ញា" ដូចព្យញ្ជនៈ.ក ព្យញ្ជនៈ.ខ ជាដើម ។ ចំពោះភាសាវិទូវិញ គេច្រើនប្រើវាក្នុងន័យ "សូរ" ដើម្បីកុំអោយច្រឡំ ខ្ញុំក៏បញ្ជាក់ "សញ្ញាព្យញ្ជនៈនិងសូរព្យញ្ជនៈ" ។

(២) - តាមការប្រៀបធៀបរវាងសូររបស់ប្រតិចារឹកអក្សរ (ដែលទំនងជាស្របនឹងសូរដើមរបស់អក្សរឥណ្ឌា ដែលខ្មែរបានខ្ចីមកប្រើ) និងសូរដែលខ្មែរបន្លឺចេញពីអក្សរទាំងនោះ យើងអាចសង្កេតឃើញថា :

(២.១) - អក្សរ គ ឃ ជ ឈ ,... ដែលកត់ត្រាសូរព្យញ្ជនៈឃោសៈពីកំណើត បែរជាកត់ត្រាសូរព្យញ្ជនៈអឃោសៈក្នុងភាសាខ្មែរទៅវិញ ពីព្រោះភាសាខ្មែរគ្មានសូរព្យញ្ជនៈឃោសៈជំពូកនេះសម្រាប់អក្សរទាំងនោះទេ ;

(២.២) - លើសពីនេះទៅទៀត[៣៨] បញ្ហាស្មុគស្មាញបានកើតមានឡើងដោយមានការប្តូរសូរគ្នា រវាងអក្សរ. "ប" និងអក្សរ."ព"[៣៩] : "ប" : [p] ក្នុងអក្ខរក្រមសំស្ក្រឹត --> [b] ក្នុងអក្ខរក្រមខ្មែរ ឯ "ព" : [b] ក្នុងអក្ខរក្រមសំស្ក្រឹត --> [p] ក្នុងអក្ខរក្រមខ្មែរ ។ ម្យ៉ាងទៀត ខ្មែរបានយកអក្សរ "ដ" និងអក្សរ "ឌ" ដែលកត់ត្រាសូរព្យញ្ជនៈក្រអូមឥណ្ឌា (ដ = ṭa អឃោសៈ & ឌ = ḍa ឃោសៈ) មកសម្គាល់ព្យញ្ជនៈសូរធ្មេញរបស់ខ្លួន ហើយ អក្សរ "ទ" & "ធ" ដែលកត់ត្រាព្យញ្ជនៈឃោសៈសូរធ្មេញឥណ្ឌា [da, dha] បែរជាសម្គាល់ព្យញ្ជនៈអឃោសៈសូរធ្មេញខ្មែរ [tɔ, thɔ] ទៅវិញ ។

(៣) -ប្រតិចារឹកអក្សរបានបានទាញស្មារតីយើងលើបន្លែកអឃោសៈ-ឃោសៈពិតប្រាកដ[៤០] របស់ភាសាសំស្ក្រឹត ក្នុងផ្ទៃអក្សរព្រាហ្មី ដែលបានប្រែប្រួលក្នុងភាសាខ្មែរ : ka kha ga gha... pa pha ba bha,... ។ ដើម្បីចៀសការភាន់ច្រឡំ សូមបងប្អូនខ្មែរផ្អែកលើការកត់ត្រាតាមអក្ខរ-ក្រមសូរវិស័យអន្តរជាតិ (បន្ទាត់ទី៣)[៤១] ។

---

៣៨ : ការដែលអក្សរ "គ" សម្គាល់សូរ [k] ដូចអក្សរ "ក" ដែរ អក្សរ "ជ" សម្គាល់សូរ [c] ដូចអក្សរ "ច" ដែរ -ល- នោះវាមិនសូវជាស្មុគស្មាញប៉ុន្មានទេ ។

៣៩ : ប្រតិចារឹកអក្សរទំនងជាត្រឹមត្រូវនិងស្របតាមសូរដើមពីព្រោះវគ្គនីមួយៗសុទ្ធតែចាប់ពីព្យញ្ជនៈអឃោសៈទៅព្យញ្ជនៈឃោសៈ ក/k , ខ/kh , គ/g , ឃ/gh ... ប/p , ផ/ph , ព/b , ភ/bh... (ផ្ទុយពីខ្មែរដែលថា ប [b], ផ [ph]) ។

៤០ : "អឃោសៈ-ឃោសៈពិតប្រាកដ" ពីព្រោះ អក្សរ "គ" , អក្សរ "ជ",... ត្រូវបានគេបន្លឺសូរជាព្យញ្ជនៈឃោសៈពិតប្រាកដ /g/ , /ɟ /,... ក្នុងភាសាឥណ្ឌា ប្លែកពីសូរដែលខ្មែរបន្លឺចេញពីអក្សរ គ" ឬ អក្សរ "ជ" នេះ ដែលជាសូរអឃោសៈ ។

៤១ : ការផ្ទៀងផ្ទាត់ឱ្យឃើញការប្រែប្រួលពីអក្ខរក្រមសំស្ក្រឹតមកអក្ខរក្រមខ្មែរ អាចនាំឱ្យខ្មែរធម្មតាមានការវិលវល់ក្នុងស្មារតី ។ ប៉ុន្តែ កូនសៀវភៅមូលដ្ឋាននេះបានសរសេរឡើងសម្រាប់ និស្សិតខាងសូរវិទ្យាដែលយកចិត្តទុកដាក់ពិចារណា និង សម្រាប់អ្នកស្រាវជ្រាវ ។ ម្យ៉ាងទៀត ខ្ញុំសូមរំលឹកថា សូរវិទ្យាគ្មានបំណងនឹងកែប្រែអ្វីៗដែលគេធ្លាប់ចេះចាំមាត់រួចរាល់មកហើយ នោះទេ វាគ្រាន់តែជាការហាត់និស្សិតសូរវិទ្យាឱ្យចេះវិភាគ ចេះពិចារណា តែប៉ុណ្ណោះ ។

**២.៣.២ - សញ្ញាស្រៈ និង សូរស្រៈ**

ខ្មែរទាំងអស់គ្នាបានដឹងថា ភាសាខ្មែរប្រើស្រៈពេញតួនិងស្រៈនិស្ស័យ ប៉ុន្តែ មានខ្មែរតិចគ្នាណាស់ដែលដឹងថាចំនួនសញ្ញាស្រៈខ្មែរប្លែកគ្នាពីចំនួនសូរស្រៈខ្មែរ ។

ដូចករណីសញ្ញាព្យញ្ជនៈដែរ ដើម្បីជាខ្សែលំនាំដល់ស្មារតី និង ដើម្បីជាបង្អែកក្នុងការពិចារណាវិភាគ ខ្ញុំសូមស្រង់សញ្ញាស្រៈទាំងពីរប្រភេទ ដាក់ពិនិត្យជាលំដាប់លំដោយតទៅ :

កំណត់សម្គាល់ : ដូចក្នុងករណីព្យញ្ជនៈដែរ ក្នុងករណីស្រៈ (ពេញតួនិងនិស្ស័យ) បន្ទាត់ទី១ជាសញ្ញាស្រៈ បន្ទាត់ទី២ជាប្រតិចារឹកអក្សរ និង បន្ទាត់ទី៣ជាអក្ខរក្រមសូរវិស័យអន្តរជាតិ ។

**(១)- ស្រៈពេញតួ មាន ១២តួ :**

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1- | ឥ | ឦ | ឧ | ឩ | ឫ | ឬ | ឭ | ឮ | ឯ | ឰ | ឱ | ឲ |
| 2- | i | ī | u | ū | ṛ | ṝ | ḷ | ḹ | e | ai | o | au |
| 3- | e/ej | ej | o/u | ow/œw | rɯ | rɯ: | lɯ | lɯ: | ɛ | aj | a͡o | aw |

**ការពិនិត្យពិចារណា :**

(១.១) - ក្នុងភាសាខ្មែរ មានតែសញ្ញា ឯ & ឱ ទេ ដែលសម្គាល់សូរស្រៈ [ɛ] & ស្រៈ [a͡o] ។ សញ្ញា ឥ សម្គាល់សូរស្រៈទោលក្នុងករណីខ្លះគឺស្រៈ[e] ហើយ សម្គាល់ព្យាង្គ [ej] (អិ ប្រកបនឹង យ) ក្នុងករណី ខ្លះទៀត ។ រីឯសញ្ញាឯទៀត គឺសុទ្ធតែសម្គាល់ព្យាង្គទាំងអស់ : ស្រៈ + ព្យញ្ជនៈ/ព្យញ្ជនៈ + ស្រៈ[៤២] ។

(១.២) - សូរដើមនៃអក្សរព្រហ្មីនិងសូរអក្សរខ្មែរសព្វថ្ងៃ (ដែលជាអក្សរព្រហ្មីក្លាយ) ប្លែកគ្នាជាច្រើនចំណុច ហើយ អ្វីដែលគួរសង្កត់ខ្លាំង គឺភាសាសំស្ក្រឹត/បាលីប្រើ [ ṛ ] និង [ ḷ ] សម្គាល់សូរស្រៈប្រហាក់ប្រហែលគ្នា[៤៣]នឹងក្រុមអក្សរ "bl" និង "sm" នៃពាក្យអង់គ្លេស table/tourism ដែលត្រូវគេអាន [bəl] & [səm] ហាក់បីដូចជាមានស្រៈ [ə] នៅមុខ [l] ឬ មុខ [m] ដូច្នេះដែរ ។

---

[៤២] : តាមសូរវិទូ គេអាចយក ṛ , ṝ, ḷ, ḹ មកធ្វើជាស្រៈ ហើយ ការកត់ត្រាសូរស្រៈបែបនេះ ពិតជាត្រឹមត្រូវចំពោះភាសាមួយចំនួន ប៉ុន្តែ វាមិនត្រឹមត្រូវចំពោះភាសាខ្មែរទេ ។

**(២) - <u>សញ្ញាស្រៈនិស្ស័យ មាន ២៥តួ</u> :**

**<u>បច្ចយោគ</u> :** យើងបានឃើញថា ការសិក្សាអំពីសូរស្រៈខ្មែរបានផ្តល់ :

**- សូរស្រៈពួក.អ ចំនួន១៣ មាន :**

[e] អិ, [e:] អេ, [o] អុ, [o:] អូ, [ɛ] អែ, [œ/ə] អឺ, [œ:] អឹ, [a] អា', [a:] អា, [ɑ] អ', [ɑ:] អ, [ɑ͡o] អៅ, [a͡ə] អើ។

**- សូរស្រៈពួក.អ៊ ចំនួន១៨ មាន :**

[i] អ៊ិ, [i:] អ៊ី, [ɯ] អ៊ឹ, [ɯ:] អ៊ឺ, [u] អ៊ុ, [u:] អ៊ូ, ɤ អ៊ើ, [ẹ] អ៊េ, [ọ] អ៊ោ, [ɔ] អ៊', [ɔ:] អ៊, [ɛ̹] អ៊ែ, [ɯ͡ə] អឿ, [i͡e] អៀ, [u͡o] អួ[44], [ẹ͡a] អ៊ា', [ẹ͡a:] អ៊ា, [ɔ͡ɑ] អ៊័រ។

<u>បញ្ជាក់</u> : បើយើងមិនខ្ចីសញ្ញា "អ" មកប្រើជាទម្រ (ដោយប្រើតែសញ្ញាស្រៈនិស្ស័យនោះ យើងមិនអាចដឹងថាស្រៈណាមានសូរពួក.អ ស្រៈណាមានសូរពួក.អ៊ បានទេ។

អាស្រ័យហេតុនេះ យើងអាចនិយាយដោយសមហេតុផលថា សញ្ញាស្រៈនិស្ស័យខ្មែរគ្មានសូរផ្ទាល់ខ្លួនទេ ពីព្រោះសញ្ញានីមួយៗត្រូវសម្របសូរទៅតាមព្យញ្ជនៈ, ឧ.សញ្ញា " ា" បើគេប្រើជាមួយ "ក"(ព្យញ្ជនៈពួក.អ) គេត្រូវអានថា"កា" [ka:] បើគេប្រើជាមួយ "គ" (ព្យញ្ជនៈពួក.អ៊ ) គេត្រូវអានថា"គា" [kẹa:] ហើយ បើយើងអះអាងថា " ា" មានសូរផ្ទាល់ខ្លួន គឺ [a:] ហើយ បើយើងប្រើវាជាមួយ "គ" គឺ គ + ា [a:] > [ka]។ ក្រោយពីបានបង្ហាញហេតុផលថា សញ្ញាស្រៈនិស្ស័យជាសញ្ញាឥតសូរផ្ទាល់ខ្លួនរួចមក យើងបង្ហាញសញ្ញាស្រៈទាំងនេះ ដោយត្រៀមសូរជាពីរស៊េរី (មួយស៊េរីសម្រាប់ព្យញ្ជនៈពួក.អ និង មួយស៊េរីទៀតសម្រាប់ព្យញ្ជនៈពួក.អ៊) ដូចតទៅ :

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1- | ា | ិ | ី | ឹ | ឺ | ុ | ូ | ួ | ើ |
| 2- | ā | i | ī | ɨ | ɨ̄ | u | ū | uo | œ |
| 3- | a:/ẹ͡a: | e/i | ej/i: | œ/ɯ | œ:/ɯ: | o/u | o:/u: | u͡o | a͡ə/ɤ |

---

[43] : "ប្រហាក់ប្រហែល" ឥតមានន័យថា "ដូចគ្នា" នោះទេ។

[44] : គួររំលឹកថា សញ្ញាស្រៈ ឿ [ɯə], ៀ [iə], និង ួ [uo],អាចផ្តល់សូរដដែលទោះបើគេប្រើជាមួយព្យញ្ជនៈពួក អ ក្តី ឬ ព្យញ្ជនៈពួក អ៊ ក្តី, ឧ. ចឿ= ជឿ = [cɯə], កៀ=គៀ = [kiə], តួ=ទួ = [tuo]។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 1- ឿ | ៀ | េ | ែ | ៃ | ោ | ៅ | ុំ | ំ |
| 2- ɨə | ie | e | ae | ai | o | au | um̩ | m̩ |
| 3- ɯ͡ə | i͡ə | e/e̜ | ɛ/ɛ̜ | aj/e̜j | a͡o/o̜ | aw/ɣw | om/um | ɑm/ɔm |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1- ាំ[៤៥] | ះ | ិះ | ឹះ | ុះ | េះ | ោះ | ៗ |
| 2- ām | ah | ih | --- | uh | eh | oh[៤៦] | |
| 3- am/e̜am | as[៤៧]/e̜as | es/is | œs/ɯs | os/us | es/e̜s | aos/o̜s | |

**ការពិនិត្យពិចារណា :**

(១)- ខ្មែរទាំងអស់គ្នាបានយល់ច្បាស់ថា សញ្ញា ុំ ំ ាំ ះ ិះ ឹះ ុះ េះ ោះ មិនសម្គាល់សូរស្រៈទោល ដូចសញ្ញា ា ិ ី ឹ ុ ូ , ... ទេ (តែ ជាសញ្ញាសម្គាល់ព្យាង្គសុទ្ធសាធ) ។ ម្យ៉ាងទៀតគួរបញ្ជាក់ថា ស្រៈនិស្ស័យ ី ប្រើជាមួយព្យញ្ជនៈពួក.អ ក្លាយទៅជាព្យាង្គ "អិ + យ → អិយ" ។

(២)- ខ្មែរជាច្រើននាក់នៅមិនទាន់យល់ថា ៃ & ៅ ជាសញ្ញាសម្គាល់ព្យាង្គដូច ុំ ំ ាំ ះ ,... ដែរនៅឡើយទេ ។

(៣)- ខ្មែរទាំងអស់គ្នាបានយល់ច្បាស់ថា សូរស្រៈ[ɑ]/[ɑː] ឬ ស្រៈ[ɔ]/[ɔː] គ្មានរូបសញ្ញាទេ ប៉ុន្តែប្រហែលជាមានខ្មែរតិចគ្នាណាស់ដែលបានចាប់អារម្មណ៍ថា កង្វះស្រៈ[ɑ]/[ɑː] ឬកង្វះស្រៈ [ɔ]/[ɔː] ជាហេតុនាំអោយអក្សរខ្មែរត្រូវការប្រើជើងអក្សរ : បើសិនណាយើងយករូបសញ្ញាអ/អ៊ ធ្វើជាស្រៈ

---

៤៥ : ចំពោះព្យញ្ជនៈពួក.អ៊ សញ្ញាព្យាង្គ ុំ ំ ាំ ត្រូវគេអានផ្សេងៗគ្នាទៅតាមសម័យកាលឬទៅតាមក្រុម : នៅពេលខ្លះ គេអាន តាមលំដាប់ [um] , [ɔm] , [e̜am] នៅពេលខ្លះទៀត គេអាន [um] , [um] , [ɔm] ។

៤៦ : ការកត់ត្រាតាមប្រតិចារឹកអក្សរ (translitération) ទាក់ទងនឹងស្រៈពេញតួនិងស្រៈនិស្ស័យ បានពីលោកសាស្ត្រាចារ្យ បណ្ឌិត ឡុង សៀម ។

៤៧ : គេបានដាក់ [h] ជំនួស [s] ដែលជាសូរនៃអក្សរ "ស" ខ្មែរ ដោយសំអាងថា កាលណាគេប្រើក្នុងតួប្រកប ព្យញ្ជនៈ "ស" ត្រូវគេអានបន្ទើរ ហើយ មានសូរដូច [h] ប៉ុន្តែ គប្បីចាំថា ព្យញ្ជនៈប្រកបទាំងអស់ក្នុងភាសាខ្មែរសុទ្ធតែជាអតិសទ្ធតា (voir supra) ដូច្នេះហើយ ខ្ញុំយល់ថា គប្បីយើងកុំកត់ត្រាដោយឡែកចំពោះតែសូរព្យញ្ជនៈ "ស" នេះឡើយ ។

យើងត្រូវសរសេរ[កអង] ដើម្បីអោយគេអានថា[kɑŋ] ។ ក្នុងករណីនេះ ( ក្នុងករណី ដែលស្រះ[ɑː] មានរូបជា [អ] បើយើងសរសេរ[កង] គឺវាត្រូវនឹងអក្ខរក្រមសូរវិស័យអន្តរជាតិ [kɔŋ] ដូច [ក៏] នៃអក្ខរាវិរុទ្ធខ្មែរសព្វថ្ងៃទៅវិញទេ[៤៨] ។

( ៤ ) - លើសពីសញ្ញាព្យញ្ជនៈទៅទៀត សញ្ញាស្រៈមិនអាចអោយយើងដឹងចំនួនសូរស្រៈពិតប្រាកដទេ ពីព្រោះ សញ្ញាស្រៈខ្លះដូច ី កត់ត្រាព្យាង្គ [ej] ( ជាមួយព្យញ្ជនៈពួកអ. ) ។ ចំពោះសញ្ញាដូចនេះ ៃ, ៅ, ុំ, ំ, ាំ, ះ, ុះ, េាះ សុទ្ធតែសញ្ញាដែលកត់ត្រាព្យាង្គទាំងអស់ ( ទោះជាមួយព្យញ្ជនៈពួក.អក្តីឬជាមួយព្យញ្ជនៈពួក.អ៊ក្តី ) ។

## សូរសៀងវិទ្យា

(Etude de la prosodie)

លក្ខណៈសំឡេងដែលមិនចូលក្នុងពួកសូរ/សទ្ទតា ត្រូវនៅក្នុងពួកសូរសៀង ។ លក្ខណៈសំឡេងជំពូកនេះមាន ÷ បរិមាណ, ស្មៀង, សូរសង្កត់ និង ការលើកដាក់សំឡេងក្នុងល្បះ ។

**១ - បរិមាណ (la quantité)**

បរិមាណជាថិរវេលាដែលអំណានសូរណាមួយបានចំណាយ ។ ថិរវេលាអាចខ្លីឬវែង តាមបរិបទ តាមករណី ឬ តាមសេចក្តីត្រូវការ : ឧ. ស្រៈ " i " គេអាចអានខ្លី [ i ] ឬ វែង [ iː ] ។ ភាសាអង់គ្លេសប្រើបរិមាណ ដើម្បីបង្កើតស័ទ្ទតាពីរចេញពីសូរដើមតែមួយ ដែលមានសញ្ញាតាបន្ទី (traits articulatoires) តែមួយបែប ហើយ ប្លែកតែត្រង់បរិមាណនេះឯង ( សូមពិនិត្យឡើងវិញនូវពាក្យ [ʃip] & [ʃiːp] ទាក់ទងនឹងបន្នែករវាងសូរវិទ្យានិងសទ្ទតាវិទ្យា ) ។

**២ - ស្មៀង (le ton)**

---

[៤៨] : អក្សរដែលខ្មែរបានបានខ្ចីមកប្រើប្រាស់បានដើរតាមមាគ៌ាតក្កភាពរបស់ខ្លួន ( ដោយគ្មានរូបស្រៈអ./ស្រៈអ៊ អ្នកដែលបង្កើតអក្សរនេះបានបង្កើតជើងអក្សរ ដើម្បីដោះស្រាយបញ្ហាដែលបានចោទឡើង ) : ភាសាវិទ្យាជាវិទ្យាសាស្ត្រមូលដ្ឋានសម្រាប់ស្វែងយល់ពីភាសា និង អ្វីៗដែលទាក់ទងនឹងភាសា ( មានអក្ខរាវិរុទ្ធរបស់ភាសា ជាដើម ) ប៉ុន្តែ មិនមែនជាមនោគមវិជ្ជាចង់កែប្រែអ្វីៗដែលមានមកហើយនោះទេ ។

ស្មៀងជាការផ្លាស់កម្ពស់ក្នុងសូរតែមួយ ( ពីសំឡេងទាបទៅសំឡេងខ្ពស់ ឬ ពីសំឡេងខ្ពស់ទៅសំឡេងទាប) ។ ស្មៀងក៏ត្រូវភាសាខ្លះប្រើប្រាស់សម្រាប់បង្កើតសទ្ទតាពីរក្នុងសូរតែមួយដែរ ។ ភាសាចិន ភាសាយួន ភាសាសៀម ( នៅជិតខាងយើង) និង ភាសាជាច្រើននៅទ្វីបអាហ្វ្រិក ជាភាសាស្មៀងនិយម ។

- ក្នុងភាសាចិនពាក្យ "li" មានន័យថា "ផ្លែព័រ" ( ផ្លែឈើមួយបែប) កាលណាគេដាក់សំឡេងខ្ពស់[៤៥] ( សំឡេងគ្រលួច)/lí/ ឬ មានន័យថា"ផ្លែសាតែញ" ( ផ្លែឈើមួយបែបទៀត) កាលណាគេដាក់សំឡេងទាប ( សំឡេងគ្រលរ) /lì/ ។
- ក្នុងភាសាបាម្ប៊ូឡេ ពាក្យ"bla" មានន័យថា "ស្ត្រី"កាលណាគេដាក់សំឡេងខ្ពស់ /blá/ ឬ មានន័យថា "មកណេះ !" កាលណាគេដាក់សំឡេងទាប /blà/ ។

## ៣ - <u>**សូរសង្កត់**</u> (l'accent)

សូរសង្កត់ជាប្រពលភាព/កម្លាំងរបស់សូរ ។ ព្យាង្គក្នុងពាក្យ ( ឬ ពាក្យក្នុងកន្សោមពាក្យ/ក្នុងល្បះ) ដែលគេអានទទួលប្រពលភាពខុសគ្នា គឺព្យាង្គខ្លះទទួលប្រពលភាពខ្លាំង ព្យាង្គខ្លះទទួលប្រពលភាពខ្សោយ ។ ព្យាង្គដែលទទួលប្រពលភាពខ្លាំងជាព្យាង្គនៅក្រោមសូរសង្កត់ ។

### ៣.១ - <u>**សូរសង្កត់ក្នុងពាក្យ**</u> (l'accent du mot)

- ក្នុងភាសាបារាំង គឺព្យាង្គចុងបង្អស់ដែលត្រូវទទួលសូរសង្កត់ ÷ désirable [dezírabl] , travailler [travá je] , etc...
- ពាក្យក្នុងភាសាខ្មែរទទួលសូរសង្កត់ប្រហាក់ប្រហែលនឹងពាក្យបារាំងដែរ :

  ឧ. ឪពុក [ɔvpúk] , ជីតា [cíta] ,...
- ក្នុងភាសាអេស្ប៉ាញ៉ុល ÷

  * កាលណាមាន<u>ស្រៈ</u> ឬ ព្យញ្ជនៈ <u>[s] / [n]</u> នៅខាងចុងពាក្យ គឺព្យាង្គជាប់ជាមួយព្យាង្គចុងបង្អស់ ដែលត្រូវទទួលសូរសង្កត់ ÷ ´libro , cantan [´kantan] ;

---

[៤៥] ចំពោះសំឡេងខ្ពស់ឬតាមសូរមើលឡើងវិញនូវសូរវិទ្យាអាគូស្ទិក ។

* ក្នុងករណីឯទៀត គឺព្យាង្គចុងបង្អស់ដែលត្រូវទទួលសូរសង្កត់ ÷ proféssor.

- ក្នុងភាសាអង់គ្លេស ពាក្យខ្លះទទួលសូរសង្កត់លើព្យាង្គដើម ពាក្យខ្លះលើព្យាង្គ កណ្តាល ពាក្យខ្លះលើព្យាង្គចុង ( គឺគ្មានក្បួនអ្វីក្រៅពីការចំណាំទេ) ។

កំណត់សម្គាល់ : ក្នុងពាក្យឯកព្យាង្គ សូរសង្កត់ធ្លាក់លើឯកព្យាង្គរបស់ពាក្យនោះឯង ។ ពាក្យវែងតែងតែមានសូរសង្កត់ពីរ គឺសូរសង្កត់ច្បង និង សូរសង្កត់បន្ទាប់បន្សំ :
ឧ. international [ intənǽʃnal] .

**៣.២ - សូរសង្កត់ក្នុងកន្សោមចង្វាក់** (l'accent du groupe rythmique)

ការសង្កេត - សូរសៀងវិទ្យាមិនសូវមានលក្ខណៈវិទ្យាសាស្ត្ររឹងមាំដូចសូរវិទ្យា ឬ សទ្ទតាវិទ្យា ទេ ។ ដូច្នេះហើយ ការកំណត់ន័យអោយពាក្យបច្ចេកទេសខាងក្រោមនេះមិនសុទ្ធតែរឹងមាទាំងអស់ទេ។

កន្សោមចង្វាក់ជាកន្សោមពាក្យដែលមានសូរសង្កត់ជាទីសម្គាល់និងមានបែបផែនជាចង្វាក់ កាលណាគេអានកន្សោមពាក្យនោះ។ យើងបានឃើញហើយថា ពាក្យនីមួយៗសុទ្ធតែមានសូរសង្កត់របស់ខ្លួន។ ក្នុងភាសាខ្លះ ពាក្យរក្សាសូរសង្កត់របស់ខ្លួន កាលណាវារួមគ្នាជាកន្សោម ប៉ុន្តែ ក្នុងភាសាខ្លះទៀត ពាក្យខ្លះក្នុងកន្សោមត្រូវបាត់សូរសង្កត់របស់វា ហើយ មានតែពាក្យដែលនៅចំកំពូលចង្វាក់ទេ ដែលអាចរក្សាសូរសង្កត់របស់ខ្លួន : សូរសង្កត់នោះត្រូវគេចាត់ទុកថា ជាសូរសង្កត់របស់កន្សោមចង្វាក់ :

- ក្នុងភាសាអង់គ្លេស ពាក្យក្នុងកន្សោមរក្សាសូរសង្កត់របស់ខ្លួន :

  ឧ. a póor chíld ។

- ក្នុងភាសាបារាំង ពាក្យខ្លះក្នុងកន្សោមត្រូវបាត់សូរសង្កត់របស់ខ្លួន :

  ឧ. L'enfant malade ( ពាក្យ "enfant" និង ពាក្យ "malade" ដាច់ពីគ្នា មានសូរសង្កត់ផ្ទាល់ខ្លួន តែក្នុងកន្សោម មានតែពាក្យ "malade" ទេ ដែលរក្សាសូរសង្កត់ ពីព្រោះពាក្យនេះនៅចំកំពូលចង្វាក់ : សូរសង្កត់របស់វាក្លាយទៅជាសូរសង្កត់របស់កន្សោមទាំងមូល) ។

## ៣.៣ - សូរសង្កត់ក្នុងកន្សោមដង្ហើម (accent dans le groupe de souffle)

ក្នុងខ្សែសម្តី កន្សោមចង្វាក់ជួបគ្នានឹងកន្សោមចង្វាក់ ដើម្បីបង្កើតជាខ្សែកន្សោមចង្វាក់។ ដោយយើងត្រូវការដកដង្ហើមក្នុងអំណាន/ការនិយាយស្តី ខ្សែកន្សោមចង្វាក់ត្រូវដាច់ជាអន្លើៗ ចំកន្លែងដែលយើងដកដង្ហើម : កំណាត់មួយៗនៃខ្សែកន្សោមចង្វាក់មានឈ្មោះថា "កន្សោមដង្ហើម" (កន្សោមដង្ហើមមានកន្សោមចង្វាក់ច្រើនជាប់គ្នា) ។

កន្សោមដង្ហើមឥតមានសូរសង្កត់ផ្ទាល់ខ្លួនទេ : សូរសង្កត់ក្នុងកន្សោមដង្ហើមជាសូរសង្កត់របស់កន្សោមចង្វាក់ដែលនៅក្នុងកន្សោមដង្ហើមនោះ ដូចមានឧទាហរណ៍ខាងក្រោមនេះ :

(១) - L'enfant málade doit être soigné >

(២) - Les chants des oiseaux emplissaient ´l'air lorsque j'ouvris la fenêtre[៥០]

<u>កំណត់សម្គាល់</u> : ក្នុងឧទាហរណ៍ខាងលើនេះ យើងមានកន្សោមដង្ហើមតែមួយទេ ក្នុងល្បះនីមួយៗ។

អ្នកចេះនិយាយស្តីមិនឈប់ដកដង្ហើមតាមតែអំពើចិត្តនោះទេ គេដឹងថា គេត្រូវដកដង្ហើមកន្លែងណាដែលសេចក្តីរបស់គេមានន័យស្រួលយល់ដល់អ្នកស្តាប់។ តាមធម្មតា កន្សោមដង្ហើមជាន់គ្នានឹងខណ្ឌសញ្ញានៃអក្ខរាវិរុទ្ធ (ចុចមួយ, ក្បៀស, ចុចពីរ, ខណ្ឌ,...) ប៉ុន្តែជួនកាល គេអាចរំលងសញ្ញាទាំងនេះ កាលណាគេនិយាយដោយខឹង ឬ ដោយមានការភ័យភិត។ ក្នុងល្បះបារាំង "Rien ne sert de courir, il faut partir à point[៥១]" គេអាចមិនគោរពសញ្ញាក្បៀស ហើយ ឈប់ដកដង្ហើមនៅចុងល្បះតែម្តង ដូចមានការ កត់ត្រាតាមសូរវិធីនេះ : [rjɛ̃nəsərdəkurir-ilfopartirapwɛ̃] ។

<u>សេចក្តីបញ្ជាក់</u> : ពិតមែនតែគេអាចមិនកាត់ខ្សែសម្តីត្រង់ចន្លោះរវាង [kurir] និង [ilfo] ប៉ុន្តែគេមិនត្រូវភ្ជាប់ [r] ទៅនឹង [il] ទេ គឺគេមិនត្រូវអានថា [rifo] ទេ ។

---

[៥០] : ឧទាហរណ៍ខ្ចីពី André Roche, Eléments de prononciation anglaise, Masson & Cie Éditeurs 1959, Paris, p.117.

[៥១] : Op.cit. , André Roche, Eléments de prononciation anglaise, p. 111.

<u>កំណត់សម្គាល់</u>- ក្នុងការកត់ត្រាភាសាតាមសញ្ញាសូរវិធី គេមិនផ្ដាច់ពាក្យមួយៗពីគ្នាដូចក្នុងអក្ខរាវិរុទ្ធ បារាំង, អង់គ្លេស ជាដើមនោះទេ គេត្រូវដាក់ពាក្យជាប់ៗគ្នា <u>លើកលែងតែកាលណា នៅត្រង់កន្សោមដង្ហើម</u> ។

## ៤ - <u>ការលើកដាក់សំឡេង (intonation)</u>.

### <u>បុព្វយោគ</u>

ដោយសារបន្លែកខ្ពស់-ទាប (គ្រលួច-គ្រលរ) គេអាចសម្ដែងសុខុមភាព (nuances/subtilités) ផ្សេងៗនៃពាក្យសម្ដី : ពំនោល, សំណួរ, បញ្ជា, កំហឹង, ពំនេញចិត្ត ,... ។ គឺបន្លែករវាងសូរខ្ពស់-ទាបបែបនេះហើយដែលគេហៅថា "ការលើកដាក់សំឡេង" ពីព្រោះសូរត្រូវឡើងចុះៗ ។

គប្បីយើងចាំថា សូរសង្កត់ជាសូរដែលមានប្រពលភាពខ្លាំង (កម្លាំងខ្លាំង) រីឯការលើកដាក់សំឡេង ជាសូរទាប-ខ្ពស់ ហើយ ដើម្បីយល់ពីបន្លែករវាងសូរសង្កត់និងការលើកដាក់សំឡេងនេះ យើងត្រូវចាំអោយច្បាស់ថា អ្វីទៅហៅថា "ប្រពលភាព" អ្វីទៅហៅថា "កម្ពស់" ចំពោះសូរ (សូមវិលទៅរកសូរវិទ្យាអាគូស្ទិកវិញ) ។

ភាសាទាំងប៉ុន្មានក្នុងលោកសុទ្ធតែមានការលើកដាក់សំឡេង តែការលើកដាក់សំឡេងនេះតែងមានសភាពប្លែកៗគ្នាទៅតាមភាសានិងទៅតាមប្រភេទល្បះ ។ ចំពោះល្បះប្រកាស (phrase déclarative) ភាសាបារាំងនិងភាសាអង់គ្លេសមានការលើកដាក់សំឡេងផ្ទុយគ្នាស្រឡះ ។

(១) - ក្នុងភាសាបារាំង កន្សោមចង្វាក់ទី១និងទី២មានការលើកដាក់សំឡេង<u>ឡើងពីទាបទៅខ្ពស់</u> ហើយ ប្លែកគ្នាតែត្រង់ខាងចុងនៃកន្សោមទី២ដែលកម្ពស់សូរត្រូវធ្លាក់ទាបទៅវិញ ក្រោយពីបានឡើងខ្ពស់អតិបរិមាណលើព្យាង្គដែលជាប់នឹងព្យាង្គចុងបង្អស់ (សូរគ្រលរ/ទាប តែមានប្រពលភាពខ្លាំង) :




(២) - ក្នុងភាសាអង់គ្លេស កន្សោមចង្វាក់ទី១និងទី២មានការលើកដាក់សំឡេង<u>ចុះពីខ្ពស់មកទាប</u> (ផ្ទុយពីល្បះបារាំង) ហើយ ប្លែកគ្នាខាងចុង ដូចមានការបង្ហាញដោយ

រូបសញ្ញាខាងក្រោមនេះ :

He spent most of the time walking about the deck[៥២].

[ hi spent moust ov ðə taim wɔ: kiŋ ə baut ðə dek ]



ក្នុងភាសាតែមួយ សូររលកត្រូវដូរទៅតាមប្រភេទរបស់ល្បះ : ល្បះប្រកាស, ល្បះសំណួរ, ល្បះបញ្ជា, ល្បះបញ្ចោក,[៥៣] (ដូចល្បះក្នុងវង់ក្រចកជាដើម) សុទ្ធតែមានសូររលកប្លែកៗគ្នា ។ ដើម្បីអោយអ្នកសិក្សាយល់ពីបន្ទែកជំពូកនេះ គេអាចយកមកបង្ហាញនូវការលើកដាក់សំឡេងនៃបែបល្បះផ្សេងៗ ក្នុងភាសាបារាំង សិន ។

**៤.១- <u>ការលើកដាក់សំឡេងក្នុងល្បះនានានៃភាសាបារាំង</u>**

**៤.១.១- <u>ការលើកដាក់សំឡេងនៃល្បះប្រកាស</u>** (l'intonation des phrases déclaratives).

**៤.១.១.១- <u>ល្បះដែលមានកន្សោមចង្វាក់ច្រើន</u>** (phrases à plusieurs groupes rythmiques).

(១) ល្បះដែលមានកន្សោមចង្វាក់ពីរ : "l'enfant malade doit être soigné".

ល្បះ : "l'enfant malade doit être soigné" មានកន្សោមចង្វាក់ពីរ : កន្សោមចង្វាក់ទី១ជាកន្សោមចង្វាក់ព្យួរ កន្សោមចង្វាក់ទី២ជាកន្សោមចង្វាក់បង្ហើយ ។ កន្សោមចង្វាក់ព្យួរមានការលើកដាក់សំឡេងឡើងខ្ពស់ កន្សោមចង្វាក់បង្ហើយមានការលើកដាក់សំឡេងចុះទាបនៅខាងចុង ។ គេអាចតាងការលើកដាក់សំឡេងជំពូកនេះដោយប្រើបន្ទាត់ភ្លេង ដូចតទៅ :




---

[៥២] : Op.cit, André Roche, Eléments de prononciation anglaise, p. 127.

[៥៣] : ល្បះបញ្ចោក ប្លែកពីល្បះប្រកាស បញ្ចោកសេចក្តីក្នុងសេចក្តី ច្រើនតែជាកន្សោមដែក ដែលបារាំងហៅថា incise ។

(២) - ល្បះដែលមានកន្សោមចង្វាក់លើសពីពីរ : Je l'ai rencontré à la bibliothèque ce matin[៥៤]

កាលណាមានកន្សោមចង្វាក់លើសពីពីរ កន្សោមចង្វាក់ខាងដើមទាំងប៉ុន្មានជាកន្សោមចង្វាក់ព្យួរ កន្សោមបញ្ចប់ជាកន្សោមចង្វាក់បង្ហើយ ហើយ សូរការលើកដាក់សំឡេងមានចលនាដូចក្នុងល្បះដែលមានកន្សោមចង្វាក់តែពីរដែរ ប៉ុន្តែ មានបន្លែកបន្ថិចបន្តួចនៅត្រង់ថា តើគេចង់សង្កត់លើ "à la bibliothèque" ឬលើ "ce matin" តែប៉ុណ្ណេះ ។ យើងអាចតាងករណីនីមួយៗ ដូចតទៅ :

(២.១) - គេសង្កត់នៅលើជំនួប ÷




(២.២) - គេសង្កត់លើទីកន្លែង ÷




**៤.១.១.២ - ល្បះដែលមានកន្សោមចង្វាក់តែមួយ** (phrases à un seul groupe rythmique).

តាមធម្មតា ក្នុងករណីនេះ គេប្រើការលើកដាក់សំឡេងដូចក្នុងកន្សោមបង្ហើយដែរ ប៉ុន្តែ បើឃ្លាខ្លីខ្លាំងពេក គេប្រើការលើកដាក់សំឡេងចុះភ្លាមតាំងពីដើមដល់ចប់ (ពីព្រោះ ក្នុងករណីនេះ រយៈពេលខ្លីមិនអាចអោយប្រើសូរឡើងសិន ចាំចុះក្រោយបានឡើយ) :

---

[៥៤] ឧទាហរណ៍នេះ និង ឧទាហរណ៍ច្រើនទៀត ខាងក្រោយ ជាឧទាហរណ៍ខ្ចីពី Monique CALLAMEND, L'intonation expressive, ពី Pierre & Monique LEON, Introduction à la phonétique corrective និងពី André ROCHE, Eléments de prononciation anglaise (voir bibliographie).




ដើម្បីអោយគំនូសតាងការលើកដាក់សំឡេងមានការងាយស្រួល គេអាចតាងវាតាមវិធីងាយៗ ដូចតទៅ :

(១) - <u>ដោយខ្សែឡើងចុះទទេ (ឥតបន្ទាត់ភ្លេង)</u> ÷




(២) - <u>ដោយខ្សែឡើងចុះសម្រួល</u> ÷




(៣) - <u>ដោយសញ្ញាព្រួញ</u> ÷




អំណើះតទៅ យើងនឹងយកវិធីទី២មកប្រើសម្រាប់តាងការលើកដាក់សំឡេងនៃល្បះទាំងប៉ុន្មានដែលនៅសល់ ។

**៤.១.២ - <u>ការលើកដាក់សំឡេងក្នុងល្បះសំណួរ</u>** <u>(l'intonation des phrases interrogatives)</u>.

**៤.១.២.១ - <u>សំណួរដោយមានចម្ងល់ទាំងស្រុង</u>** <u>(l'interrogation entière)</u>.

សំណួរដោយមានចម្ងល់ទាំងស្រុង គឺជាសំណួរដែលយើងត្រូវឆ្លើយថា "មែន" ឬ "មិនមែន"។ ចំពោះសំណួរបែបនេះ គេប្រើការលើកដាក់សំឡេងនៃកន្សោមចង្វាក់ព្យួរ ដោយលើកសំឡេងខាងចុងអោយគ្រលួចជាងការលើកដាក់សំឡេងនៃកន្សោមចង្វាក់ព្យួរ ។

<u>ឧទាហរណ៍</u> : Jacques , a-t-il travaillé ?



### ៤.១.២.២ - <u>សំណួរដោយសល់ចម្ងល់ (l'interrogation partielle)</u>.

គឺជាសំណួរដែលគេមិនត្រូវឆ្លើយថា "មែន" ឬ "មិនមែន" នោះទេ គឺគេត្រូវបញ្ជាក់ថា "ប៉ុន្មាន/ពេលណា / ពីព្រោះអ្វី" .... ពីព្រោះគេទុកដូចជាមានចម្លើយមួយមកហើយ : –"មែន ឬ មិនមែន?" – "មែន ! "។ ក្នុងសំណួរបែបនេះ គេប្រើការលើកដាក់សំឡេងនៃកន្សោមចង្វាក់បង្ហើយ ដោយយកសំឡេងឡើងខ្ពស់ទៅជំនួសសំឡេងចុះទាបនៅខាងចុង :

<u>ឧទាហរណ៍</u> : Combien d'heures a-t-il travaillé ?



កាលណាសំណួរមានកន្សោមពាក្យខ្លីពេក គេត្រូវអនុវត្តការលើកដាក់សំឡេងដែលចាប់ផ្តើមពីខ្ពស់មកទាបភ្លាម (ដូចករណីកន្សោមពាក្យខ្លីក្នុងល្បះប្រកាសដែរ ប៉ុន្តែ គេត្រូវលើកសំឡេងអោយខ្ពស់ឡើងវិញនៅខាងចុង)

Quel âge a-t-il ?



### ៤.១.៣ - <u>ការលើកដាក់សំឡេងនៃល្បះបញ្ជា និង ល្បះឧទាន (l'intonation des phrases impératives et des phrases exclamatives)</u>.

<u>ល្បះបញ្ជា</u> : Prouve-le moi ! ------- Allez bien vite !





<u>ល្បះឧទាន</u> : Quel enfant ! -------- C'est bien dommage !





ការលើកដាក់សំឡេងនៃល្បះទាំងពីរប្រភេទនេះមានមូលដ្ឋានដូចគ្នា (ស្វរចុះទាប) ប៉ុន្តែ :

(១) - ចុងបញ្ចប់នៃល្បះបញ្ជាទទួលការរលាស់សំឡេងឡើង

(២) - ចុងបញ្ចប់នៃល្បះឧទានទទួលការរលាក់សំឡេងចុះ ។

គប្បីយើងដឹងថា ល្បះឧទានបង្ហាញនូវសុខុមភាពស្រដៀងៗគ្នាជាច្រើន : ការភ្ញាក់ផ្អើល , សេចក្តីទុក្ខព្រួយ, កំហឹង -ល- ។ ដូច្នេះហើយ ការលើកដាក់សំឡេងនៃល្បះឧទានក៏ត្រូវតែមានសភាពប្លែកគ្នាខ្លះៗមិនខាន ។ ឧទាហរណ៍ខាងលើនេះ តំណាងការលើកដាក់សំឡេងសួររលកនៃល្បះឧទានកណ្តាល កាលណាគេនិយាយតាមសម្រួល ។

### ៤.១.៤- ការលើកដាក់សំឡេងនៃកន្សោមជែក ឬ កន្សោមក្នុងវង់ក្រចក (intonation de l'incise ou parenthèse).

គឺជាកន្សោមបញ្ជាក់ ឬ កន្សោមពន្យល់ ។ វាបន្ថែមសេចក្តីអោយល្បះណាមួយដោយឥតចូលជាធាតុពេញទីនៃល្បះនោះទេ ដូច្នេះហើយ វាគ្មានឥទ្ធិពលអ្វីក្នុងល្បះនោះឡើយ ហើយ វាមានការលើកដាក់សំឡេងស្មើ ( មិនឡើង មិនចុះ) កម្រិតទាប ( គឺសំឡេងគ្រលរ ) ។

ឧទាហរណ៍ : Il viendra, j'imagine, après le dîner.



ព័ត៌មានបន្ថែម : គេអាចប្រើការលើកដាក់សំឡេងសួររលកនៃកន្សោមជែក កាលណាគេប្តូរកន្លែងរវាងកម្មបទ (complément d'objet) និងកម្មទេសកាល (complément circonstanciel) ដូចមានឧទាហរណ៍ខាងក្រោមនេះ :

Il a acheté une voiture pour sa femme en Allemagne.



Il a acheté une voiture en Allemagne, pour sa femme.



### ៤.១.៥- ការលើកដាក់សំឡេងក្នុងកន្សោមផ្តើម និង កន្សោមបញ្ចប់ (l'intonation des têtes de groupe et des queues de groupe).

កន្សោមទាំងពីរប្រភេទនេះ ក៏ដូចកន្សោមជែកដែរ បន្ថែមសេចក្តីអោយល្បះណាមួយដោយឥតចូលជាធាតុពេញទីនៃល្បះនោះទេ ។

#### ៤.១.៥.១- កន្សោមផ្តើម

Monsieur, voulez-vous me donner le dictionnaire ?



"Monsieur" ជាកន្សោមផ្ដើម (មុនល្បះស្នូលចាប់ចេញដំណើរ) មានការលើកដាក់សំឡេងស្មើ (មិនឡើងមិនចុះ) កម្រិតទាប (សំឡេងគ្រលរ) យកកម្ពស់តាមកន្សោមស្នូលដែលផ្ដើមល្បះ។

### ៤.១.៥.២ - **កន្សោមបញ្ចប់**

Entrez, s'il vous plaît !



C'est toi , ma chérie?



កន្សោម "s'il vous plaît" និងកន្សោម "ma chérie" ជាកន្សោមបញ្ចប់ តពីចំណប់ល្បះស្នូល មានការលើកដាក់សំឡេងស្មើ (មិនឡើង មិនចុះ)។ រីឯ កម្ពស់សូរវិញ វាទាប/ខ្ពស់ គឺអាស្រ័យតាមកម្ពស់សូររបស់កន្សោមដែលបញ្ចប់ល្បះស្នូល :

- "s'il vous plaît" មានកម្រិតទាប ពីព្រោះកន្សោមខាងឆ្វេង ("entrez") មានកម្រិតទាប ។
- "ma chérie" មានកម្រិតខ្ពស់ ពីព្រោះកន្សោមខាងឆ្វេង ("C'est toi") មានកម្រិតខ្ពស់ ។

កំណត់សម្គាល់ : គំរូនៃការលើកដាក់សំឡេងដូចមានខាងលើនេះជាការលើកដាក់សំឡេងធម្មតា កាលណាគេនិយាយតាមសម្រួល ដោយឥតស្វែងរកវោហារសាស្ត្រ/វិសេសវិសាលភាព ។ បើគេស្វែងរកវោហារសាស្ត្រ/វិសេសវិសាលភាព គេអាចច្នៃការលើកដាក់សំឡេងអោយមានសុខុមភាពប្លែកៗជាច្រើនបែប ។

## ៤.២ - **ការលើកដាក់សំឡេងក្នុងល្បះនានានៃភាសាខ្មែរ**[៥៥] :

### ៤.២.១ - **ការលើកដាក់សំឡេងនៃល្បះប្រកាស** :

#### ៤.២.១.១ - **ល្បះដែលមានកន្សោមចង្វាក់តែមួយ** :

ឯង ឆ្កួត ។ ខ្ញុំមិន ចង់បាន ទេ ។

[៥៥] : ការលើកដាក់សំឡេងទាំងប៉ុន្មានបែបខាងក្រោមនេះអាចល្អៀងត្រង់កន្លែងខ្លះ សូមលោកអ្នកមេត្តាជួយកែតម្រូវតាមការគួរ : ខ្ញុំអរគុណទុកជាមុន ។

**៤.២.១.២- <u>ល្បះដែលមានកន្សោមចង្វាក់ច្រើន</u> :**

ជនពិការកម្ពុជា នឹងមានសង្ឃឹម ជានិច្ច ។

<u>ការសង្កេត</u> : ការលើកដាក់សំឡេងខាងលើនេះ សម្គាល់ការនិយាយស្ដិធម្មតា ។ បើគេសំដែងកំហឹង ឬ មនោសញ្ចេតនាអ្វីប្លែកពីធម្មតា ការលើកដាក់សំឡេងអាចមានទិដ្ឋភាពផ្សេង ។ ការលើកដាក់សំឡេងទី២អាចក្លាយទៅជាការលើកដាក់សំឡេង ដូចខាងក្រោមនេះ :

ខ្ញុំ មិនចង់ បានទេ ។

**៤.២.២- <u>ការលើកដាក់សំឡេងនៃល្បះសំណួរ</u> :**

**៤.២.២.១- <u>សំណួរដោយចម្លល់ទាំងស្រុង</u> :**

ឯង ចង់ទៅលេងកំពង់ សោមទេ ?

ឯង យល់ទេ ?

**៤.២.២.២- <u>សំណួរដោយមានសល់ចម្ងល់</u> :**

ឯងធ្វើ ការប៉ុន្មានថ្ងៃ មួយអាទិត្យ ? បាន ប៉ុន្មាន ?

**៤.២.៣- <u>ការលើកដាក់សំឡេងនៃល្បះឧទាន</u> :**

**៤.២.៣.១- <u>ល្បះដែលមានកន្សោមចង្វាក់តែមួយ</u> :**

ថ្លៃ ណាស់ !

**៤.២.៣.២- <u>ល្បះដែលមានកន្សោមចង្វាក់លើសពីមួយ</u> :**

ស្រី នេះល្អអស្ចារ្យមែន !

**៤.២.៤- <u>ការលើកដាក់សំឡេងនៃល្បះបញ្ជា</u> :**

ចូលមក !　　　ឈប់ត្រង់ហ្នឹងហើយ !

**៤.២.៥ - ការលើកដាក់សំឡេងនៃកន្សោមដែក ឬ កន្សោមវង់ក្រចក :**

គាត់ប្រហែលជាមិនមកទេ　តាមខ្ញុំស្មាន　ពីព្រោះគាត់មិនស្លូវស្រួលខ្លួន !

សង្កេតមើល : ការលើកដាក់សំឡេងនៃកន្សោមដែកមានកម្ពស់ទាបហើយស្មើ ឥតទាក់ទងនឹងកម្ពស់របស់កន្សោមចង្វាក់ខាងមុខ ឬ ខាងក្រោយទេ ( បើដូចគ្នានោះ វាជាចៃដន្យ ) ។

**៤.២.៦ - ការលើកដាក់សំឡេងក្នុងកន្សោមបើក :**

ម៉ានេត្រ　ឈប់ត្រង់ហ្នឹងហើយ !

សង្កេតមើល : ការលើកដាក់សំឡេងរបស់កន្សោមផ្ដើមមានកម្ពស់ដូចការលើកដាក់សំឡេងនៃកន្សោមដែលផ្ដើមល្បះស្នូល ។

**៤.២.៧ - ការលើកដាក់សំឡេងក្នុងកន្សោមបញ្ចប់ :**

ចូលមក　កូនស្រី !

សង្កេតមើល : ការលើកដាក់សំឡេងរបស់កន្សោមបញ្ចប់មានកម្ពស់ដូចការលើកដាក់សំឡេងនៃកន្សោមដែលបញ្ចប់ល្បះស្នូល ។

## លំហាត់

១- សូមអោយឈ្មោះសូរ (ព្យញ្ជនៈ/ស្រៈ) ក្រោយពីបានបំផុសលក្ខណៈបន្លឺរបស់សូរនីមួយៗ តាមរយៈគំនូរប្រដាប់បន្លឺសំឡេងនីមួយៗខាងក្រោមនេះ ដែលបង្ហាញសរីរាង្គកំពុងដំណើរការ :

១.១- <u>សូរព្យញ្ជនៈ</u>




១.២- <u>សូរស្រៈ</u>



២- សូមអោយឈ្មោះសូរ (ព្យញ្ជនៈ/ស្រៈ) តាមរយៈលក្ខណៈបន្លឺរបស់សូរនីមួយៗ ដូចមានពណ៌នាខាងក្រោមនេះ :

(១) - សូរមាត់ រង្វះបន្ទុះ បន្លឺបបូរមាត់ ឃោសៈ សិថិល ។

(២) - សូរមាត់ រង្វះបន្ទុះ បន្លឺបបូរមាត់ អឃោសៈ ធនិត ។

(៣) - សូរច្រមុះ(នាសិកជៈ) រង្វះបន្ទុះ បន្លឺធ្មេញ ឃោសៈ សិថិល ។

(៤) - សូរមាត់ រង្វះត្រដុស បន្លឺធ្មេញ អឃោសៈ ។

(៥) - សូរមាត់ រង្វះត្រដុស បន្លឺកន្ទើត ឃោសៈ ។

(៦) - សូរមាត់ រង្វះព្យញ្ជនៈ-ស្រៈ បន្លឺក្រអូម ឃោសៈ ។

(៧) - សូរមាត់ រង្វះស្រៈបិទ បន្លឺមុខ បបូរមាត់វែង ។

(៨) - សូរមាត់ រង្វះស្រៈបិទកន្លះ បន្លឺក្រោយ បបូរមាត់វង់ ។

(៩) - សូរច្រមុះ រង្វះស្រៈបើកកន្លះ បន្លឺមុខ បបូរមាត់វែង ។

(១០) - សូរច្រមុះ រង្វះស្រៈបើក បន្លឺក្រោយ បបូរមាត់វង់ ។

៣- សូមប្រើអក្ខរក្រមសូរវិស័យអន្តរជាតិ (API) ដើម្បីកត់ត្រាអត្ថបទសរសេរដោយអក្ខរាវិរុទ្ធខ្មែរ ខាងក្រោមនេះ :

(១) - ក្មេងស្រីតូចនេះបានអង្គុយលើជីរជាប់គូទ ក្រោកមិនរួច ហើយ យំស្ទើរបាត់ស្មារតី ។

(២) - សឿន ស្រីមុល អាយុ១២ឆ្នាំ ជាសិស្សថ្នាក់ទី២ សាលាបឋមសិក្សាគោកបញ្ជាន់បាន និយាយថា : "ប្អូនមិនបានទៅរៀនគួរអ្វីទេ នៅពេលវិស្សមកាល ព្រោះគ្មានលុយបង់ ដោយសារជីវភាពគ្រួសារខ្វះខាត ដូច្នេះត្រូវតែជួយរកលុយគ្រួសារខ្លះ" ។

ស្រីមុលបានបន្តថា : នេះជាឆ្នាំទី២ហើយដែលប្អូនជួយរកលុយគ្រួសារនៅពេលវិស្សមកាល ។ ឆ្នាំមុនប្អូនលក់ផ្លែស្វាយនិងផ្លែក្រូច តែដោយឡែកឆ្នាំនេះ លក់ពោតស្ងោរនិងពោតអាំង ។

(ស្រង់ពីកាសែតរស្មីកម្ពុជា ថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ២០០៣ , ទំព័រ១២)

៤- សូមប្រើអក្ខរក្រមសូរវិស័យអន្តរជាតិ (API) ដើម្បីកត់ត្រាអត្ថបទសរសេរដោយអក្ខរាវិរុទ្ធ បារាំង ខាងក្រោមនេះ :

Je trace une tettre. C'est un O. Devant ce O , je trace une autre lettre. Vous lisez ZO ; comme zoo , comme zona , comme zodiaque. Nous avons appris ça à la maternelle . C'est très important , vous allez le voir . Dans l'autre coin du tableau , je trace un A . Devant le A , j'écris un W , ce qui fait WA , n'est-ce pas ? WA , comme wapiti , le grand cerf canadien , WA , comme ce que les Français appellent waters . Nous sommes bien d'accord ? Alors , je vous le demande , si WA s'écrit W.A et si ZO s'écrit bien Z.O, comment se fait-il que le nom de ce volatile s'écrive O.I.S.E.A.U. et non W.A.Z.O ? Comment se fait-il que pour écrire ce mot , quatre lettres suffisent et que pourtant pas une d'entre elles ne soit employée ?

Hervé BAZIN (Plumons l'oiseau)

៥- សូមប្រើអក្ខរក្រមសូរវិស័យអន្តរជាតិ (API) ដើម្បីកត់ត្រាអត្ថបទសរសេរដោយអក្ខរាវិរុទ្ធ អង់គ្លេស ខាងក្រោមនេះ :

A SNOB

Mr. Warburton was a snob. He was not a timid snob, a little ashamed of being impressed by his betters, nor a snob who sought intimacy of person who had acquired celebrity in politics or notoriety in the arts, nor the snob who was dazzled by riches; he was the naked, common snob who dearly loved a lord. It was marvellous to watch the ingenuity he used to mention his distant relationship to the noble family he belonged to; but never a word did he say of the honest Liverpool manufacturer from whom, through his mother, a Miss Gubbins, he had come by his fortune . The great whom he adored laughed at him, but in their hearts felt his adoration not unnatural.

W. Somerset Maugham (The outstation)

(យកពី André Roche, Eléments de prononciation anglaise , Masson 1959, p. 174 )

៦- បាតុភូតបម្រែសូរ (changement phonétique) បានធ្វើអោយអក្ខរាវិរុទ្ធបារាំង ដែលជាអក្ខរាវិរុទ្ធសទ្ទតាវិស័យ ក្លាយទៅជាអក្ខរាវិរុទ្ធសទ្ទតាវិស័យស្ទួចស្តើង : ជារឿយៗ មានគម្រោងចង់កែតម្រូវអក្ខរាវិរុទ្ធនេះ តែក្រុមអភិរក្សនិយមតែងតែឈ្នះក្នុងការប្រឆាំង ។

ដោយផ្អែកលើមតិរបស់លោកសូសេរ៍ដែលថា "ភាសាជាសូរ មិនមែនជាអក្សរទេ" និង លើពតិមានទាក់ទងនឹងអក្ខរាវិរុទ្ធអ៊ីតាលី/អេស្ប៉ាញ ,... និង លើបញ្ញាញាណសុភវិនិច្ឆ័យរបស់អ្នកផង សូមអ្នកបញ្ចេញយោបល់ បញ្ជាក់ពីផលល្អនិងផលអាក្រក់ចំពោះភាសាបារាំង បើសិនណាជាមានការកែអក្ខរាវិរុទ្ធបារាំងអោយទៅជាអក្ខរាវិរុទ្ធសទ្ទតាវិធីឡើងវិញ ។

៧- សូមប្រៀបធៀបសូរសង្កត់ខ្មែរ និង សូរសង្កត់បារាំង ។

៨- សូមប្រៀបធៀបការលើកដាក់សំឡេងក្នុងភាសាខ្មែរ និង ការលើកដាក់សំឡេងក្នុងភាសាបារាំង ។

# គន្ថនិទ្ទេស


- CALLAMAND Monique - L'intonation expressive. Exercices systématiques de perfectionnement, Hachette/Larousse 1974.
- CARTON Fernand - Introduction à la phonétique du français, Bordas 1974.
- CHOMSKY Noam & HALLE Morris , Principes de phonologie générative, Editions du Seuil , 1973.
- DELL François - Les règles et les sons. (Introduction à la phonologie générative), Hermann 1973.
- GRAMMONT Maurice - Traité de phonétique, Delagrave 1960.
- HAUDRICOURT André G., THOMAS Jacqueline M. C. - La notation des langues : phonétique et phonologie, Institut géographique nationale 1967.
- LEON Monique - Exercices systématiques de prononciation française, Hachette/ Larousse 1976.
- LEON Pierre , Précis de phonostylistique , Nathan , 1993.
- LEON Pierre & Monique - Introduction à la phonétique corrective, Hachette/ Larousse 1977.
- LEON Pierre - Laboratoire de langues et correction phonétique, Didier 1967.
- MALMBERG Bertil - La phonétique, P. U. F. (Que sais-je ? ) 1975.
- MALMBERG Bertil – les nouvelles tendances de la linguistique, P.U.F. 1966
- MARCHAND F. - La phonétique et ses applications, Delagrave 1975.
- MOUCHON J. , FILLOL F. - Pour enseigner l'oral, Editions CEDIC 1980.
- ROCHE André. J. - Eléments de prononciation anglaise, Masson et Cie 1959.
- THOMAS J. M. C., BOUQUIAUX L. , CLOAREC-HEISS F. - Initiation à la phonétique, P. U. F. 1976.
- TROUBETZKOY Nicolaï - Principes de phonologie, Editions Klincksieck, 1976.
- VIEL Michel - La phonétique de l'anglais, P. U. F. (Que sais-je ? ).


x x

x

## <u>បញ្ជីពាក្យបច្ចេកទេស ដែលមាន ក្នុងសិក្សាកថានេះ</u>

### ខ្មែរ -បារាំង

- កន្ទើត : luette
- កន្សោមចង្វាក់ : groupe rythmique
- កន្សោមដែក/ល្បះដែក : incise
- កន្សោមដង្ហើម : groupe de souffle
- កម្ពស់សូរ ( គ្រលួច-គ្រលរ ) : hauteur du son
- កម្មទេសកាល : complément circonstanciel
- កម្មបទ : complément d'objet
- កម្សោយសូរ : amuissement
- ការសម្របសូរ : assimilation
- ការសម្របសូរទៅតាមសូរខាងមុខ : assimilation progressive
- ការសម្របសូរទៅតាមសូរខាងក្រោយ : assimilation régressive
- ការសម្របសូរទ្វេគុណ : assimilation double
- ការសម្របសូរពីចម្ងាយ : dilation
- កាឡាសូរ : allophone
- កាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី : allophone en varieation libre
- ក្រអូមលេខនី : palatographe
- ការលើកដាក់សំឡេង : intonation
- ការលើកដាក់សំឡេងនៃកន្សោមបិទ : intonation des queues de groupe
- ការលើកដាក់សំឡេងនៃកន្សោមបើក : intonation des têtes de groupe
- ខ្សែសំឡេង : cordes vocales
- គម្ករ : résonance
- គុហាផ្លូវច្រមុះ : cavité nasale
- គុហាផ្លូវមាត់ : cavité buccale

- គូក្រោមអប្បបរមា : paire sous-minimale
- គូអប្បបរមា : paires minimales
- គ្រសនី : pharynx
- ឃោសៈ/លឺ : sonore
- ដើមបំពង់ខ្យល់ : larynx
- ដំណូរទីតាំង : interversion
- ដំណូរទីតាំងពីចម្ងាយ : métathèse
- តម្រង : filtre
- ត្រីស្វរៈ : triphtongue
- ទីបន្លឺ : points d'articulation
- ទោស្វរៈ : diphtongue
- ធនិត : aspiré
- និយ័ត : régulier
- បដិកាឡាសូរ : allophones en distribution complémentaire
- បរិបទ : contexte/environnement
- បរិមាណ : quantité
- បំប្លែកសូរ : différenciation
- បំប្លែកសូរពីចម្ងាយ : dissimilation
- ប្រពលភាព : intensité
- ប្រតិចារឹកអក្សរ : translitération
- ព្យញ្ជនៈកន្លះ : semi-consonne
- ពាក្យកម្លាយ : mots dérivés
- វនាំងក្រអូម : voile du palais
- លក្ខណៈបន្លឺ/សញ្ញាតាបន្លឺ : trait articulatoire

- លំញ័រ : vibration
- លំញ័រលេខនី : kymographe
- លំញាប់ : fréquence
- លំញាប់បំប៉ន : formant
- ល្បឺ : timbre
- ល្បឿង : amplitude
- ល្បះបញ្ជា : phrase impérative
- ល្បះប្រកាស : phrase déclarative
- ល្បះសំណួរ : phrase interrogative
- ល្បះឧទាន : phrase exclamative
- វដ្ដ : cycle
- វិទ្យុលេខនៈ : radiographie
- សទ្ទតា : phonème
- សរុបនិទ្ទេស : récapitulatif
- សិថិល : non aspiré
- សុខុមភាព : nuances / subtilités
- សូរគ្រឹះ : (son) fondamental
- សូរទោល : son simple
- សូរផៅសន្ដាន : son apparenté / son proche
- សូរត្រដុស : fricative
- សូរខ្យល់ : aperture
- សូរបន្ទុះ : occlusive
- សូរព្យញ្ជនៈ-ស្រះ : semi-consonne/ semi-voyelle
- សូរលំហូរ : liquide

- សូរច្រមុះ ( នាសិកជៈ ) : nasale
- សូរមាត់ ( មុខជៈ ): orale
- សូរបំពង់ក : laryngale
- សូរក្រអូម : palatale
- សូរគល់ធ្មេញ : alvéolaire
- សូរដើមក : glottale
- សូរធ្មេញ : dentale
- សូរបបូរមាត់ : labiale
- សូរបបូរមាត់-ធ្មេញ : labio-dentale
- សូររនាំងក្រអូម : vélaire
- សូរល្បាយ : son à articulations complexes
- សូររលាត : latérale
- សូររលាស់ : vibrante
- សូរល្បាយ : son complexe
- សូរវិទ្យា : phonétique
- សូរវិទ្យាបង្គុំធាតុ : phonétique combinatoire
- សូរវិទ្យាបន្លឺ : phonétique articulatoire
- សូរវិទ្យាអាគូស្ទិក : phonétique acoustique
- សូរសង្កត់ : accent
- សូរសង្កត់ក្នុងពាក្យ : accent du mot
- សូរសាខា : (son) harmonique
- សូរសៀងវិទ្យា : Etude de la prosodie / prosodologie
- ស្មៀង : ton
- សំរាំងពាក្យ : corpus de mots

- ស្រៈទោល : voyelles simples
- ស្រៈនិស្ស័យ : voyelles dépendantes
- ស្រៈផ្សំ : voyelles combinées
- ស្រៈពេញតួ : voyelles indépendantes
- ហឺត្ស : Hertz
- អក្ខរក្រមសូរវិស័យអន្តរជាតិ : A P I (Alphabet Phonétique Internationale)
- អឃោសៈ/ថ្លង់ : sourde
- អញ្ញថាភាព : subjectivité
- អតិសទ្ទតា : archiphonème
- អន្តៃបទ : infixe

----

## បារាំង - ខ្មែរ

- A P I (Alphabet Phonétique Internationale) : អក្ខរក្រមសូរវិស័យអន្តរជាតិ
- accent : សូរសង្កត់
- accent du mot : សូរសង្កត់ក្នុងពាក្យ
- allophone : កាឡាសូរ
- allophone en variation libre : កាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី
- allophones en distribution complémentaire : បដិកាឡាសូរ
- alvéolaire : សូរគល់ធ្មេញ
- amplitude : ល្បឿង
- amuissement : កម្សោយសូរ
- aperture : រង្វះខ្យល់
- archiphonème : អតិសទ្ទតា

- articulations complexes : បន្លឹល្បាយ
- aspiré : ធនិត
- assimilation : ការសម្របសូរ
- assimilation double : ការសម្របសូរទ្វេគុណ
- assimilation progressive : ការសម្របសូរទៅតាមសូរខាងមុខ
- assimilation régressive : ការសម្របសូរទៅតាមសូរខាងក្រោយ
- cavité buccale : គុហាផ្លូវមាត់
- cavité nasale : គុហាផ្លូវច្រមុះ
- complément circonstanciel : កម្មទេសកាល
- complément d'objet :កម្មបទ
- contexte/environnement : បរិបទ
- cordes vocales : ខ្សែសំឡេង
- corpus de mots : សំរាំងពាក្យ
- cycle : វដ្ដ
- dentale : សូរធ្មេញ
- différenciation : បំប្លែកសូរ
- dilation : ការសម្របសូរពីចម្ងាយ
- diphtongue : ទោស្វរៈ
- dissimilation : បំប្លែកសូរពីចម្ងាយ
- épiglotte : សន្ទះបំពង់ខ្យល់
- Etude de la prosodie / prosodologie : សូរសៀងវិទ្យា
- filtre : តម្រង
- formant : លំញោប់បំប៉ន
- fréquence : លំញោប់

- fricative : សូរត្រដុស
- glottale : សូរដើមក
- groupe de souffle : កន្សោមដង្ហើម
- groupe rythmique : កន្សោមចង្វាក់
- hauteur du son : កម្ពស់សូរ ( គ្រលួច-គ្រលរ)
- Hertz : ហឺត្ស
- incise : កន្សោមដែក/ល្បះដែក
- infixe : អន្តបទ
- intensité : ប្រពលភាព
- interversion : ដំណូរទីតាំង
- intonation : ការលើកដាក់សំឡេង
- intonation des queues de groupe : ការលើកដាក់សំឡេងនៃកន្សោមបញ្ចប់
- intonation des têtes de groupe : ការលើកដាក់សំឡេងនៃកន្សោមផ្ដើម
- kymographe : លំញ័រលេខនី
- labiale : សូរបបូរមាត់
- labio-dentale : សូរបបូរមាត់-ធ្មេញ
- laryngale : សូរដើមបំពង់ខ្យល់
- larynx : ដើមបំពង់ខ្យល់
- latérale : សូររលាត
- liquide : សូរលំហូរ
- métathèse : ដំណូរទីតាំងពីចម្ងាយ
- mots dérivés : ពាក្យកម្លាយ
- nasale : នាសិកជៈ/ខ្យល់ច្រមុះ
- non aspiré : សិថិល

- nuances / subtilités : សុខុមភាព
- occlusive : សូរបន្ទុះ
- orale : មុខជះ /ខ្យល់មាត់
- paire sous-minimale : គូក្រោមអប្បបរមា
- paires minimales : គូអប្បបរមា
- palatale : សូរក្រអូម
- palatographe : ក្រអូមលេខនី
- pharynx : គ្រសនី
- phonème : សទ្ទតា
- phonétique : សូរវិទ្យា
- phonétique acoustique  សូរវិទ្យាអាគូស្ទិក
- phonétique articulatoire : សូរវិទ្យាបន្លឺ
- phonétique combinatoire : សូរវិទ្យាបង្គុំធាតុ
- phrase déclarative : ល្បះប្រកាស
- phrase exclamative : ល្បះឧទាន
- phrase impérative : ល្បះបញ្ជា
- phrase interrogative : ល្បះសំណួរ
- points d'articulation : ទីបន្លឺ
- quantité : បរិមាណ
- radiographie : វិទ្យុលេខនៈ
- récapitulatif : សរុបនិទ្ទេស
- régulier : និយ័ត
- résonance : គម្ពុរ
- semi-consonne : ព្យញ្ជនៈកន្លះ

- semi-consonne/ semi-voyelle : សូរព្យញ្ជ-ស្រៈ
- son apparenté / son proche : សូរផៅសន្តាន
- son complexe : សូរល្បាយ
- son fondamental : សូរគ្រឹះ
- son harmonique : សូរសាខា
- son simple : សូរទោល
- sonore : ឃោសៈ/លឺ
- sourde : អឃោសៈ/ថ្លង់
- subjectivité : អញ្ញថាភាព/អត្តវិស័យភាព
- timbre : ល្បឺ
- ton : ស្នៀង
- trait articulatoire : សញ្ញាតាបន្លឺ
- translitération : ប្រតិអក្សរចារឹក
- triphtongue :ត្រីស្វរៈ
- vélaire : សូរនាំងក្រអូម
- vibrante : សូររលាស់
- vibration : លំញ័រ
- voile du palais : រនាំងក្រអូម
- voyelles combinées : ស្រៈផ្សំ
- voyelles dépendantes : ស្រៈនិស្ស័យ
- voyelles indépendantes : ស្រៈពេញតួ
- voyelles simples : ស្រៈទោល

# ឧបសម្ព័ន្ធ

ដើម្បីអោយអ្នកមានលទ្ធភាពប្រៀបធៀប ដូចខ្ញុំបានសន្យាក្នុងសិក្សាកថាខ្ញុំ ខ្ញុំសុំដាក់ជាឧបសម្ព័ន្ធនូវប្រព័ន្ធសូរព្យញ្ជនៈ និង ប្រព័ន្ធសូរស្រៈរបស់បណ្ឌិត ឃួន សុខម្ភ ដូចខាងក្រោមនេះ :

## ១ - សូរព្យញ្ជនៈ :

| | Occlusives | | | Nasales | Fricatives | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | simples | | aspirées | | spir. | siffl. | latér. | vibr. | mouil. | asp. |
| | - | + | - | + | + | - | + | + | + | - |
| bilabiales | p | b | ph | m | | | | | | |
| labio - dentales | | | | | v | | | | | |
| alvéolaires | t | d | th | n | | s | l | r | | |
| palatales | c | | ch | ɲ | | | | | j | |
| vélaires | k | | kh | ŋ | | | | | | |
| laryngales | | | | | | | | | | h |
| glottales | ʔ | | | | | | | | | |

## ២ - សូរស្រៈ :

### ២.១ - សូរស្រៈទោល

(voyelles simples)

| Antérieures | Moyennes | Postérieures | |
|---|---|---|---|
| non arrondies | non arrondies | non arrondies | arrondies |
| i: - អ៊ី  i - អ៊ិ<br>ẹ: - អេ  ẹ - អិ<br>e: - អ៊េ<br>ɛ: - អ៊ែ  ɛ- អ៊ែ់ | ɯ:- អ៊ឺ  ɯ - អ៊ឹ<br>œ:- អឺ  œ - អឹ<br>ə - អឹ | ɤ - អ៊ើ | u: - អ៊ូ  u - អ៊ុ<br>ọ: - អូ  ọ - អុ<br>o - អ៊ោ<br>ɔ: - អ៊  ɔ - អ៊ |

| | | | |
|---|---|---|---|
| a: - អា | | u: - អ u - អ់<br>a - អា | |

## ២.២ - ស្វរស្រៈផ្សំ

(voyelles combinées)

ie - អៀ ei – អី ɛi - អ៊ី ɯə- អឿ uə - អួ oa: ai - អៃ

iə - អ៊ា់ ɛa - អ៊ា əu - អៅ oa au - អៅ ɔa - អ៊័រ

ao - អោ

aə - អើ

aɛ - អែ

សេចក្ដីបញ្ជាក់ : អំណោយឈ្មោះស្រះជាអក្សរខ្មែរជាទង្វើរបស់អ្នករៀបរៀងសិក្សាកថា ខាងដើមនេះ ( បណ្ឌិត ឃួន សុខម្ មិនបានអោយឈ្មោះស្រះជាអក្សរខ្មែរ ទេ ក្នុងអត្ថបទដើមរបស់គាត់) ។

# មាតិកា

## សញ្ញាណខ្លះៗនៃសូរវិទ្យាអាគូស្ទិក

- បុព្វយោគ ...................................................................................... ទំព័រ ១

១- កំណើតសូរ & លក្ខណៈសំខាន់ៗនៃសូរ (production du son) ................. --- ២

១.១- លំញ័រ <ញ័រ (vibrations)........................................................... --- ៣

១.២- វេលា (période) ឬ វដ្ត (cycle)................................................ --- ៤

១.៣- រលក (ondes) ........................................................................ --- ៤

១.៤- លំញាប់ < ញាប់ (fréquence) & ហឺត្ស (Hertz)........................... --- ៥

១.៥- កម្ពស់ (hauteur) .................................................................... --- ៥

១.៦- ល្បើង < ឡើង (amplitude)...................................................... --- ៦

១.៧- ប្រពលភាព (intensité)........................................................... --- ៦

១.៨- ល្បឺ < លឺ/ឮ (timbre)................................................................ --- ៦

២- បាតុភូតឧបសម្ព័ន្ធនៃសូរ ................................................................ --- ៦

២.១- សូរទោល និង សូរល្បាយ ........................................................... --- ៦

២.២- កម្ទរនៃសូរ (résonance du son)............................................... --- ៧

២.៣- លំញាប់បំប៉ន (formant)........................................................... --- ៨

## សូរវិទ្យាបន្លឺ

១- ប្រដាប់បន្លឺសំឡេង : ទ្រង់ទ្រាយនិងដំណើរការ (description et fonctionnement de l'appareil phonatoire) .................................... --- ៩

២- ចំណាត់ថ្នាក់រវាងសូរ ...................................................................... --- ១២

២.១- ចំណាត់ថ្នាក់រវាងសូរដែលកើតឡើងដោយបន្លឺទោល (classification des sons à articulations simples)........................................... --- ១២

២.១.១- ចំណាត់ថ្នាក់ផ្អែកលើផ្លូវដែលខ្យល់ចេញពីសួតមកក្រៅ (classification fondée sur les voies de sortie de l'air)................................. --- ១២

២.១.២- ចំណាត់ថ្នាក់ផ្អែកលើមុខងារខ្សែសំឡេង (classification

fondée sur le rôle des cordes vocales) ........................... --- ១៣
២.១.៣- ចំណាត់ថ្នាក់ផ្អែកលើរង្វះខ្យល់ (classification fondée sur l'aperture) ........................... --- ១៦
២.១.៣.១- ឈ្មោះសូរតាមរង្វះខ្យល់ (dénomination des sons d'après leur degré d'aperture) ........................... --- ១៦
២.១.៣.២- បន្លែករវាងព្យញ្ជនៈនិងស្រៈ (différenciation entre les consonnes et les voyelles) ........................... --- ១៧
២.១.៤- ចំណាត់ថ្នាក់នៃសូរផ្អែកលើទីបន្លឺ (classification fondée sur le point d'articulation) ........................... --- ១៨
២.១.៤.១- អំណោយឈ្មោះព្យញ្ជនៈ (dénomination des consonnes)..... --- ១៩
២.១.៤.២- អំណោយឈ្មោះស្រៈ (dénomination des voyelles).......... --- ១៩
២.១.៥- អំណោយឈ្មោះទាំងមូលដល់ ព្យញ្ជនៈ និង ស្រៈនីមួយៗ (dénomination complète de chaque consonne et voyelle).... --- ២០
២.២- សូរកើតពីបន្លឺល្បាយ ........................... --- ២១
២.២.១- ព្យញ្ជនៈ (consonnes) ........................... --- ២១
២.២.១.១- ព្យញ្ជនៈដែលមានរង្វះខ្យល់មួយ និង ទីបន្លឺពីរ ........................... --- ២១
២.២.១.២- ព្យញ្ជនៈដែលមានរង្វះខ្យល់ពីរ និង ទីបន្លឺមួយ ........................... --- ២១
២.២.២- ស្រៈ (voyelles) ........................... --- ២១
៣- សរុបនិទ្ទេស អំពីសូរដោយតារាង ........................... --- ២២

**<u>សូរវិទ្យាបង្គុំធាតុ</u>**

១- កម្សោយសូរ (amuissement)........................... --- ២៤
២- ការសម្រួបសូរ (assimilation) ........................... --- ២៤
២.១- និយមន័យ និង ឧទាហរណ៍ (définitions & exemples)........................... --- ២៤
២.១.១- ការសម្រួបសូររវាង ព្យញ្ជនៈ និង ព្យញ្ជនៈ (assimilation de consonne à consonne) ........................... --- ២៤
២.១.២- ការសម្រួបសូររវាងស្រៈ និង ព្យញ្ជនៈ (assimilation entre voyelle & consonne) ........................... --- ២៥

២.១.៣- ការសម្រុបសូររវាងស្រៈ និង ស្រៈ
(assimilation entre voyelles) ........................................ --- ២៦

២.២- បែបផ្សេងៗនៃការសម្រុបសូរ (divers types d'assimilation)......... --- ២៧

២.២.១- ការសម្រុបសូរតាមសូរខាងមុខ (assimilation progressive).... --- ២៧

២.២.២- ការសម្រុបសូរតាមសូរខាងក្រោយ (assimilation régressive). --- ២៧

២.២.៣- ការសម្រុបសូរទ្វេគុណ (assimilation double) .................... --- ២៧

៣- បំប្លែកសូរ ........................................................................................ --- ២៨

៤- ដំណូរទីតាំង (រវាងសូរ) (interversion) ............................................... --- ២៨

**សទ្ទតាវិទ្យា**

១- បន្លែករវាងសូរវិទ្យា និង សទ្ទតាវិទ្យា តាមរយៈភាសាអ៊ឺរ៉ុប ......................... --- ២៩

១.១- បន្លែករវាងសូរវិទ្យា និង សទ្ទតាវិទ្យា .................................................. --- ៣០

១.១.១- បញ្ញត្តិគន្លឹះ : បរិបទ ...................................................................... --- ៣០

១.១.២- លក្ខណៈវិនិច្ឆ័យសម្គាល់សទ្ទតា ................................................... --- ៣១

១.១.២.១- លក្ខណៈវិនិច្ឆ័យផ្អែកលើគូអប្បបរមា ............................................ --- ៣១

(១) - សូរនិងសទ្ទតា .......................................................................... --- ៣១

(២) - សទ្ទតានិងកាឡាសូរ (phonèmes & allophones)....................... --- ៣២

(២.១) - បដិកាឡាសូរ (allophones en distribution complémentaire) --- ៣៤

(២.២) - កាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី (allophones
en variation libre)........................................................... --- ៣៥

១.១.២.២- លក្ខណៈវិនិច្ឆ័យផ្អែកលើគូ.ក្រោមអប្បបរមា
(paires sous-minimales) .................................................... --- ៣៥

១.១.២.៣- លក្ខណៈវិនិច្ឆ័យផ្អែកលើបំណិទ-បំណើកនៃព្យាង្គ និង ទីតាំង
ក្នុងព្យាង្គ (ព្យាង្គមុខ/ព្យាង្គកណ្តាល/ព្យាង្គក្រោយ) ..................... --- ៣៦

១.១.២.៣.១- សិក្សាអំពីសូរ ........................................................................ --- ៣៧

១.១.២.៣.២- វិភាគរកសទ្ទតា .................................................................. --- ៣៨

១.១.២.៣.៣- តារាងសទ្ទតា ...................................................................... --- ៤១

(១) - តារាងសទ្ទតាព្យញ្ជនៈ ............................................................ --- ៤១

(២) - តារាងសទ្ទតាស្រៈ ................................................................ --- ៤១

១.១.២.៤- លក្ខណៈវិនិច្ឆ័យផ្អែកលើទំនាក់ទំនងព្យញ្ជនៈ-ស្រៈ និង ស្រៈ-ព្យញ្ជនៈ --- ៤១

១.២- សទ្ទតា និង អតិសទ្ទតា (phonèmes et archiphonèmes).................. --- ៤៣

២- បន្លែករវាងសូរនិងសទ្ទតា ក្នុងភាសាខ្មែរ ................................................ --- ៤៤

២.១- សូរនិងសទ្ទតានៃភាសាខ្មែរ ................................................................ --- ៤៥

២.១.១- សូរនៃភាសាខ្មែរ ........................................................................... --- ៤៥

២.១.១.១- តារាង(សូរ)ព្យញ្ជនៈ ................................................................ --- ៤៦

២.១.១.២- តារាង(សូរ)ស្រៈ ...................................................................... --- ៤៨

(១) - តារាង(សូរ)ស្រៈទោល ............................................................... --- ៤៨

(២) - តារាង (សូរ) ស្រៈផ្សំ ................................................................. --- ៤៨

២.១.២- សទ្ទតានៃភាសាខ្មែរ ....................................................................... --- ៥១

២.១.២.១- សទ្ទតាព្យញ្ជនៈ ........................................................................ --- ៥១

២.១.២.២- សទ្ទតាស្រៈ .............................................................................. --- ៥៣

២.២- ព្យាង្គ(syllabe) ............................................................................. --- ៥៦

២.៣- អក្សរខ្មែរនិងសូរនៃភាសាខ្មែរ ............................................................ --- ៥៧

២.៣.១- សញ្ញាព្យញ្ជនៈនិងសូរព្យញ្ជនៈតាមរយៈប្រតិចារឹកអក្សរ
(translitération) & តាមរយៈអក្សរសូរវិស័យអន្តរជាតិ
(Alphabet phonétique international > API) ........................... --- ៥៨

២.៣.២- សញ្ញាស្រៈនិងសូរស្រៈ ................................................................... --- ៦០

(១) - ស្រៈពេញតួ (voyelles indépendants) មាន១២តួ ......................... --- ៦០

(២) - សញ្ញាស្រៈនិស្ស័យ ( signes-voyelles dépendants) មាន២៥តួ ....... --- ៦១

**<u>សូរសៀងវិទ្យា</u>**

១- បរិមាណ (la quantité) ......................................................................... --- ៦៣

២- ស្នៀង (le ton) ...................................................................................... --- ៦៣

៣- សូរសង្កត់ (l'accent) ............................................................................ --- ៦៤

៣.១- សូរសង្កត់ក្នុងពាក្យ (l'accent du mot) ........................................ --- ៦៤

៣.២- សូរសង្កត់ក្នុងកន្សោមចង្វាក់ (l'accent du group rythmique) ....... --- ៦៥

៣.៣- សូរសង្កត់ក្នុងកន្សោមដង្ហើម (l'accent dans le groupes de souffle) ........................................................ --- ៦៦

៤- ការលើកដាក់សំឡេង (l'intonation) ...................................................... --- ៦៧

បុព្វយោគ ........................................................................................ --- ៦៨

៤.១- ការលើកដាក់សំឡេងក្នុងល្បះនានានៃភាសាបារាំង ............................ --- ៦៨

៤.១.១- ការលើកដាក់សំឡេងនៃល្បះប្រកាស (l'intonation des phrases déclaratives) ............................................ --- ៦៨

៤.១.១.១- ល្បះដែលមានកន្សោមចង្វាក់ច្រើន (phrases à plusieurs groupes rythmiques) ............................ --- ៦៨

៤.១.១.២- ល្បះដែលមានកន្សោមចង្វាក់តែមួយ (phrases à un seul groupe rythmique) .................................. --- ៦៩

៤.១.២- ការលើកដាក់សំឡេងក្នុងល្បះសំណួរ (l'intonation des phrases interrogative) ............................................ --- ៧០

៤.១.២.១- សំណួរដោយចម្លើយទាំងស្រុង (l'interrogation entière) ........... --- ៧០

៤.១.២.២- សំណួរដោយសល់ចម្លើយ (l'interrogation partielle) ................ --- ៧១

៤.១.៣- ការលើកដាក់សំឡេងនៃល្បះបញ្ជា និង ល្បះឧទាន (l'intonation des phrases impératives & des phrases exclamatives) .............. --- ៧១

៤.១.៤- ការលើកដាក់សំឡេងនៃកន្សោមដែក ឬ កន្សោមក្នុងវង់ក្រចក (intonation de l'incise ou parenthèse) ............................................... --- ៧២

៤.១.៥- ការលើកដាក់សំឡេងក្នុងកន្សោមផ្ដើម និង កន្សោមបញ្ចប់ (l'intonation des têtes de groupe et des queues de groupe) ................ --- ៧២

៤.១.៥.១- កន្សោមផ្ដើម ........................................................................ --- ៧២

៤.១.៥.២- កន្សោមបញ្ចប់ ...................................................................... --- ៧៣

៤.២- ការលើកដាក់សំឡេងក្នុងល្បះនានានៃភាសាខ្មែរ .................................. --- ៧៣

៤.២.១- ការលើកដាក់សំឡេងនៃល្បះប្រកាស ........................................... --- ៧៣

៤.២.១.១- ល្បះដែលមានកន្សោមចង្វាក់តែមួយ ...................................... --- ៧៣

៤.២.១.២- ល្បះដែលមានកន្សោមចង្វាក់ច្រើន ........................................ --- ៧៤
៤.២.២- ការលើកដាក់សំឡេងនៃល្បះសំណួរ ........................................ --- ៧៤
៤.២.២.១- សំណួរដោយចម្លល់ទាំងស្រុង ........................................ --- ៧៤
៤.២.២.២- សំណួរដោយសល់ចម្ងល់ ........................................ --- ៧៤
៤.២.៣- ការលើកដាក់សំឡេងនៃល្បះឧទាន ........................................ --- ៧៤
៤.២.៣.១- ល្បះដែលមានកន្សោមចង្វាក់តែមួយ ........................................ --- ៧៤
៤.២.៣.២- ល្បះដែលមានកន្សោមចង្វាក់លើសពីមួយ ........................................ --- ៧៤
៤.២.៤- ការលើកដាក់សំឡេងនៃល្បះបញ្ជា ........................................ --- ៧៤
៤.២.៥- ការលើកដាក់សំឡេងនៃកន្សោមដែក ឬ កន្សោមវង់ក្រចក ........... --- ៧៥
៤.២.៦- ការលើកដាក់សំឡេងក្នុងកន្សោមបើក ........................................ --- ៧៥
៤.២.៧- ការលើកដាក់សំឡេងក្នុងកន្សោមបិទ ........................................ --- ៧៥
**លំហាត់** ........................................ --- ៧៦
**គន្លនិទ្ទេស** ........................................ --- ៨០
**បញ្ជីពាក្យបច្ចេកទេសដែលមានក្នុងសិក្សាកថានេះ** ........................................ --- ៨១
**ឧបសម្ព័ន្ធ** ........................................ --- ៩០

# កាលាមសូត្រ

កុំជឿលើអ្វី ដោយគ្រាន់តែអ្នកបានឮ

កុំជឿតាមពាក្យបរម្បរា ដោយសារតែ វាជាប្រពៃណីដែលគេ
ធ្លាប់ជឿរាប់តំណមកហើយ

កុំជឿលើអ្វី ដោយសារតែ មានគេនិយាយ និង ជាពាក្យចចាម
អារ៉ាមតៗគ្នា

កុំជឿលើអ្វី ដោយគ្រាន់តែឃើញថា មានសរសេរនៅក្នុងគម្ពីរ
សាសនារបស់អ្នក

កុំជឿលើអ្វី ដោយសារតែ វាជាពាក្យប្រៀនប្រដៅរបស់គ្រូអ្នក
និងចាស់ទុំរបស់អ្នក

ប៉ុន្តែ ក្រោយពេលបានសង្កេតនិងវិភាគល្អិតល្អន់ និង នៅពេល
ដែលអ្នកយល់ឃើញថា ធមិទាំងនោះវាសមស្របនឹង
វិចារណញ្ញាណ និង ដែលនាំមកនូវគុណប្រយោជន៍ចំពោះ
មនុស្សទូទៅហើយ ពេលនោះ សូមទទួលយកនិងជឿតាមចុះ ។

ព្រះសម្មាសម្ពុទ្ធ

ដកស្រង់ចេញពី **ពុទ្ធប្បវត្តិ ដោយរូបភាព**
និពន្ធដោយព្រះតេជគុណ **ខេមរគោណ សរណ មហាថេរោ**
បោះពុម្ពឡើងវិញ នៅរោងពុម្ពមិត្តភាព កម្ពុជា-ជប៉ុន
ភ្នំពេញ ឧសភា ២០០១
ទំព័រឥតលេខ : ១៧ទំព័រមុនទំព័រទី១